# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE

ឆ្នាំទី ៣៤ លេខ ១០ ខែ តុលា

ព.ស. ២៥០៤ គ.ស. ១៩៦២

- ភ្នំពេញ -

ក-៥២១ក

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

### ផ្នែកសាសនា

ទំព័រ


– ធម្មវិចារណកថា ព្រះសាសនមុនី កឹម-ទួរ រៀបរៀង (ត) . . . . . . . . . ១០៨៣

– គោលច្បាប់ព្រះពុទ្ធសាសនា លោក ហេង-សមអាន តែងនិងរៀបរៀង (ត) . . . ១០៩៤

– ព្រះអភិធម្មបិដក (គម្ពីរព្រះយមកៈ) លោកប៊ូ-ប៊ូ ប្រែរៀបរៀង (ត) . . . . . . ១១០៧

– មធុរសវាហិណី សម្ដេចព្រះធម្មលិខិត ល្វី-ឯម ឧត្ដមប្រឹក្សា ប្រែរៀបរៀង (ត) . . . ១១១៥

– មហោសថជាតក (ត) . . . . . . . . . . . . . . . . ១១២៣


### ផ្នែកអក្សរសាស្ត្រ


– ពាក្យខ្មែរប្រែពីបរទេស ដោយគណៈកម្មការជាតិនៃការសិក្សាផ្នែកអក្សរ "ក" (ត) . ១១៤៣

– វចនានុក្រមសំស្ក្រឹត-ខ្មែរ ព្រះមហា យ៉ាង-ទាត់ រៀបរៀង (ត) . . . . . . . ១១៤៦

– រឿងល្បើកហ្វុងតែន (La Fontaine) លោកផេង-ជ្រីវ ប្រែពីភាសាបារាំង . . ១១៤៩

– រឿងសាមកុក អ្នកឧកញ៉ា នូ-កន ប្រែរៀបរៀង (ត) . . . . . . . . . ១១៦០

– រឿងព្រេងចិន លោក ក៏យ-ប៊ុក ភូឈួយខែត្រតាកែវ ប្រែរៀបរៀង (ត) . . . . ១១៨៤

– ទំនៀមទម្លាប់កុលសម្ពន្ធ លោក ឌឹក-គាម រៀបរៀង . . . . . . . . . ១១៩០


### កំណត់និងប្រវត្តិការណ៍


– ពិធីប្រគេនសញ្ញាប័ត្រឋានៈជាមេគណ ក្រុងភ្នំពេញ ចំពោះព្រះតេជគុណ ភន-កឹង . . ១១៩៧


មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជាវ ២៣០៛០០

34è Année — N° 10 — Octobre 1962

# KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire
publiée par l'Institut - Bouddhique de Phnom-Penh

## SOMMAIRE

### Partie religieuse

—Dhammavicharanakatha par le Vénérable KEM-TO (suite) . . 1083
—Principes bouddhiques par M. HENG-SAM-AN (suite) . . . . 1094
—Préah Abhidhammapitaka «Kampir Préah Yamaka»
par M. BOU-PO (suite) . . . . . . . . . . . . . . . . 1107
—Madhurasavahini par S.Em Préah Dhammalikhita LOUIS-EM
Haut Conseiller (suite) . . . . . . . . . . . . . . . . 1115
—Mahosotha Jataka (suite) . . . . . . . . . . . . . . . . 1123

### Partie littéraire

—Activité de la Commission Culturelle chapitre «Ka» (suite) . . . 1143
—Dictionnaire Sanscrit-Khmer par Vén. PANG-KHAT (suite) . . . 1146
—Fables de la Fontaine traduites par M. PHÉNG-CHRIV. . . . 1149
—Histoire de Sam-Kok traduite par Oknha NOU-KAN (suite) . . . 1160
—Légende Chinoise traduite par M. RAY-BOUC Phouchhouykhèt
de TAKEO (suite) . . . . . . . . . . . . . . . . 1184
—Les mœurs et coutumes des Tribus au Cambodge
par M. DIK-KEAM . . . . . . . . . . . . . . . . . . . 1190

### Notes et chroniques

—Cérémonie de cession de brevet portant nommination de Vénérable
RÉACH-KING comme Mékun de Phnom-Penh . . . . . . . 1197

Prix d'Abonnement annuel (comprenant 12 numéros) : 230$ 00

# ធម្មវិចារណកថា

ព្រះសាសនមុនី ភីម-គុរ រៀបរៀង

(តមក)

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការណាមក ឲ្យធ្វើល្អទៅ ។
ឲ្យផុសខាត់ចិត្ត កុំឲ្យហ្មងសៅ
បីនេះលោកហៅ ពុទ្ធសាសនា ។
ប.ព.

សេចក្ដីខ្វះ ជាមូលហេតុនាំឲ្យកើតសាសនា ដូចម្ដេច? ធម្មតា មនុស្ស រមែងមានចិត្តមិនតាំងនៅនឹងទៀងទាត់ជាប្រក្រតីទេ គឺមានការខ្វះខាត មិនចេះគ្រប់គ្រាន់ កាលបើខ្លួនជាមនុស្សខ្សត់ខ្សោយ ហើយបានទទួលសេចក្ដីសុខ-ចំរើន អំពីរបស់ណាដែលគេនិយមរាប់អាន ក៏ឈោងចាប់យករបស់នោះមកជាទីពឹងពំនាក់ ឬបើស្រឡាញ់គាប់ចិត្តចំពោះវត្ថុណា ដែលខ្លួនសំគាល់ថាឲ្យសុខឲ្យចំរើន ក៏ទទួលរាប់អានលើកតំកើងវត្ថុនោះ ថាជារបស់ខ្ពង់ខ្ពស់មានគុណវិសេសស័ក្ដិសិទ្ធិ ក៏នាំគ្នាទៅសម្ដែងសេចក្ដីរាប់អានបន់ស្រន់បួងសួង គោរពបូជាដោយគ្រឿងសក្ការៈ

ដើម្បីនឹងឲ្យបានទៅជាដូច្នេះ ដូច្នោះ សមតាមបំណងរបស់ខ្លួន សេចក្ដីខ្វះខាតនេះឯង ជាមូលហេតុនាំឲ្យកើតសាសនាដែរ ។

មូលហេតុទាំង ៣ យ៉ាង ដែលបានអធិប្បាយមកនេះ ជាផ្លូវនាំឲ្យកើតសាសនា ក៏ពិតមែន ប៉ុន្តែបើបំព្រួញឲ្យខ្លីចុះមកមានតែមួយ គឺនៅត្រង់សេចក្ដីខ្លាចហ្នឹងឯងជាសមុដ្ឋាន នាំឲ្យកើតសាសនា ។

ពាក្យថា សាសនៈ ឬ សាសនា នេះ មានន័យជ្រាលជ្រៅណាស់ បើតាមសេចក្ដីដែលយើងធ្លាប់ប្រែមកគឺប្រែថា " ពាក្យប្រៀនប្រដៅ ពាក្យមណ្ដាំ " រហូតដល់មកប្រែថា « សំបុត្រ ដំណឹង លទ្ធិ » ។ ល ។ ផងទៀត ។ ត្រង់ពាក្យប្រែថា « ប្រៀនប្រដៅ » ពាក្យនេះមិនខុសទេ ពិតជាត្រូវសមល្អណាស់ ប៉ុន្តែត្រូវសមនៅក្នុងថ្នាក់ខាងកាយ គឺក្នុងគ្រាដែលគេរៀបចំចងក្រងបង្កើតជាក្បួនតម្រាជាច្បាប់ឡើង សម្រាប់ឲ្យមនុស្សសិក្សា ជឿ ស្ដាប់ គោរព បូជា កាន់អាន តាមលំអាន ច្បាប់ជាតម្រាយស្រាប់ៗ ដែលមានមកហើយ ទើបប្រែថា ពាក្យប្រៀនប្រដៅ តែបើតាមមតិរបស់ខ្ញុំ ពាក្យថា សាសនា នេះ គួរប្រែថា ធម្មជាតិជាទីពឹងឬជាបង្អែកនៃចិត្តឬនៃជីវិតក៏បាន ព្រោះថាមនុស្សក្នុងសម័យដែលទើបនឹងកកើតឡើងជាដំបូង រមែងមានសេចក្ដីស្រឡាញ់ហួងហែងជីវិតរបស់ខ្លួន ម្ល៉ោះហើយក៏តាំងរាករស្វែងរកវត្ថុដ៏ស័ក្ដិសិទ្ធិជាបង្អែកឲ្យជាទីទុកចិត្តកក់ក្ដៅនៃជីវិត ដូចសេចក្ដីដែលបានពណ៌នាពីខាងដើមមកហើយ ថា

មូលហេតុ ៣ យ៉ាង គឺ សេចក្តីខ្លាច សេចក្តីត្រូវការ សេចក្តីខ្វះខាត ទាំងនេះណាមួយ បណ្តាលទឹកចិត្តរបស់មនុស្សឲ្យស្វែងរកវត្ថុជាបង្អែកនៃជីវិត ។

ដល់មកត្រង់នេះ ខ្ញុំត្រូវត្រឡប់ងាកទៅនិយាយពីកុសលបញ្ជាក់ជាថ្មីម្តងទៀតថា ក្នុងខាងដើមនេះ បាននិយាយថា ព្រហ្មញ្ញសាសនា ឬសាសនាព្រាហ្មណ៍ បើតាមប្រវត្តិសាស្ត្រគឺមានតាំងពីបរមបុរាណមុនពុទ្ធកាលមកម្ល៉េះ ។ សាសនានេះ ក៏មាននិយាយពីកាមាវចរកុសល រូបាវចរកុសល និងអរូបាវចរកុសល ហើយមានយោគី តាបស បុគ្គល អ្នកជឿស្តាប់គោរពប្រតិបត្តិតាម អាចឈោងចាប់យកគុណវិសេស ហើយបានទៅកើតក្នុងទេវលោក ព្រហ្មលោក ដូចអ្នកដែលប្រតិបត្តិតាមខាងផ្លូវពុទ្ធសាសនាដែរ បើសាសនានេះ មានសេចក្តីប្រតិបត្តិល្អបានកុសលដូចជាពុទ្ធសាសនាដែរ តើខាងពុទ្ធសាសនាមានប្រយោជន៍អ្វី ? បើមានតែព្រហ្មញ្ញសាសនាមួយប៉ុណ្ណោះ ហាក់ដូចជាគ្រប់គ្រាន់ដែរហើយ ចុះហេតុអ្វីចាំបាច់មានពុទ្ធសាសនា កើតឡើងជាគូប្រជែងទៀត តើពុទ្ធ-សាសនាមានឧត្តមគតិ និងគុណវិសេសខ្ពស់ជាងយ៉ាងណាខ្លះ? សាសនាដទៃក្រៅពីពុទ្ធសាសនា ច្រើនតែសាសនាបដិរូប ប្រែថា សាសនាប្លម ឬថាសាសនាមិនបរិសុទ្ធមានលាយដោយការពិតខ្លះ មិនពិតខ្លះ ប្រៀបដូចមាសដែលលាយដោយជាតិលោហៈផ្សេងៗមានទង់ដែងជាដើម មាស

នោះក៏ក្លាយទៅជារបស់មិនសុទ្ធ ឬហៅថាមាសមិនគ្រប់ទឹក ១០ ក៏ដូច្នោះដែរ ព្រោះហេតុអ្វី? ព្រោះហេតុថា សាស្តាចារ្យអ្នកមេប្រឌិតបង្កើតសាសនានោះៗឡើង ជាមនុស្សនៅប្រកបដោយកាមកិលេសមិនបរិសុទ្ធ ឯសា-សនានោះក៏មិនបរិសុទ្ធដែរ ព្រោះគេប្រឌិតបង្កើតឡើង ដោយការរិះរកគួរគាន់ឬដោយការស្មានប្រមាណយកតែតាមយោបល់របស់ខ្លួនៗ សាសនានេះមានគម្ពីរប្រៀនប្រដៅសត្វ ឲ្យសត្វប្រតិបត្តិបំពេញត្រឹមតែកុសល ៣ យ៉ាង មានកាមាវចរកុសលជាដើមប៉ុណ្ណោះ ទោះបីកុសលថ្នាក់ណាក៏សុទ្ធតែនៅក្នុងវង្វង់វដ្តតាមកុសលទាំងអស់ ហើយចង្អុលបង្ហាញលទ្ធផលដល់អ្នកដែលប្រតិបត្តិតាម ឲ្យបានត្រឹមតែសម្បត្តិមនុស្ស សម្បត្តិទេវតាសម្បត្តិព្រហ្ម ដែលហៅថា សម្បត្តិក្នុងកាមភព រូបភព អរូបភពប៉ុណ្ណោះ នេះឯងជាការបញ្ជាក់ឲ្យឃើញច្បាស់ថា សាសនានេះប្រៀនប្រដៅដឹកនាំសត្វអ្នកប្រតិបត្តិតាម ឲ្យវិលវល់ជាប់នៅក្នុងវង្វង់ភព ឬលោកទាំង ៣ នេះ មិនអាចរកផ្លូវ រកច្រកចេញឲ្យផុតចាកលោកទាំង ៣ នេះទៅបានឡើយ ។

ក្នុងចំណោមអ្នកកាន់សាសនានេះ មានគ្រូជាសាស្តាធំៗ ខ្លះដែលជាអ្នកប្រដៅខ្ពុនាឧបរិស័ទ គេមានយោបល់យល់ក្នុងអរិយសច្ចស្រដៀងនឹងអរិយសច្ចរបស់ព្រះសម្មាសម្ពុទ្ធ ដែលព្រះអង្គទ្រង់សម្តែងដែរ ដូចជាសាស្តាឈ្មោះ និគ្គន្ថនាដបុត្ត គាត់យល់ថា សេចក្តីទុក្ខគ្រប់យ៉ាង

ដែលបៀតបៀនសត្វ បណ្តាលមកតែអំពីកិលេស គឺតណ្ហា ធម៌ដែលនាំឲ្យអស់តណ្ហាគឺនិរោធ ធម៌ដែលធ្វើទៅហើយ នាំឲ្យបាននិរោធនោះ គាត់មិនយល់ថា ត្រូវធ្វើតាម អដ្ឋង្គិកមគ្គ (មគ្គប្រកបដោយអង្គ ៨ មានសម្មាទិដ្ឋិជាដើម) ទេ គាត់ត្រឡប់ជាយល់ថា ត្រូវធ្វើតាមអត្តកិលមថានុយោគវត្ត គឺប្រព្រឹត្តតបវត្តយ៉ាងតឹងរ៉ឹង មានការប្រព្រឹត្តអង្គុយហាលកំដៅថ្ងៃ ឬ ចុះត្រាំទឹកក្នុងរដូវរងាជាដើមឯណោះទៅវិញ នេះឯងជាការបញ្ជាក់ឲ្យឃើញថា សាសនា នេះ មិនបរិសុទ្ធ មិនស្គាល់ហេតុផលដោយច្បាស់លាស់ ។

ចំណែកខាងពុទ្ធសាសនា ទើបជាសាសនាដ៏បរិសុទ្ធ ជាសាសនាមានឧត្តមគតិប្រកបដោយហេតុផល ច្បាស់លាស់ជាងសាសនាដទៃឯទៀត ដែលយើងនិយាយនេះ មិនមែនដោយសារថា ខ្ញុំជាអ្នកកាន់ពុទ្ធសាសនាហើយ ក៏បេះតែនិយាយអួតកាន់ជើងខាងពុទ្ធសាសនាទៅមិនមែនដូច្នោះទេ ។ ពុទ្ធសាសនា ពិតជាសាសនាបរិសុទ្ធប្រកបដោយហេតុផល គួរឲ្យជឿស្តាប់កាន់គោរពប្រតិបត្តិតាមមែនៗ ពីព្រោះព្រះពុទ្ធព្រះអង្គជាម្ចាស់នៃពុទ្ធសាសនានេះ ជាអច្ឆរិយមនុស្សគឺជាមនុស្សអស្ចារ្យមួយរូប ដែលមានព្រះហឫទ័យដ៏បរិសុទ្ធស្អាតចាកគ្រឿងសៅហ្មង ដែលយើងបានដឹងប្រវត្តិរបស់ព្រះអង្គមកហើយ សឹងមានសេចក្តីរាំកនុកក្នុងគម្ពីរជាច្រើនអន្លើថា ព្រះពុទ្ធកាលដែលនៅក្នុងឋានៈជាពោធិសត្វ ទំព្យា

យាមបំពេញបារមីធម៌ អស់រយៈកាល ៤ អសង្ខេយ្យ និង ១ សែនកប្ប គ្រាប់ផ្គិតវិលវល់ក្នុងវាលវដ្ដសង្សារ ដើម្បីតែពោធិញ្ញាណ ។ ក្នុងកំឡុង ៤ អសំខេយ្យ និង ១ សែនកប្បនោះ ទោះបីព្រះអង្គអន្ទោលទៅកើតក្នុងកំណើតនៃមនុស្ស ឬ អមនុស្ស ឬ ក៏សត្វអ្វីក៏ដោយ ក៏សុទ្ធតែជាការពិសោធន៍ការរកពោធិញ្ញាណ ដើម្បីសេចក្ដីសុខ សេចក្ដីបរិសុទ្ធផុតចាកទុក្ខតែម្យ៉ាងប៉ុណ្ណោះ ដរាបដល់មកកើតក្នុងជាតិជាទីបំផុតដែលមានបរមនាមជា សិទ្ធត្ថៈ ។ ដោយអំណាចស្នាមគំនូសដែលធ្លាក់ជិតជាប់ក្នុងព្រះហឫទ័យប្រព្រឹត្តទៅក្នុងពោធិញ្ញាណដែលហៅថា ឧបនិស្ស័យនោះ មិនរលត់បាត់ ក៏បន្ទំឲ្យព្រះអង្គចេញសាងព្រះផ្នួស ស្វែងរកពោធិញ្ញាណជាលើកក្រោយបង្អស់ ដរាបដល់បានជួបនឹងពោធិញ្ញាណ ដែលយើងនាំគ្នាហៅថា ព្រះពុទ្ធ ឬហៅថា ព្រះអង្គត្រាស់ដឹង ។ ពាក្យថាត្រាស់ដឹងនេះ ជាពាក្យខ្ពស់ពិបាកស្ដាប់ បើប្រែឲ្យងាយស្ដាប់មកទៀតថា ស្រាវជ្រាវរកឃើញ គឺព្រះអង្គទ្រង់រកឃើញនូវធម៌ពិត ជាធម៌ល្អិតជ្រាលជ្រៅ ជាធម៌កប់កំបាំង ពុំដែលមាននរណាដឹង ឬ រកឃើញដល់ម្ដងសោះ ទើបតែមានព្រះពុទ្ធគ្រប់ព្រះអង្គរកឃើញមុនគេ បានជាលោកទាំងមូលនាំគ្នាសន្មតហៅព្រះអង្គថា ព្រះពុទ្ធអ្នកត្រាស់ដឹង ។

ក្នុងសម័យដែលព្រះអង្គបានត្រាស់ដឹងជាព្រះពុទ្ធហើយ ទ្រង់ប្រកាសធម្មៈរបស់ព្រះអង្គដែលហៅថា ពុទ្ធសាសនា ក្នុងលទ្ធិសាសនា

ព្រាហ្មណ៍ដែលមានមកជាយូរអង្វែងហើយ ។ សាសនាព្រាហ្មណ៍នេះ បែកចេញទៅជាលទ្ធិ ជាសាខាធំៗ ជាច្រើនតទៅទៀត ដែលមានឈ្មោះថា សាសនាជេន សាសនានិគ្រន្ថ សាសនាបរិពាជក និងសាសនារបស់គ្រូទាំង ៦ មានគ្រូឈ្មោះបូរណកស្សបជាដើម សាសនាទាំងអស់នេះ សុទ្ធតែមានន័យគឺពាក្យប្រៀនប្រដៅបរិស័ទ ឲ្យប្រតិបត្តិទេរទៅរកខាងកាមសុខល្លិកានុយោគ និងអត្តកិលមថានុយោគទាំងអស់ ។ ឯពុទ្ធសាសនា ព្រះអង្គទ្រង់សម្តែងវែកញែកចង្អុលប្រាប់ពន្យល់ឲ្យស្គាល់ផ្លូវវៀច ផ្លូវត្រង់ជាមុនគឺឲ្យស្គាល់ថា ផ្លូវនេះទៅកាន់អបាយភូមិ ផ្លូវនេះទៅកាន់ទេវលោក ផ្លូវនេះទៅកាន់ព្រហ្មលោក ផ្លូវនេះទៅកាន់និព្វាន ទើបព្រះអង្គទ្រង់ណែនាំសត្វឲ្យប្រតិបត្តិធម្មៈ ដើរទៅក្នុងផ្លូវកណ្តាលជាចន្លោះនៃកាមសុខល្លិកានុយោគ និងអត្តកិលមថានុយោគ ឬហៅថា មជ្ឈិមាបដិបទា ជាសេចក្តីប្រតិបត្តិប្រព្រឹត្តទៅក្នុងប្រឡោះកណ្តាល មិនធូរពេក មិនតឹងពេក គឺមិនចូលទៅខាងកាមសុខល្លិកានុយោគ និងអត្តកិលមថានុយោគ ។

ពុទ្ធសាសនានេះ ជាសាសនាមានឧត្តមគតិដ៏ល្អបរិសុទ្ធប្រកបដោយហេតុផល ទោះបីព្រះអង្គសម្តែងអំពីកុសលថ្នាក់ណាក៏ដោយ កុសលថ្នាក់នោះ សុទ្ធតែឈមមុខឆ្ពោះទៅរកខាងវិវដ្តគាមិកុសលទាំងអស់ ជាកុសលអាចញ៉ាំងអ្នកប្រតិបត្តិតាមឲ្យរួចផុតចាកទុក្ខទាំងពួង ដែលមានប្រចាំ

នៅក្នុងលោកទាំង ៣ ឆ្ពោះទៅកាន់និព្វាន បើអ្នកប្រតិបត្តិតាមពុទ្ធសាសនា មិនទាន់ដើរទៅដល់ទីដៅគោលគឺនិព្វានទេ មិនហៅថាជាអ្នកបានទទួលលទ្ធផលនៃសេចក្ដីប្រតិបត្តិតាមពុទ្ធសាសនានៅឡើយ ។

ពុទ្ធសាសនា ជាសាសនាមានវគ្គ មានសង្កាត់ មានរបៀបរៀបរយតាមលំដាប់លំដោយល្អណាស់ មានអត្ថការធ្វើអ្នកប្រតិបត្តិតាមឲ្យមានដំណើរត្រង់ផ្លូវ មិនឲ្យកាន់ប្រឡំ មិនឲ្យវៀចវេរទៅរកផ្លូវខុស ដូចបរិយត្តិ ( ការសិក្សា ) ការសិក្សានេះជាជំហានឆ្ពោះទៅរកបដិបត្តិ ( សេចក្ដីប្រតិបត្តិ ) គឺការប្រព្រឹត្តកាន់តាម សេចក្ដីប្រតិបត្តិនេះជាជំហានឆ្ពោះទៅរក បដិវេធ: ( ការត្រាស់ដឹង ) ការត្រាស់ដឹងនេះជាប្រភពនៃមគ្គនឹងផល មគ្គនឹងផលនេះជាប្រភពនៃនិព្វាន និព្វានទើបជាទីបំផុតនៃលោក និព្វានជាលទ្ធផលនៃការសិក្សានឹងសេចក្ដីប្រតិបត្តិ ត្រង់នេះឯងជាការបញ្ជាក់ឲ្យឃើញច្បាស់ថា ពុទ្ធសាសនា ជាសាសនាមានឧត្តមគតិល្អវិសេសខ្ពស់ផុតជាងសាសនាឯទៀតទាំងអស់ ។

ពុទ្ធសាសនា ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងទុកជាឱវាទទាំងប៉ុន្មាន ដែលក្រុមព្រះសង្គីតិការចារ្យ បានប្រមូលរៀបចំទុកដាក់តាមពួកតាមក្រុម កំណត់ហៅថា វិន័យ ព្រះសូត្រ ព្រះអភិធម្ម ប្រដាប់ដោយធម្មក្ខន្ធ ៨.៤០០០ ធម្មក្ខន្ធ មានចំនួនច្រើនយ៉ាងណាក៏ដោយ ក៏សុទ្ធតែជាឱវាទមានគោលបំណងធ្វើអ្នកប្រតិបត្តិតាម ឲ្យបែរមុខឆ្ពោះទៅ

កេនិព្វានតែម្យ៉ាងប៉ុណ្ណោះ ។ ប៉ុន្តែឯយើងជាពុទ្ធបរិស័ទ ទាំងបព្វជិត ទាំងគ្រហស្ថ ដែលបានប្រកាសខ្លួនថាជាពុទ្ធសាសនិក (អ្នកកាន់ពុទ្ធសាសនា) ត ៗ មកនៅនាសម័យបច្ចុប្បន្ននេះ កាលបើប្រារព្ធបំពេញករណីយកិច្ចណាមួយក្នុងពុទ្ធសាសនាដោយកាយ វាចា ចិត្ត ច្រើនធ្វើដោយសេចក្ដីយៀងឃ្លាត ឬដោយការកាន់ច្រឡំ ព្រោះហេតុនោះខ្ញុំសូមទាញយកឧទាហរណ៍របស់អ្នកដែលមានគំនិតគិតខុសឬកាន់ច្រឡំក្នុងអំពើដែលខ្លួនធ្វើដែលខ្លួនគិតនោះមកលាតត្រដាងឲ្យឃើញជាតួយ៉ាងខ្លះ ក្នុងទីនេះ៖

បព្វជិតខ្លះ ដែលបួសហើយភ្លេចនាទី ឬមុខការរបស់ខ្លួន ដែលខ្លួនត្រូវតែធ្វើ ត្រូវតែបំពេញឲ្យខានពុំបាន ។ ត្រៃសិក្ខាគឺ សីល សមាធិ បញ្ញា ជានាទី ឬមុខការរបស់បព្វជិត ។ ត្រូវតែយកចិត្តទុកដាក់បំពេញគឺត្រូវប្រតិបត្តិតាម ប៉ុន្តែបព្វជិតខ្លះ បណ្ដែតបណ្ដោយខ្លួនឲ្យនៅទំនេរ មិនសូវអើពើ ធ្វើហាក់ដូចជាថាត្រៃសិក្ខាមិនមែនជានាទីរបស់ខ្លួនទៅវិញ បែរជាទៅខ្វល់ខ្វាយយកចិត្តទុកដាក់ចំពោះកិច្ចការណាផ្សេងដែលព្រះពុទ្ធជាម្ចាស់មិនបានតម្រូវដាក់ឲ្យនោះទៅវិញ ឬបើទុកជាមានពុទ្ធានុញ្ញាតឲ្យធ្វើបានខ្លះដែរ ប៉ុន្តែការធ្វើនោះ ទៅជាជ្រុលជ្រួសហួសប្រមាណ មិនសមរម្យជាកិច្ចការដែលបព្វជិតគួរធ្វើ នេះឈ្មោះថាជាការកាន់ច្រឡំទី ១ របស់បព្វជិត ។

បព្វជិតខ្លះក្នុងសម័យបច្ចុប្បន្ន កាលបើបានឡើងកាន់ឋានៈជាអ្នកមួយ

មានកិត្តិយសប្រហែលទីនបព្វជិតក្នុងសម័យពុទ្ធកាល ដែលបានសម្រេចគុណវិសេសព្រោះហេតុអ្វី ? ព្រោះហេតុថា បព្វជិតក្នុងសម័យពុទ្ធកាលបើអង្គណាមួយបានសម្រេចគុណវិសេសគឺមគ្គផលហើយ តែងមានបរិស័ទនាំគ្នាចោមរោមពោលសរសើរ សម្ដែងសេចក្ដីគោរពគប់គាប់បូជាដោយគ្រឿងសក្ការៈ យ៉ាងណា ឯបព្វជិតដែលបានឋានៈណាមួយ ក៏មានបរិស័ទចោមរោមសរសើរគោរព រាប់អានបូជាដោយគ្រឿងសក្ការៈដូច្នោះដែរ ម្ល៉ោះហើយបព្វជិតនោះ ក៏ស្រវឹងនឹងឋានៈរបស់ខ្លួនដោយសារគ្រហស្ថរាប់អានលើកតំកើងនោះ ក៏ទើរតំនិតកើលនៅត្រឹមនោះទៅ ជាហេតុឲ្យភ្លេចបំពេញត្រៃសិក្ខាដែលជាករណីយកិច្ចរបស់ខ្លួន ដែលខ្លួនត្រូវប្រតិបត្តិទៅ នេះឈ្មោះថាជាការកាន់ប្រឡូវទី ២ របស់បព្វជិត ។

កុលបុត្តគេហជាគ្រហស្ថ ឈ្មោះថាជាអ្នកនៅក្នុងចំណោមកាម ស្វែងរកកាម បរិភោគកាម ទទួលសេចក្ដីសុខក្នុងកាម កាលបើកាមមានការវិបត្តិប្រែប្រួលបណ្ដាលឲ្យទុក្ខទោសកើតឡើង ក៏មានសេចក្ដីនឿយណាយធុញទ្រាន់ស្អប់ខ្ពើមកាម មិនចង់ឲ្យជួបប្រទះនឹងកាមនោះតទៅទៀត ដោយបានដឹងច្បាស់ថា សេចក្ដីទុក្ខទោសទាំងអស់ដែលធ្វើមនុស្សសត្វឲ្យបានទទួលនូវទុក្ខវេទនាគ្រប់យ៉ាង គឺបណ្ដាលមកតែអំពីកាមហ្នឹងឯងជាហេតុ ។ កុលបុត្តនោះ លុះបានដឹងច្បាស់ដូច្នេះហើយ ក៏រកឧបាយដោះដៃគេចចេញអំពីកាមនោះ គឺប្រឹងចិត្តលះបង់កាម ទាំងលះបង់គេហ

ខ្លួនជាគ្រហស្ថផង ចូលមកកាន់ភេទជាបព្វជិត លុះបានភេទជាបព្វជិតហើយ ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ជាក់ខ្ពស់ ដើម្បីធ្វើនូវធម៌ជាទីបំផុតនៃទុក្ខដែលកើតអំពីកាមនោះចេញ នេះមិនដូច្នោះ បែរត្រឡប់ជាប្រព្រឹត្តព្រហ្មចរិយធម៌ថោកទាបថយក្រោយ ដើម្បីទៅរកកាមក្នុងលោកនេះ ឬក្នុងលោកខាងមុខដែលទៅវិញ ។ គ្រង់ពាក្យថា ដើម្បីទៅរកកាមក្នុងលោកនេះ គឺដើម្បីឲ្យបានឋានៈជានេះ ជានោះ ក្នុងបច្ចុប្បន្ននេះ គ្រង់ពាក្យថា ដើម្បីទៅរកកាមក្នុងលោកខាងមុខ គឺដើម្បីឲ្យបានសម្បត្តិក្នុងកពជាទេវតានេះ ជាទេវតានោះ ឬជាទេវតាណាមួយក្នុងលោកខាងមុខដោយអំណាចព្រហ្មចរិយធម៌របស់អាត្មាអញនេះ ។ បើបព្វជិតបណ្ដោយចិត្ត ឬបណ្ដោយទាំងកាយទាំងចិត្តឲ្យស្អាបអន្ទ្រល ប្រឡែងប្រឡូកជាមួយនឹងគ្រឿងកាមដូចជាគ្រហស្ថដែល តើការទ្រាំសម្ងំនៅធ្វើជាភេទបព្វជិតបែបនេះ នឹងមានប្រយោជន៍អ្វីខ្លះដែរឬទេ ? នេះឈ្មោះថាជាការកាន់ប្រឡូកទី ៣ របស់បព្វជិត ។

(នៅមានត)

# គោលច្បាប់នៃព្រះពុទ្ធសាសនា

## បាកធម្មបទ - ខុទ្ទកនិកាយ

*លោក ហោង-សមអាន រៀបរៀង*

( តមក )

---

រីគោនន្ទិវិសាលឃើញម្ចាស់សោកស្តាយដូច្នោះ ក៏ចូលទៅនិយាយថា "បពិត្រព្រាហ្មណ៍! សូមអ្នកទៅភ្នាល់ម្តងទៀតចុះ ដាក់ប្រាក់ ២០០០ កហាបណៈ ប៉ុន្តែត្រូវអ្នកនិយាយពាក្យល្អ កុំថាគោកៀចដូចមុនទៀតឡើយ" ។ ព្រាហ្មណ៍ឮហើយក៏ទៅនិយាយភ្នាល់ម្តងទៀត ក្នុងពេលបញ្ចារទេះនោះ ព្រាហ្មណ៍ពោលនឹងនន្ទិវិសាលថា "ហៃគោដ៏ចំរើន ចូរអ្នកអូសទេះនេះទៅ" ។ នន្ទិវិសាលបានឮសំដីម្ចាស់ជាទីគាប់ចិត្ត ក៏ខំអូសទេះ ១០០ ដែលមានទម្ងន់ហួសប្រមាណបានផុតទីភ្នាល់ភ្លាម ។ ព្រាហ្មណ៍ជាម្ចាស់ត្រូវឈ្នះបានប្រាក់ ២០០០ កហាបណៈ ។

ព្រោះហេតុនោះ ព្រះមុនីលោកនាថទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ផរុសវាចាដែលបុគ្គលបានពោលហើយ ជាអំពើប្រព្រឹត្តទៅដើម្បីអបាយ គឺនាំឱ្យអន្តរាយបាត់ញាតិ-មិត្ត និងជនក្រោមបង្គាប់ ។ សំដីទ្រគោះតែងនាំឱ្យខកការ ដែលបំរុងធ្វើដំណើររកៀនទៅ ។ ជនពោលទ្រគោះបោកបោះនោះ លុះទម្លាយរាងកាយទៅទៀតតែងទៅកើតក្នុងនរក

រូបពីនរកមកកើតជាប្រេត រូបពីប្រេតមកកើតជាអសុរកាយ រូបពីអសុរកាយមកកើតជាតិរច្ឆាន រូបពីតិរច្ឆាន មកកើតជាមនុស្ស តែជាមនុស្សដូចប្រទះតែពាក្យទ្រគោះបោះបោកគំរាមពីអ្នកដទៃ ។

ផរុសវាចា ជាពាក្យអាក្រក់ លោកឲ្យឈ្មោះថា មាប ជាពាក្យមិនគួរពោលឡើយ

៧- សម្ផប្បលាប គឺការពោលនូវពាក្យរេយរាយ ឥតប្រយោជន៍

សម្ផប្បលាបវាចា ជាសំដីរេយរាយធ្វើឲ្យអ្នកស្ដាប់រាយមាយចិត្ត អ្នកនិយាយលេះលោះ អាចញុំាងអាការៈឲ្យអ្នកដទៃឃើញថា ជាមនុស្សលេះលោះ គ្មាននរណាយកជាមុខជាមាត់អ្វីទេ ។

បុគ្គលណាពោលនូវពាក្យឥតប្រយោជន៍ បុគ្គលនោះឈ្មោះថា អធម្មវាទី គឺអធម្មវាទីអាចញុំាងព្រះសទ្ធម្មឲ្យអន្តរធានទៅ ។ ដូចមានព្រះពុទ្ធដីកាថា យេ ចេ តេ ភិក្ខវេ ភិក្ខូ អធម្មំ ធម្មោតិ ។បេ។ សទ្ធម្មំ អន្តរធាបេន្តិ [១] ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយណា ពោលពាក្យមិនមែនធម៌ថាជាធម៌ ភិក្ខុទាំងឡាយនោះប្រតិបត្តិដើម្បីមិនមែនជាគុណដល់ជនមានប្រមាណច្រើន ដើម្បីមិននាំមកនូវសេចក្ដីសុខដល់ជនមានប្រមាណច្រើន

---

១- បាលី អង្គុត្តរនិកាយ ឯកនិបាត ។

ដើម្បីមិនជាប្រយោជន៍ ដើម្បីមិនមែនជាគុណ ដើម្បីសេចក្ដីទុក្ខ ដល់ជនមានប្រមាណច្រើន គឺដល់ទេវតានិងមនុស្សទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ! ភិក្ខុទាំងឡាយនោះតែងរងកម្មដ៏លាមកជាច្រើន ភិក្ខុទាំងឡាយនោះតែងញ៉ាំងព្រះសទ្ធម្មឲ្យអន្តរធានទៅ ។

សម្ផប្បលាបវាទ នេះមានទោសធ្ងន់ណាស់ ។ ឧទាហរណ៍ដូចជា៖

## រឿងកបិលភិក្ខុ

ក្នុងសាសនកាលនៃព្រះសម្មាសម្ពុទ្ធ ព្រះនាមកស្សប មានភិក្ខុ ១ រូប ឈ្មោះ កាបិល ជាពហុស្សូត បានរៀនព្រះត្រៃបិតកចេះដឹងច្រើនហើយ ជាធម្មកថិកយ៉ាងជំនាញ ១ រូបផង មានបរិវារនិងលាភសក្ការៈច្រើន ។ កបិលភិក្ខុ ស្រវឹងដោយពហុស្សូត សំគាល់ខ្លួនថាជាអ្នកប្រាជ្ញ ពោលផ្ទុយនឹងអត្ថដែលអ្នកប្រាជ្ញទាំងឡាយពោលថា គួរ ត្រឡប់ពោលថា មិនគួរវិញ តែងពោលនូវសម្ផប្បលាបក្រៅធម៌វិន័យជាច្រើន កាលបើភិក្ខុទាំងឡាយអ្នកមានសីល ពោលទូន្មានម្ដងៗក៏តែងតែជេរប្រទេចនូវភិក្ខុទាំងឡាយនោះវិញ ។ កបិលភិក្ខុនោះ ស្លាប់ទៅៗកើតក្នុងអវិចីមហានរក មានអណ្ដាតភ្លើងឆេះឡើងសន្ធោសន្ធៅអស់ ១ពុទ្ធន្តរ លុះសេសសល់ផលកម្មលាមក បានមកកើតជាត្រីមានសម្បុរដូចមាស នៅក្នុងស្ទឹងអចិរវតី ប៉ុន្តែមាត់ស្អុយ ។ លុះស្លាប់ពីត្រីទៅកើតក្នុងអវិចីមហានរកវិញដដែល ។

សម្ផប្បលាបវាទ ជាពាក្យអាក្រក់ លោកឲ្យឈ្មោះថា ចាប ជាពាក្យមិនគួរពោលឡើយ ។

## មនោកម្ម

មនោកម្ម គឺអំពើដែលធ្វើអាក្រក់ដោយចិត្ត មាន ៣ យ៉ាង គឺ អភិជ្ឈា ១ ព្យាបាទ ១ មិច្ឆាទិដ្ឋិ ១ ។

៨– អភិជ្ឈា ចិត្តសម្លឹងរំពៃចំពោះទ្រព្យអ្នកដទៃដោយគិតបម្រុងឲ្យបានមកជារបស់ខ្លួន ។

អភិជ្ឈានេះ បើកើតមានក្នុងសន្តានចិត្តនៃបុរសស្ត្រីណាហើយ ក៏ធ្វើនូវសន្តានចិត្តនៃបុរសស្ត្រីនោះឲ្យសៅហ្មង កាលបើចិត្តមិនបរិសុទ្ធជាចិត្តសៅហ្មងហើយ ប្រាកដជាទៅកាន់ទុគ្គតិ គឺទៅកើតក្នុងចតុរាបាយ ក្នុងបច្ចុប្បន្នជាតិនេះក៏ក្តៅក្រហាយមិនសប្បាយក្នុងចិត្ត ព្រោះជាប់ជំពាក់នៅក្នុងវត្ថុដែលខ្លួនប្រាថ្នា កើតវិប្បដិសារីក្តៅក្រហាយពេលកាលក្នុងចិត្ត ឧទាហរណ៍ដូចជា៖

## រឿងព្រះចៅល្មោភរាជសម្បត្តិ[១]

ក្នុងអតីតកាល ព្រះចៅក្រុងពារាណសី ទ្រង់លង់ចូលក្នុងអំណាចនៃអភិជ្ឈា មួយថ្ងៃ ៗ ព្រះរាជហឫទ័យរំពៃបៃរឈមទៅរកព្រះរាជអាណាចក្រឯទៀត ៗ ដោយមិនកំណត់ ។

---

១- ប.ក.ខុទ្ទកនិកាយ ទុកនិបាត ត្រង់តាមទិតសូត្រជាតក ។

ក្នុងខណៈនោះ សក្កទេវរាជ ស្តេចទ្រង់ជ្រាបដោយទិព្វនេត្រនូវចេតនាព្រះចៅពារាណសីហើយ ទើបទ្រង់ត្រិះរិះថា "បើអាត្មាអញព្រងើយកន្តើយ ពិភពលោកនឹងក្តៅក្រហាយ ដោយព្រះរាជាអង្គនេះមិនខាន គួរតែទៅផ្ចញ់ផ្ចាល់ឲ្យអៀនខ្មាស ហើយពន្យល់ឲ្យមកកាន់សេចក្តីស្ងប់វិញ ;" ។ ទ្រង់ព្រះតម្រិះគិតយ៉ាងនេះហើយ ក៏ទ្រង់យាងចុះមកដោយក្លែងភេទជាព្រាហ្មណ៍កម្លោះ ចូលទៅគាល់ព្រះចៅពារាណសីក្រាបបង្គំទូលថា "សូមព្រះតេជៈដ៏គល់លើត្បូង ទូលព្រះបង្គំបានដើរទៅឃើញក្រុងឧត្តរបញ្ចាល ឥន្ទបត្ត និងក្រុងសាកេត រាជធានីទាំង ៣ នេះ សឹងពេញដោយសេចក្តីសុខសប្បាយ ស្រូវ-អង្ករ គោ សណ្តែក ។ល។ ទាំងឡាយបរិបូណ៌ពោរពេញឥតខ្វះខាត ទាំងសម្បូណ៌ដោយមាស-ប្រាក់-កែវ-កង ពិទូរ្យស្ទូរ្យកាញ្ចន៍ជាដើម បើព្រះអង្គមានព្រះបំណងក្នុងរាជធានីទាំង ៣ នោះ ទូលព្រះបង្គំសូមព្រះរាជទានពលតែ ១០០ នាក់ពីព្រះអង្គ ទទួលយកអាសារទៅរឹបជាន់ដណ្តើមយកនគរទាំងនោះ ឲ្យបានដោយងាយលើកថ្វាយព្រះអង្គ" ។ ព្រះចៅពារាណសី ទ្រង់ជ្រាបថានឹងបាននគរទាំងនោះ ក៏ទ្រង់សោមនស្សរីករាយសប្បាយក្រៃលែង ទ្រង់រាជានុញ្ញាតឲ្យព្រាហ្មណ៍កម្លោះលើកទ័ពទៅច្បាំង ក្នុងពេលស្អែក តែទ្រង់ភ្លេច មិនបានព្រះរាជទានទីដំណេកនិងបាយទឹកដល់មាណពនោះសោះ ។

លុះព្រឹកឡើង ទ្រង់ចាត់ឲ្យរៀបចំពរួបស្រេចហើយ ទ្រង់ត្រាស់ឲ្យហៅព្រាហ្មណ៍ឈ្មោះនោះចូលគាល់ អាមាត្យទាំងឡាយក្រាបបង្គំទូលថា "បពិត្រព្រះមហាអំណាច បើព្រះអង្គមិនប្រទានទីដំណេកនឹងបាយទឹកដល់មាណពនោះ តើឲ្យទូលព្រះបង្គំទៅហៅនៅកន្លែងណា? ។ ព្រះរាជាទ្រង់បញ្ជាឲ្យពាហានតាមរកគ្រប់ច្រកល្ហកក្នុងទីក្រុង តែមិនប្រទះសោះ ។

ព្រះចៅក្រុងពារាណសី ទ្រង់ជ្រាបថារកព្រាហ្មណ៍មាណពនោះមិនឃើញ ក៏ទ្រង់ទោមនស្សទុក្ខម្នេញអន្ទះអន្ទែងក្តៅក្រហល់ក្រហាយ ព្រោះតណ្ហារួបរឹតព្រះហឫទ័យ សំឡឹងរំពៃចង់តែបានរាជធានី ៣ នោះ បណ្តាលឲ្យធ្លាក់លោហិតយ៉ាងច្រើនចេញពីព្រះឧស្ឋ ហៅថាបក្ខន្ទិកាពាធ ពួកពេទ្យមិនអាចនឹងថ្វាយការថែរក្សាបាន ព្រោះជារោគចិត្តឥតឃើញស្អាកស្នាមអ្វីបន្តិចឡើយ ។

ព្រះឥន្ទ្រាធិរាជ ទ្រង់យាងចុះមកដោយក្លែងភេទជាព្រាហ្មណ៍ ចូលទៅសូមព្យាបាល ព្រះរាជាទ្រង់ត្រាស់ថា "ចូរឲ្យរង្វាន់ហើយបង្គាប់ឲ្យទៅវិញទៅ" ព្រាហ្មណ៍ទូលតបថា "មិនត្រូវការរង្វាន់ខាន់ទេ ឬទ្រង់មិនត្រូវទេ គឺតាំងចិត្តនឹងថ្វាយការព្យាបាលរក្សាប៉ុណ្ណោះ" ។

កាលបានរាជានុញ្ញាតហើយ ឥន្ទព្រាហ្មណ៍ក៏ចូលទៅក្រាបបង្គំទូលសួរអំពីសមុដ្ឋាននៃរោគ ព្រះរាជាទ្រង់ត្រាស់ឲ្យស្តាប់តាំងពីដើមដល់ចប់ ហើយអញ្ជើញព្រាហ្មណ៍ឲ្យដាក់ឱសថ ។ ព្រាហ្មណ៍ដឹងអាការៈនៃរោគហើយ

ក៏ក្រាបបង្គំទូលថា "បពិត្រព្រះមហារាជ! បើពស់ចឹក មានពេទ្យពស់អាចដាក់ថ្នាំរម្ងាប់ពិសពស់បាន បើខ្មោចធ្វើ មានគ្រូខ្មោចបេះមន្តអាគមគាថា សូត្របណ្ដេញខ្មោចបាន រីឯជម្ងឺឈឺចិត្ត ព្រោះតែសម្ងំនឹងលោភចង់បានទ្រព្យអ្នកដទៃ ជាជម្ងឺគ្មានស្នាកស្នាម តើនរណាហ្ន៎! អាចដាក់ថ្នាំរក្សាដល់ជនលោភបាន ?" ។ កាលឥន្ទព្រាហ្មណ៍ពោលដូច្នោះហើយ ទើបសំដែងឲ្យទ្រង់ជ្រាបដោយព្រះអង្គឯងថា "បពិត្រមហារាជ! មិនគួរឡើយគ្រាន់តែពួសំដីប្រាប់ប៉ុណ្ណោះ ក៏ចុះព្រះទ័យប្រាថ្នាការគន្ធលោក លោកជាកយ៉ាងនេះទេ នេះព្រោះតែលោភហើយ បានជាក្លាយទៅជាប្រឈ្មួនដ៏សាហាវស្មើរតែអស់ព្រះជន្ម សូមព្រះអង្គទ្រង់ព្រះតម្រិះត្រិះរិះគិតមើល តើព្រះអង្គប្រាថ្នារាជសម្បត្តិនោះមកធ្វើអ្វី ? ប្រសិនជាបានរាជធានីទាំងនោះមក តើព្រះអង្គសោយព្រះក្រយាហូសពី ១ ចំអែកឬ ? មិនគួរព្រះអង្គលុះដោយអំណាចនៃសេចក្ដីលោភដូច្នោះសោះ ។ ព្រោះថា បុគ្គលណាលោភ សំឡឹងគយគន់ប្រុងយកទ្រព្យគេ បុគ្គលនោះរមែងទទួលទោសទុក្ខក្នុងលោកនេះ ដូចទ្រង់ជួបប្រទះនេះឯង និងបរលោក សោយទុក្ខវេទនាក្នុងអបាយមាននរកជាដើម ។

ព្រះចៅពារាណសីទ្រង់សវនាការពាក្យពន្យល់ដោយនិយ័យព្រមទាំងឧបមានោះហើយក៏កើតព្រះប្រាជ្ញាញាណឡើងភ្លាម ប្រាជ្ញា

ញាណនោះបានដូចជាទុសថទំពាំកបាក់ទុក្ខសោក បាត់ប្រឈួនក្នុងពេល នោះឯង ។

អភិជ្ឈា ជាគំនិតគិតអាក្រក់ លោកឱ្យឈ្មោះថា ចាប ជាអំពើ មិនត្រូវគិតឡើយ ។

៩– ព្យាបាទ: ចិត្តចង់គំនុំគុំគួនគិតចង់ឱ្យអ្នកដទៃដល់នូវសេចក្ដី វិនាស ។

ព្យាបាទនេះ បើទុកជាសេចក្ដីក្រោធដែលមានសត្វដទៃជាទីតាំង ហើយ ប៉ុន្តែមិនទាន់គិតថា "ឱ្យសត្វនោះស្លាប់ទៅចុះ" ដូច្នេះនៅឡើយ ទេ នឹងចាត់ថា ព្យាបាទក៏មិនទាន់បានដែរ ។ ឯសេចក្ដីក្រោធនេះជា អកុសលចិត្តពិតហើយ ប៉ុន្តែមិនមែនជាអកុសលកម្មបថទេ គឺមិនមែនជា ព្យាបាទ គ្រាន់តែក្រោធខឹងប៉ុណ្ណោះ លុះតែសេចក្ដីក្រោធកើតឡើងហើយ ថែមទាំងមានគំនិតគិតថា "ឱ្យសត្វនោះស្លាប់ទៅចុះ" ដូច្នេះទើបចាត់ជា ព្យាបាទ ។

ព្យាបាទនេះ បើមានក្នុងសន្ដានចិត្តបុរសស្ត្រីណាហើយ រមែងធ្វើ សន្ដានចិត្តនៃបុរសស្ត្រីនោះឱ្យកំរើកញាប់ញ័រឡើង នឹងប្រឹងទប់ទល់ឱ្យ នៅពុំបាន មានអាការៈពុះពោរឡើងជាមិច្ឆ ឃាត់បង់នូវកុសលធម៌ទាំងពួង មិនឱ្យកើតឡើងបាន ហើយអាចនាំសត្វឱ្យទៅកើតក្នុងអបាយផង ។

ទោសនៃព្យាបាទនេះ ឧទាហរណ៍ដូចជា ៖

# រឿងអជគរប្រេត (១)

ក្នុងសម័យថ្ងៃមួយ ព្រះមហាមោគ្គលានត្ថេរ ចុះពីភ្នំគិជ្ឈកូដជាមួយនឹងព្រះលក្ខណត្ថេរ លោកបានឃើញប្រេត ១ ឈ្មោះ អជគរៈ មានកំពស់ ២៥ យោជន៍ មានភ្លើងឆេះស្រោចពីក្បាលកលទៅសព្វខ្លួន ព្រះមោគ្គលានបានឃើញប្រេតនោះហើយក៏ញញឹម ព្រះលក្ខណត្ថេរក៏សួររកហេតុដែលញញឹមភ្លាម ព្រះមោគ្គលានប្រាប់ថា ពេលនេះជាពេលមិនគួរទេ ចាំទៅដល់សំណាក់ព្រះសាស្ដាចាំខ្ញុំប្រាប់ ។ លុះទៅដល់សំណាក់ព្រះសាស្ដាហើយ ព្រះលក្ខណត្ថេរក៏ផ្ដើមសួរទៀត ព្រះមោគ្គលាន ក៏ប្រាប់ថា "ខ្ញុំឃើញប្រេត ១ មានអត្តភាពយ៉ាងនេះ ៗ ខ្ញុំគិតថា អត្តភាពដូច្នេះខ្ញុំមិនដែលឃើញសោះ បានជាខ្ញុំញញឹម" ។

ព្រះសាស្ដាចារ្យ ទ្រង់មានពុទ្ធដីកាថា "ប្រេតនោះតថាគតបានឃើញតាំងពីតថាគតនៅក្នុងពោធិមណ្ឌលម្ល៉េះ? ប៉ុន្តែគ្មានសាក្សីបានជាមិននិយាយ ឥឡូវនេះបានមោគ្គលានជាសាក្សីហើយតថាគតត្រូវតែនិយាយ ។ ភិក្ខុទាំងឡាយក៏ក្រាបបង្គំទូលសួរអំពីបុព្វកម្មប្រេតនោះ ។ ព្រះអង្គទ្រង់សំដែងថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានៃព្រះពុទ្ធព្រះនាម កស្សប មានសេដ្ឋីម្នាក់ឈ្មោះ សុមង្គល បានផែមាសធ្វើជាឥដ្ឋក្រាលលើផែនដីពេញ ចម្ងាយ ២០ ឧសភៈ ហើយចាត់ឲ្យ

---

១- បាកធម្មបទដ្ឋកថា ទណ្ឌវគ្គ ។

សានវត្តកំណត់ត្រឹមស្មើនឹងទ្រព្យដែលជាតម្លៃមាសប៉ុណ្ណោះទៀត ។

ថ្ងៃ ១ សេដ្ឋីទៅវត្តពីព្រឹកបានឃើញចោរម្នាក់ មានជើងប្រឡាក់ភក់ ដេកវង្វូរក្បាលនៅលើសាលា ក៏លាន់មាត់ថា "មនុស្សមានជើងប្រឡាក់ភក់នេះ ប្រហែលជាមនុស្សដើររកស៊ីយប់" ។ ចោរឮហើយក៏ចងគំនុំថា "គង់តែនឹងជួបគ្នាទេសេដ្ឋី" ហើយក៏តាំងព្យាយាមបំផ្លាញសម្បត្តិសេដ្ឋី គឺដុតស្រែកន្លែង ៧ ដង កាត់ជើងគោទាំងឡាយ ៧ ដង ដុតផ្ទះ ៧ ដង សេដ្ឋីនៅតែមិនខឹង ចោរទៅអែបអបអ្នកបំរើសេដ្ឋីម្នាក់យកជាមិត្រយ៉ាងជិតស្និទ្ធ ហើយសួរថា "របស់អ្វីជាទីពេញចិត្តសេដ្ឋី ?" អ្នកបំរើសេដ្ឋីប្រាប់ថា "មានគន្ធកុដិទើបជាទីស្រឡាញ់របស់លោក ។ កាលព្រះសាស្តាចារ្យ និងភិក្ខុ-សាមណេរ និមន្តទៅបិណ្ឌបាតបាត់ ចោរនោះចូលទៅដុតគន្ធកុដិនេះខ្ទេច ។ សេដ្ឋីបានឮថានេះគន្ធកុដិ ក៏មកមើលឃើញនេះដូច្នោះ ក៏មិនទោមនស្សសោះ បែរជាទះដៃសើចទៅវិញ ដោយត្រេកអរនឹងបានកសាងម្តងទៀត ទើបចំណាយទ្រព្យធ្វើគន្ធកុដិជាថ្មីទៀត លុះធ្វើរួចហើយ បានប្រគេនបង្អាន់ដោយសេចក្តីរីករាយដល់ព្រះសាស្តា-ចារ្យ មានភិក្ខុ២ហ្មឺនជាបរិវារ ។ ចោរឃើញសេដ្ឋីធ្វើដូច្នោះហើយក៏គិតថា "បើអញមិនសម្លាប់សេដ្ឋីនេះ មុខជាមិនអាចនឹងបង្អន់គាត់បានឡើយ" ហើយក៏សៀតកាំបិតបង្កប់ដើរទៅដើរមកក្នុងវត្តស្កាត់ចាំសម្លាប់សេដ្ឋី អស់គំរប់ ៧ ថ្ងៃ ប៉ុន្តែរកឱកាសមិនបានសោះ ។ សេដ្ឋីធ្វើ

បុណ្យគ្រប់ ៧ ថ្ងៃហើយ ថ្វាយបង្គំព្រះសាស្តាក្រាបទូលថា « បពិត្រព្រះអង្គដ៏ចំរើន មានបុរសម្នាក់ដុតស្រូវក្នុងស្រែ ៧ ដង កាត់ជើងគោ ៧ ដង ដុតផ្ទះ ៧ ដង ឥឡូវនេះគន្ធកុដិប្រហែលជាបុរសនោះដុតដែរ ខ្ញុំព្រះករុ-ណាសូមចែកចំណែកបុណ្យជាបឋមដល់បុរសនោះ ។ ចោរបានឮពាក្យនោះហើយក៏គិតថា « អើហ្ន៎ ! អំពើដែលអញធ្វើនេះជាទម្ងន់ណាស់ សេដ្ឋីមិនខឹងនឹងអញបន្តិចបន្តួចសោះ បើអញមិនសូមទោសនឹងគាត់ទេ មុខជាការពិន័យរបស់ទេវតានឹងធ្លាក់លើអំបែងក្បាលអញមិនខានឡើយ » គិតហើយក៏ទៅក្រាបទៀបជើងសេដ្ឋីសូមខមាទោស ជំរាបអំពីកំហុសដែលខ្លួនបានធ្វើទាំងអស់ សេដ្ឋីក៏និយាយថា « ពាក្យដែលខ្ញុំបានថាហួសទៅហើយនោះ ត្រូវអ្នកឯងអត់ទោសឲ្យខ្ញុំផង ខ្ញុំអត់ទោសឲ្យអ្នកឯងហើយ អ្នកឯងទៅចុះ ។ ចោរមិនព្រមទៅ សុខចិត្តនៅបំរើសេដ្ឋី និយាយអង្វរសេ-ដ្ឋីថា « បើលោកអត់ទោសឲ្យខ្ញុំបាទហើយ សូមលោកមេត្តាឲ្យខ្ញុំបាទព្រមទាំងកូនប្រពន្ធទាំងអស់នៅបំរើក្នុងផ្ទះលោក » សេដ្ឋីប្រកែកថា « ណើយកុំ ! ប្រហែលពាក្យខ្ញុំពោលបន្តិចបន្តួចប៉ុណ្ណោះ អ្នកឯងបំផ្លាញខ្ញុំម្ល៉ឹងទៅហើយ ចំណង់បើអ្នកឯងនៅផ្ទះជាមួយខ្ញុំ ធ្វើម្តេចខ្ញុំហ៊ាននិយាយផង » ។

ចោរនោះលុះស្លាប់ទៅ ។ កើតក្នុងអវិចិនរកអស់កាលជាអង្វែងដោយសេសសល់ផលកម្ម បានមកកើតជាអជគរប្រេតនេះ ដែលមានភ្លើងឆេះនៅទៀតក្នុងគិជ្ឈកូដភ្នំឯង ។

ព្យាបាទ គឺបំផ្លាញអ្នកដទៃឲ្យវិនាស លោកឲ្យឈ្មោះថា បាប ជាអំពើមិនត្រូវធ្វើឡើយ ។

១០ មិច្ឆាទិដ្ឋិ គំនិតយល់ខុសចាកគន្លងធម៌ពិតមែន

ពាក្យថា ទិដ្ឋិនេះ ប្រែថា "សេចក្ដីយល់" បើយល់ត្រូវលោកហៅថា សម្មាទិដ្ឋិ បើយល់ខុសលោកហៅថា មិច្ឆាទិដ្ឋិ ។

ក្នុងដីកាសង្គីតិសូត្រថា កិរិយាយល់ខុសហើយប្រកាន់យកថាពិត នោះគឺតែដែលមិនទៀង យល់ឃើញថាទៀង អំពើនាំមកនូវសេចក្ដីទុក្ខ យល់ឃើញថា នាំមកនូវសេចក្ដីសុខ ឲ្យបានមានផល យល់ឃើញថា គ្មានផលវិញ លទ្ធិដូច្នេះលោកហៅថា មិច្ឆាទិដ្ឋិ ។

## មិច្ឆាទិដ្ឋិមាន ២ យ៉ាងគឺ:

១- សស្សតទិដ្ឋិ យល់ថាទៀងទាត់ឋិតថេរ គឺជាតិនេះធ្លាប់កើតជាសត្វ ទៅលោកខាងមុខក៏កើតជាសត្វទៀតមិនប្រែប្រួល ។

២- ឧច្ឆេទទិដ្ឋិ យល់ថាគ្មាន ថាសូន្យ គឺស្លាប់ហើយមិនកើតទៀត ។

បើបុគ្គលណាជាមិច្ឆាទិដ្ឋិហើយ បុគ្គលនោះទោះនិយាយក្ដី ធ្វើក្ដី គិតក្ដី ក៏សុទ្ធតែខុសទាំងអស់ ។ ព្រោះមិច្ឆាទិដ្ឋិនេះ ជាឫសគល់នៃអកុសលគ្រប់ចំពូក ។ ហេតុនេះបានជាព្រះបរមសាស្ដាព្រះទ្រង់ត្រាស់ថា ណាហំ ភិក្ខវេ អញ្ញំ ឯកធម្មំ សមនុបស្សាមិ ម្នាលភិក្ខុទាំងឡាយ!

គឺថា គតមិនឃើញមានធម៌ដទៃណាមួយ ជាហេតុ ជាឫសគល់នាំអកុសលដែលមិនទាន់កើតឡើង ឲ្យកើតឡើង នាំអកុសលដែលកើតឡើងហើយ ឲ្យរឹងរឹតតែកើតចំរើនឡើងដូចមិច្ឆាទិដ្ឋិនេះឡើយ ។

មិច្ឆាទិដ្ឋិនេះ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ទុកក្នុងគម្ពីរអង្គុត្តរនិកាយថា គឺថាគតស្រាវជ្រាវរកអំពើដែលមានទោសច្រើនដូចមិច្ឆាទិដ្ឋិមិនឃើញមាន មានតែមិច្ឆាទិដ្ឋិនេះឯងហើយ ដែលមានទោសច្រើនជាងគេបំផុត ។ អនន្តរិយកម្មទាំង ៥ ក៏មានទោសច្រើនដែរ តែមិច្ឆាទិដ្ឋិមានទោសច្រើនជាងនោះទៅទៀត ព្រោះអនន្តរិយកម្មមានកំណត់គឺថា "ញុំាងអ្នកដែលធ្វើឲ្យកើតក្នុងនរក" ប៉ុណ្ណោះ ។ ឯទោសមិច្ឆាទិដ្ឋិ រកកំណត់មិនបានគឺថា "ជាត់ជាឫសគល់នៃវដ្តៈទីងចេញចាកភពមិនងាយរួចឡើយ" ។

កន្លែងគ្រាដែលកប្បវិនាស មហាជនតែងទៅកើតក្នុងឋានព្រហ្មលោកទាំងអស់គ្នា ប៉ុន្តែជនមិច្ឆាទិដ្ឋិមិនបានកើតក្នុងទីនោះនឹងគេទេ បែរជាទៅធ្លាក់ក្នុងលោកន្តរនរក ដែលភ្លើងប្រល័យកប្បឆេះមិនដល់ឯណោះទៅវិញដោយកម្លាំងកម្មរបស់ខ្លួន ។

(នៅមានត)

# គម្ពីរព្រះយមកៈ

*លោក ប៊ុ - ប៊ុ ប្រែរៀបរៀង*

( តមក )

---

## ឥន្ទ្រិយយមក

ពាវីសតិន្ទ្រិយានិ ឧទ្ទេសន្តោ យមកំ យមកំ ឧទ្ទេសិត្វា ចក្ខុ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយំ ចក្ខូតិ អាទិកំ អាបុច្ឆនំ កត្វា អាមន្តាតិ វិស្សជ្ជេត្វា ឥន្ទ្រិយយមកំ ឧទ្ទេសិ ។

*លំដាប់នេះ សូមវិសជ្ជនាក្នុងឥន្ទ្រិយយមកតទៅ ដំណើរសេចក្ដីថា លោកណាថោ សម្ដេចព្រះបរមលោកនាថ កាលទ្រង់ត្រាស់ទេសនាធម្មយមកចប់ហើយ ក្នុងលំដាប់នោះទើបទ្រង់ត្រាស់ទេសនានូវឥន្ទ្រិយយមក សំដែងដោយឥន្ទ្រីយ៍ ២២ ប្រការតទៅទៀត ។*

*ឯឥន្ទ្រីយ៍ ២២ ប្រការនោះ គឺចក្ខុន្ទ្រីយ៍ ១ សោតិន្ទ្រីយ៍ ១ ឃានិន្ទ្រីយ៍ ១ ជិវ្ហិន្ទ្រីយ៍ ១ កាយិន្ទ្រីយ៍ ១ មនិន្ទ្រីយ៍ ១ ឥត្ថិន្ទ្រីយ៍ ១ បុរិសិន្ទ្រីយ៍ ១ ជីវិតិន្ទ្រីយ៍ ១ សុខិន្ទ្រីយ៍ ១ ទុក្ខិន្ទ្រីយ៍ ១ សោមនស្សិន្ទ្រីយ៍ ១ ទោមនស្សិន្ទ្រីយ៍ ១ ឧបេក្ខិន្ទ្រីយ៍ ១ សទ្ធិន្ទ្រីយ៍ ១ វិរិយិន្ទ្រីយ៍ ១ សតិ-*

ន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ អនញ្ញាតញ្ញស្សាមិតិន្ទ្រិយ ១ អញ្ញិន្ទ្រិយ ១ អញ្ញាតាវិន្ទ្រិយ ១ គ្រប់ជាឥន្ទ្រិយ ២២ ប្រការ ។

កាលព្រះអង្គត្រាស់ទេសនាឥន្ទ្រិយ ២២ ប្រការនោះ យមកំ យមកំ ឧស្សេក្តា ទ្រង់ត្រាស់ទេសនាជាគូ ៗ គ្នា គឺត្រាស់បុច្ឆាក៏ជាគូ វិសជ្ជនាក៏ជាគូ ត្រាស់បុច្ឆាជាអាទិ៍ថា ចក្ខុ ចក្ខុន្ទ្រិយំ ចក្ខុនោះឬឈ្មោះចក្ខុន្ទ្រិយ? ចក្ខុន្ទ្រិយនោះឬឈ្មោះថា ចក្ខុ? ជាលំដាប់ដរាបទៅដល់ អញ្ញាតាវិន្ទ្រិយ ។

ត្រាស់បុច្ឆាជាគូ ៗ ដូច្នេះហើយ ទើបត្រាស់វិសជ្ជនាជាគូ ៗ វៀងគ្នាទៅថា អាមន្តា អើ! ចក្ខុនោះឯងឈ្មោះថាចក្ខុន្ទ្រិយ ចក្ខុន្ទ្រិយនោះឯងឈ្មោះថាចក្ខុ ជាលំដាប់ដរាបទៅដល់ អញ្ញាតាវិន្ទ្រិយ ។

មានពាក្យអធិប្បាយថា សភាវៈណាធ្វើឲ្យជាធំក្នុងការឃើញរូប សភាវៈនោះហៅថា ចក្ខុន្ទ្រិយ ក្នុងការស្តាប់នូវសំឡេងហៅថា សោ-តិន្ទ្រិយ ក្នុងការហិតក្លិនហៅថា ឃានិន្ទ្រិយ ក្នុងការលិទ្ធភ្លក្សរសហៅថា ជិវ្ហិន្ទ្រិយ ក្នុងការពាល់ត្រូវហៅថា កាយិន្ទ្រិយ ក្នុងការដឹងនូវអា-រម្មណ៍ផ្សេង ៗ ហៅថា មនិន្ទ្រិយ ។

សភាវៈណាធ្វើរូបកាយអាកប្បកិរិយា នៃ ឥត្ថីនិមិត្ត ឲ្យកើតប្រាកដ សភាវៈនោះឈ្មោះថា ឥត្ថិន្ទ្រិយ ។

សភាវៈណាធ្វើរូបកាយអាកប្បកិរិយា នៃ បុរិសនិមិត្ត ឲ្យកើត

ប្រាកដ សភាវៈនោះឈ្មោះថា បុរិសិន្ទ្រិយ ។

ឥត្ថិន្ទ្រិយនោះ បានដល់ភេទនៃស្ត្រី ។ បុរិសិន្ទ្រិយនោះ បានដល់ភេទនៃបុរស ។ ភេទស្ត្រីនិងភេទបុរសទាំងពីរនេះ កើតមានដល់សត្វទាំងឡាយក្នុងបឋមកប្ប គឺតាំងពីដាប់កើតកប្បឡើងជាដំបូងហើយមានតគ្គាជាលំដាប់ដកបមកដល់សព្វថ្ងៃនេះ ។ លុះចំណេរយូរមក ភេទបុរសនិងភេទស្ត្រីនេះផ្លាស់ប្តូរគ្នាទៅវិញទៅមក សមតាមពាក្យព្រះអដ្ឋកថាតាវ្យសំដែងក្នុងវិន័យបិដកថា សម្តេចព្រះមានព្រះភាគទ្រង់បញ្ញត្តិឲ្យនាងភិក្ខុនីដែលមានភេទស្ត្រីត្រឡប់ជាបុរសនោះ ឲ្យនៅជាមួយពួកភិក្ខុបាន ព្រោះភេទនៃនាងភិក្ខុនីនោះបាត់ទៅ ។

ឥត្ថីលិង្គំ ហីនំ ភេទស្ត្រីជាភេទថោកទាប ព្រោះហេតុថា ស្ត្រីបើប្រាថ្នាជាពុទ្ធភូមិ ត្រូវប្រាថ្នាឲ្យកើតជាបុរសមុនសិន ទើបសេចក្តីប្រាថ្នានោះបានសម្រេច បើមិនកើតជាបុរសទេ ប្រាថ្នាជាពុទ្ធភូមិមិនបានសម្រេចឡើយ ។

ពលវ អកុសលេន បំណែកភេទប្រុសនិងត្រឡប់ទៅជាភេទស្ត្រីវិញនោះដោយកម្លាំងអកុសលកម្ម ។ ឯភេទស្ត្រីនិងត្រឡប់ទៅជាភេទបុរសវិញនោះដោយកម្លាំងនៃកុសលកម្ម ។ ដូចព្រះ សោរេយ្យត្ថេរ កាលដើមឡើយលោកជាបុរសមានប្រពន្ធហើយមានកូនពីរនាក់ ។ ថ្ងៃមួយលោកបានទៅជួបនិងព្រះ កច្ចាយនត្ថេរ ក៏កើតចិត្តប្រតិពទ្ធស្នេ-

ហាគិតថា ធ្វើម្ដេចនឹងបានព្រះថេរអង្គនេះមកជាប្រពន្ធអញ ឬមួយធ្វើម្ដេចនឹងឲ្យបានប្រពន្ធអញមានរូបកាយល្អល្អះដូចជាលោកម្ចាស់នេះ ក្នុងលំដាប់នៃចិត្តគិតដូច្នេះ ភេទស្ត្រីក៏កើតមានប្រាកដឡើង គឺថាកាយខ្លួនទៅជារូបរាងកាយស្ត្រីភាព លែងជារូបរាងបុរស ។

សោរេយ្យសេដ្ឋីបុត្រ ដឹងថាខ្លួនក្លាយទៅជាស្ត្រីហើយ ក៏នឹកអៀនខ្មាសគេណាស់ មិនហ៊ានវិលទៅនៅផ្ទះជាមួយប្រពន្ធកូនវិញ ទើបរត់ចេញពីស្រុកទៅនៅក្នុងនគរតក្កសិលា មានប្ដីហើយបានកូនពីរនាក់ដែលកើតចេញពីទ្វាររបស់ខ្លួន ។

ខាងក្រោយមក នាងក្លាយភេទនេះ បានទៅសូមខមាទោសនឹងព្រះកច្ចាយនត្ថេរ ដោយដឹងទោសរបស់ខ្លួនថា ស្រឡាញ់លោកពីមុននោះភេទស្ត្រីក៏អន្តរធានបាត់ទៅ កើតភេទបុរសដូចដើមឡើងវិញ មានចិត្តនឿយណាយក្នុងឃរាវាស ទើបចូលបួសក្នុងព្រះបវរពុទ្ធសាសនាបានសម្រេចព្រះអរហត្ត ។ សូម្បីលោកជាបច្ឆិមភវិកសត្វ គឺបានអរហត្តក្នុងជាតិនោះ ក៏នៅតែក្លាយភេទបុរសទៅជាភេទស្ត្រីក្នុងបច្ចុប្បន្នទាន់ភ្នែកដោយអំណាចកម្លាំងអកុសលចិត្ត ដែលប្រមាទព្រះកច្ចាយនត្ថេរនោះ ។ ប៉ុន្តែទោសនេះស្រាលអាចសូមខមាទោសរួច ។

មានពាក្យព្រះអដ្ឋកថាចារ្យពោលក្នុងអង្គុត្តរសំយុត្តថា ការដែលស្ត្រីទៅកើតជាបុរស ឬបុរសទៅកើតជាស្ត្រីក្ដី ស្ត្រីទៅកើតជាបុរសក្ដី

ឧកម្សោំ  ហេតុទាំងពីរប្រការនេះ  នឹងរាប់នឹងប្រមាណមិនបានទេ ជួនកាលកើតជាបុរសក្នុងចក្រពាឡនេះ  ទៅកើតជាស្រីក្នុងចក្រពាឡដទៃក៏មាន  ជួនកាលកើតជាស្រីក្នុងចក្រពាឡដទៃ  មកកើតជាបុរសក្នុងចក្រពាឡនេះក៏មាន  ចេះតែប្រែប្រួលផ្លាស់ប្តូរភេទទៅមកយ៉ាងនេះ  នឹងរាប់កំណត់ជាតិពុំបានឡើយ ។

ឯជីវិតិន្ទ្រិយ៍នោះ បាននឹងការធ្វើឲ្យជាធំក្នុងកិច្ចចិញ្ចឹមរក្សាទុកឲ្យសត្វរស់នៅបាន ។

សុខិន្ទ្រិយ៍នោះ  បាននឹងសភាវ ជាធំក្នុងកិច្ចនាំឲ្យបានសុខ ។

ទុក្ខិន្ទ្រិយ៍នោះ  បាននឹងសភាវៈជាធំក្នុងកិច្ចនាំឲ្យបានទុក្ខ ។

សោមនស្សិន្ទ្រិយ៍នោះបាននឹងសភាវៈជាធំក្នុងការធ្វើនូវសោមនស្ស គឺធ្វើឲ្យសត្វទាំងឡាយមានចិត្តល្អ ។

ទោមនស្សិន្ទ្រិយ៍នោះ  បាននឹងសភាវៈជាធំក្នុងការធ្វើនូវទោមនស្ស គឺធ្វើឲ្យសព្វសត្វមានចិត្តអាក់អន់ ឬតូចចិត្ត ។

ឧបេក្ខិន្ទ្រិយ៍នោះ  បាននឹងសភាវៈជាធំក្នុងលក្ខណៈឧបេក្ខា ។

សទ្ធិន្ទ្រិយ៍នោះ  បាននឹងសភាវៈជាធំក្នុងការនាំឲ្យកើតសទ្ធា  គឺជឿក្នុងព្រះពុទ្ធគុណ  ព្រះធម្មគុណ  ព្រះសង្ឃគុណ  នឹងជឿក្នុងផលសីល ផលទានជាការកុសលទាំងពួង ។

វីរិយិន្ទ្រិយ៍នោះ  បាននឹងសភាវៈជាធំក្នុងលក្ខណៈនៃការលើកឡើង

នូវចិត្តកាន់អារម្មណ៍ មិនឲ្យរញ្ញេកក្នុងការកុសល ។

សតិន្ទ្រិយ៍នោះ បាននឹងសភាវៈជាធំក្នុងលក្ខណៈនៃការនឹករឭក មានសតិបដ្ឋាន ៤ នឹងអនុស្សតិ ១០ ជាដើម ។

សមាធិន្ទ្រិយ៍នោះ បាននឹងសភាវៈជាធំក្នុងសមាធិ គឺការតាំងចិត្តមាំ មិនបានញាប់ញ័រដោយកិលេស នឹងមិនបានញុំាងចិត្តឲ្យអណ្តែតអណ្តូង។

បញ្ញិន្ទ្រិយ៍នោះ បាននឹងសភាវៈជាធំក្នុងលក្ខណៈនៃការពិចារណាឃើញដោយបញ្ញា ដោយកំណត់មានក្នុងទីបំផុត ការដែលឃើញដោយកម្មស្សកតាញាណ ។

អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ៍នោះ បាននឹងសភាវៈជាធំក្នុងលក្ខណៈនៃការដឹងដោយអភិញ្ញាប្រាំមួយប្រការ ។

អញ្ញិន្ទ្រីនោះ បាននឹងសភាវៈជាធំក្នុងការដឹងនូវត្រៃវិជ្ជា ។

អញ្ញាតាវិន្ទ្រិយ៍នោះ បាននឹងសភាវៈជាធំក្នុងការត្រាស់ដឹងនូវបញ្ញាក្នុងអរិយមគ្គ អរិយផល ។

ក្នុងសុត្តន្តកាជនីយ សម្តេចព្រះបរមទេសពលមិនបានត្រាស់ទេសនានូវឥន្ទ្រិយ៍ទាំង ២២ ប្រការនោះទេ ក្នុងសូត្រខ្លះ ទ្រង់ត្រាស់សំដែងតែឥន្ទ្រិយ៍ពីរប្រការ បីប្រការ ប្រាំប្រការ ។ ឯឥន្ទ្រិយ៍បីប្រការខាងចុងបំផុត គឺអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ៍ ១ អញ្ញិន្ទ្រិយ៍ ១ អញ្ញាតាវិន្ទ្រិយ៍ ១ ទ្រង់សំដែងចំពោះតែក្នុងបរមត្ថ ។ ឥន្ទ្រិយ៍ ៦ ប្រការមានចក្ខុន្ទ្រិយ៍ជាដើម

មានមនិន្ទ្រីយ៍ជាបរិយោសាន ទ្រង់សំដែងតាំងក្នុងព្រះសូត្រ តាំងក្នុងព្រះបរមត្ថ តាំងក្នុងព្រះវិន័យ ។ ឥន្ទ្រីយ៍ ៥ ប្រការ គឺសទ្ធិន្ទ្រីយ៍ ១ វិរិយិន្ទ្រីយ៍ ១ សតិន្ទ្រីយ៍ ១ សមាធិន្ទ្រីយ៍ ១ បញ្ញិន្ទ្រីយ៍ ១ ទ្រង់សំដែងកប់បញ្ចូលក្នុងពោធិបក្ខិយធម៌ គឺធម៌ជាចំណែកនៃពោធិ ជាហេតុនឹងឲ្យត្រាស់ដឹងនូវព្រះអរិយមគ្គ អរិយផល ។

សម្តេចព្រះបរមទសពលទ្រង់សំដែងនូវឥន្ទ្រីយ៍ ២២ ប្រការដោយទ្រង់បុច្ឆានិងវិសជ្ជនាជាគូ ៗ គ្នា ទើបឈ្មោះថាឥន្ទ្រីយយមក ។

កាលព្រះពុទ្ធអង្គទ្រង់ត្រាស់ទេសនានូវគម្ពីរយមក នេះ ចាត់ជាព្រះធម្មក្ខន្ធប្រាំពាន់មួយរយព្រះធម្មក្ខន្ធ ទ្រង់ត្រាស់ទេសនា ១៨ ថ្ងៃទើបចប់ ទេព្តាបានសម្រេចព្រះអរិយមគ្គ អរិយផល មានប្រមាណ ៧ កោដិក្នុងយមកបករណាវសានកាល គឺកាលចប់គម្ពីរយមក ។

គម្ពីរយមកៈ ចប់ប៉ុណ្ណោះ ។

---

## គម្ពីរព្រះមហាបដ្ឋាន

យមកំ នាម បករណំ ទេសេត្វា សម្មាសម្ពុទ្ធោ មហាបដ្ឋានំ ទេសេន្តោ អនន្តនយមណ្ឌិតំ ចតុវីសតិបច្ចយំ ហេតុបច្ចយោតិ អាទិំ អារភន្តោ កថយីតិ ។

លំដាប់នេះ សូមវិសជ្ជនាក្នុងគម្ពីរព្រះមហាបដ្ឋានតទៅ ដំណើរសេចក្តីថា សម្មាសម្ពុទ្ធោ សម្តេចព្រះមានព្រះភាគព្រះអង្គត្រាស់ដឹង

នូវចតុរារិយសច្ច នឹងញេយ្យធម៌ទាំងពួងដោយព្រះអង្គឯង ពុំមានបុគ្គលណាជាគ្រូអាចារ្យប្រៀនប្រដៅ ដោយអាការដ៏ល្អគឺមិនបានវិបរិតធស្សេតា ព្រះអង្គត្រាស់ទេសនានូវគម្ពីរព្រះយមកចប់ហើយ ក្នុងលំ-ដាប់នោះ ទើបត្រាស់ទេសនានូវគម្ពីរព្រះមហាបដ្ឋានតទៅ ដ៏ប្រដាប់ដោយន័យពុំមានទីបំផុត មានបច្ច័យ ២៤ ប្រការ មានន័យជ្រាលជ្រៅឆ្ងាយទូ-លាយជាងគម្ពីរទាំង ៦ ខាងដើម ។

ឯគម្ពីរព្រះមហាបដ្ឋានអនន្តន័យជាគំរប់ ៧ នេះ មានអត្ថដ៏ល្អិតសុខុមគម្ភីរភាពជ្រាលជ្រៅជាងព្រះសទ្ធម្មទាំងពួង ដែលមានក្នុងព្រះត្រៃបិ-ដក សិនេរុ វិយ បីដូចសិនេរុបពិត ពុំនោះសោតដូចជាមហាសមុទ្រទាំងបួនជ្រៅជាងមហានទី នឹងជាទីអាស្រ័យនៅនៃសត្វារជាតិតូចធំ ។ ព្រះមហាបដ្ឋាននោះជាវិស័យនៃព្រះសព្វញ្ញូសម្ពុទ្ធគ្រប់ព្រះអង្គ មិនមែនជាវិស័យនៃព្រះសាវកទាំងពួងទេ ។

(នៅមានត)

## មនុស្សភាហាណី

## សម្ដេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

(តមក)

ព្រះសារីបុត្តថេរ លោកបានទទួលបាយាស ហើយក៏ញុំាងមង្គលសួស្តីឲ្យចំរើនដល់បុរសនោះ ហើយនិមន្តត្រឡប់ទៅកាន់ព្រះវិហារវិញ ៗ ក្រោយពីនោះមក ពោរយាជកាមាត្យ មានសេចក្តីរលឹករឿយ ៗ នូវទានដែលបានបូជាដល់ព្រះថេរៈ ហើយធ្វើមរណកាលក្សិណក្ស័យជីវិតទៅក្នុងខណៈនោះ ក៏បានឡើងទៅកើតក្នុងស្ថានសួគ៌ទេវលោកសោយទិព្វសម្បត្តិប្រកបដោយស្រីទេពអប្សរមានប្រមាណច្រើន ចោមរោមជាបរិវារបំរើជាប្រក្រតី ដោយផលានិសង្សនោះឯង ។ ឧហ្ន៎ មុខគួរអស្ចារ្យពេកណាស់កំឡាំងអានុភាពនៃបុគ្គលដែលមានរាគាទិកិលេសប្រាសចេញហើយ អាចញុំាងសត្វលាមកអ្នកមានបាបស្លាប់ហើយគួរនឹងទៅកើតក្នុងនរក នេះត្រឡប់ឲ្យទៅកើតក្នុងស្ថានសួគ៌វិញបាន ដោយអំណាចសេចក្តីព្យាយាមរបស់ព្រះមហាថេរៈនោះឯង ។ ហេតុដូច្នេះ បានជាមានសុភាសិតជាបទគាថា ថា:

ឋានំ តាណំ មនុស្សានំ ឋានំ ទុគ្គតិភាវណំ
ឋានំ សត្តស្ស សោចាណំ ឋានំសង្គារិបរំ ។

អធិប្បាយថា ឋានជាទីពឹងផ្អែកនៃមនុស្សទាំងឡាយ ឋានអាចឃាត់

ឃាំងកាំងកមិនព្រមឲ្យទៅកាន់ទុគ្គតិបាន ទានប្រាកដស្មើដូចជណ្តើរកែវឡើងទៅកាន់ស្ថានសួគ៌ ទានដ៏ឧត្តម អាចធ្វើម្ចាស់ទានឲ្យលត់ទុក្ខទាំងពួងបានដោយពិត ។

ឥច្ឆិតិច្ឆិតទានេន ទានំ ចិន្តាមណី វិយ

កប្បរុក្ខោវ សត្តានំ ទានំ ភទ្ទឃដោវិយ

ទានបីដូចជាកែវចិន្តាមណី អាចឲ្យសម្រេចសេចក្តីប្រាថ្នាទាំងពួងតាមចិត្តនឹក ពុំនោះសោតបីដូចជាដើមកប្បព្រឹក្ស អាចឲ្យសម្រេចសម្បត្តិទាំងពួងដល់សត្វនិករទូទៅ ទានបីដូចជាឆ្នាំងដ៏ពេញដោយបាយជាទិព្វ អាចផ្តល់ឲ្យដល់សត្វទាំងឡាយបានដោយពិត ។

សីលវន្តស្ស ទានេន ចក្កវត្តិសិរិម្បិច

លភន្តិ សក្កសម្បត្តិ តថា លោកុត្តរសុខំ ។

មួយវិញទៀត ជនទាំងឡាយ តែងបានសោយសម្បត្តិជាស្តេចចក្រ-ពត្តិដ៏មានសិរីសួស្តី បានសោយទិព្វសម្បត្តិជាព្រះឥន្ទ្រាធិរាជក្តី ក៏បានដោយទានដែលខ្លួនបានឲ្យដល់បុគ្គលអ្នកមានសីលដោយពិត ឬថាជនទាំងឡាយតែងបាននូវលោកុត្តរសុខ គឺសេចក្តីសុខជាលោកុត្តរសម្បត្តិក្តី ក៏បានដោយផលទានជាដើមនោះដែរ ។

ចាបកម្មស្ស ធីរត្តា ម៉ែតាយំ នរកាយេ

សារីបុត្តស្ស ថេរស្ស បិណ្ឌបាតស្ស ភិខាសា

អថាយំ បរិវជ្ជេត្វា ទេហំ ទុក្ខសមាកុលំ
ទេវសំឃបរិពុឡ្ហោ គតោ ទេវបុរំ វរំ ។

ពោរឃាដកាមាត្យនេះ ស្ថិតនៅជានិច្ចតែក្នុងបាបកម្មទាំងឡាយ នឹងត្រូវទៅស្ថិតនៅក្នុងផ្ទះ គឺឋាននរកដោយពិត តែបែរអាចវៀរចាកអបាយ-ទុក្ខបាន ព្រោះហេតុបានថ្វាយបិណ្ឌបាត្រដល់ព្រះថេរៈព្រះនាមសារីបុត្ត ។ ទានដែលពោរឃាដកាមាត្យបានធ្វើ ជាអំពើមិនប្រឡំលាយដោយសេចក្តីទុក្ខឡើយ ។ ដោយផលានិសង្សបិណ្ឌបាត្រទាននេះ ពោរឃាដកាមាត្យបានឡើងទៅកាន់ទេវបុរីដ៏ប្រសើរ សឹងមានពួកទេវតាចោមរោមជាបរិវារជាសុខសប្បាយពិត ។

តស្មា សុខេត្តេ សទ្ធាយ ទេថ ទានានិ កាមិតំ
រក្ខិតព្វា សីលញ្ច ផលញ្ញាតិសុទុរំ ។

ព្រោះហេតុនោះ សប្បុរសទាំងឡាយត្រូវតែឲ្យទាន ដែលជាគុណអាចឲ្យសម្រេចប្រយោជន៍ដល់បុគ្គលជាស្រែបុណ្យល្អ តាមចិត្តសទ្ធាដោយពិត ត្រូវតែរក្សាសីល (តាមកាលគួរ) រីទាននឹងសីលនេះជាធម្ម-ជាតមានផលល្អក្រៃលែង ។

កាលនោះ ភិក្ខុទាំងឡាយបានចូលមកប្រជុំគ្នាក្នុងរោងធម្មសភា បានលើកអញ្ជលីឡើងថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ទើបក្រាបបង្គំទូលថា: បពិត្រព្រះមានព្រះភាគដ៏ចំរើន! បុរសដ៏លាមក

ដូចចោរឃាតកាមាត្យនោះ តើនឹងទៅកើតក្នុងអបាយណា ព្រះអង្គ ព្រះបរមសាស្តាជាម្ចាស់ ទ្រង់ត្រាស់ព្យាករណ៍ថា ម្នាលភិក្ខុទាំងឡាយ បុរសនោះបានទៅកើតក្នុងស្ថានទេវលោកហើយ ដោយអានុភាពនៃទានដែលបុរសនោះបានថ្វាយដល់ព្រះសារីបុត្តក្នុងថ្ងៃនេះឯង មួយទៀតសោតលុះអម្ពុងយូរទៅនាអនាគតកាល បុរសនោះនឹងបានត្រាស់ដឹងជាព្រះបច្ចេកពុទ្ធមួយព្រះអង្គ ដោយអំណាចផលានិសង្សដែលហូរជូនមកពុំដាច់នោះដោយពិត ៗ លុះព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងយ៉ាងនេះហើយក៏ទ្រង់ប្រកាសជាបទគាថាដូចនេះថា :

ភោ សារិបុត្តនិហិតស្សទានំ
ខណេន ទាបេតិ ច សគ្គមគ្គំ
តស្មា សុខេត្តេសុ ទទាថ ទានំ
កាមត្តកំ សគ្គបទម្បេត្ថ ៗ

អធិប្បាយថា ម្នាលអ្នកទាំងឡាយដ៏ចំរើន ការថ្វាយអាហារបិណ្ឌបាត្រ មានប្រមាណតិចដែលបុរសអ្នកសំឡាប់ចោរ បានថ្វាយហើយដល់ព្រះមហាសារីបុត្ត ក៏គង់អាចញ៉ាំង ឲ្យបានដល់នូវស្ថានសួគ៌ទេវលោកមួយរំពេច ព្រោះហេតុដូចនោះ អ្នកទាំងឡាយត្រូវតែឲ្យទានដែលជាគុណញ៉ាំងសេចក្តីប្រាថ្នាឲ្យសំរេច ជាឧបាយទៅកាន់ស្ថានសួគ៌ឯបរលោក ចំពោះបុគ្គលអ្នកមានសីល ទុកដូចស្រែដ៏មានដីជាតិល្អដោយពិត ៗ

សម្ដែងរឿងនិទានបុរសអ្នកសំឡាប់ចោរ ជាគំរប់ប្រាំមួយក្នុងវគ្គទីបី គឺចប់សេចក្ដីជាសង្ខេប តែប៉ុណ្ណេះឯង ។

---

## ៣– សទ្ធោបាសកវត្ថុកថា

សម្ដែងរឿងនិទានឧបាសកម្នាក់ អ្នកមានសទ្ធាតទៅទៀត ដោយករបាលីថា: អតីតេ កិរ កស្សបទសពលកាលេ ដូចនេះជាដើម អធិប្បាយថា បានឮរឿង ៗ មកថា ក្នុងអតីតកាលកន្លងទៅយូរហើយ ក្នុងជំនាន់សាសនានៃព្រះទសពលសម្ពុទ្ធ ទ្រង់ព្រះនាមកស្សបៈនោះ មានបុរសម្នាក់ អ្នកមានសទ្ធាជ្រះថ្លាក្នុងគុណព្រះរតនត្រ័យ តែងចិញ្ចឹមជីវិត ដោយការស៊ីឈ្នួលគាបអំពៅ គាត់នៅអាស្រ័យក្នុងក្រុងពារណសីនោះឯង ។

មានកាលមួយថ្ងៃ បុរសនោះបានឃើញភិក្ខុមួយរូបមានជម្ងឺ គាត់បានប្រគេនសប្បិប្រមាណមួយវែកដល់ភិក្ខុនោះ ដល់ថ្ងៃមួយទៀត បានប្រគេនស្ករអំពៅមួយដុំ ដល់ភិក្ខុមួយរូបដទៃ អ្នកមានជម្ងឺដូចមុននោះដែរ ថ្ងៃជាខាងក្រោយទៀត បានឃើញសុនខ (ឆ្កែ) មួយរអត់បាយ រឃ្លានបាយពន់ពេក គាត់មានចិត្តមេត្តា បានឱ្យបាយមួយដុំល្មមស៊ីឆ្អែតដោយអនុគ្រោះដល់ឆ្កែនោះ ៗ មិនតែប៉ុណ្ណោះ បានឱ្យហិរញ្ញវត្ថុមួយកហាបណៈដល់បុរសម្នាក់ អ្នកជំពាក់បំណុលគេដោយសេចក្ដីអាសូរ ។ អដេត-

ធិវសំ លុះដល់ថ្ងៃមួយជាខាងក្រោយទៀត បុរសនោះបានចូលស្តាប់ព្រះធម៌ទេសនា ក៏មានសេចក្តីជ្រះថ្លាហើយបានបូជាសំពត់សាដកមួយដល់ធម្មថិកដែលសម្តែងព្រះធម៌ទេសនានោះឯង ។

ឯបុរសនោះ បានធ្វើបុណ្យដូចបានពណ៌នាប៉ុណ្ណេះហើយ បានតាំងប្រណិធាន សេចក្តីប្រាថ្នាដូចនេះថា កាលបើខ្ញុំអន្ទោលទៅក្នុងភពតូចធំនានា បណ្តាវត្ថុទាំងឡាយដែលមាននៅក្នុងសមុទ្រទឹកដីជាដើម ប្រសិនបើខ្ញុំប្រាថ្នាវត្ថុណា ៗ ហើយ ក៏សូមវត្ថុនោះ ៗ សំរេចតាមប្រាថ្នារបស់ខ្ញុំដោយពិត ។

លុះចំណេរកាលមកជាខាងក្រោយ បុរសអ្នកមានសទ្ធានោះក៏ធ្វើមរណកាលក្ស័យជីវិតហើយ បានទៅកើតក្នុងស្ថានទេវលោកនាយមួយរំពេច បីដូចជាភ្ញាក់អំពីដេកលក់ដូច្នោះ បានសោយទិព្វសម្បត្តិយ៉ាងធំប្រសើរក្នុងស្ថានទេវលោកនោះឯង លុះអស់កំណត់អាយុទិព្វហើយក៏ច្យុតអំពីស្ថានទេវលោកនោះ ចុះមកចាប់បដិសន្ធិកើតក្នុងត្រកូលព្រាហ្មណ៍មហាសាល ដ៏ស្តុកស្តម្ភមាំមួនមានទ្រព្យសម្បត្តិច្រើន ក្នុងនគរសាវត្ថីជំនាន់ពុទ្ធកាលនៃព្រះមានព្រះភាគជាម្ចាស់នៃយើងនេះឯង ។

លុះប្រសូតិចេញអំពីផ្ទៃមាតាហើយ ក៏បានចំរើនវ័យវៀងវៃមាការដឹងក្តីឡើងហើយ តែងចូលទៅកាន់វត្តស្តាប់ធម៌ទេសនាអស់កាលទាំងពួងហើយបានពុទ្ធវេទាសក្នុងយកពីសផង នូវអានិសង្សក្នុងការចេញបួសផង

បានសុំអនុញ្ញាតអំពីសំណាក់មាតាបិតាហើយ ទើបចេញទៅបួសក្នុងព្រះពុទ្ធសាសនា ។ លុះបានបួសរួចហើយពុំយូរប៉ុន្មាន បានចំរើនសមាធិកម្មដ្ឋាន ក៏បានសម្រេចព្រះអរហត្ត ក៏ផ្តាច់បង់នូវកងកិលេសទាំងពួងជាស្រឡះ ព្រមទាំងបដិសម្ភិទាញាណជាអង្គព្រះអរហន្ត វិសេសក្នុងលោក ។

លំដាប់តពីនោះមក ព្រះថេរៈអង្គនោះក៏បានថ្វាយបង្គំលាព្រះសាស្តាចារ្យជាម្ចាស់ហើយចេញទៅអំពីវត្តព្រះជេតពន មានព្រះភិក្ខុសង្ឃប្រមាណប្រាំរយអង្គហោមហែមជាយសបរិវារ និមន្តទៅកាន់ឧត្តរនគរ ។ ក៏ឯក្នុងឧត្តរនគរនោះ មានករិយាសេដ្ឋីម្នាក់ជាស្ត្រីមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា បានឃើញព្រះថេរៈអង្គនោះព្រមទាំងព្រះសង្ឃប្រាំរយអង្គជាបរិវារនិមន្តចូលមកដើម្បីបិណ្ឌបាត្រចង្ហាន់ ក៏មានសេចក្តីជ្រះថ្លាសើពន់ម្ហ្មានទទួលយកបាត្រអំពីព្រះហស្តព្រះថេរៈ ហើយប្រគេនចង្ហាន់ចំពោះព្រះថេរៈព្រមទាំងព្រះសង្ឃប្រាំរយអង្គ និមន្តឆាន់ក្នុងគេហស្ថានរបស់ខ្លួននោះឯង ។ លុះព្រះសង្ឃធ្វើភត្តកិច្ចឆាន់ស្រេចហើយ នាងក៏អារាធនានិមន្តព្រះថេរៈព្រមទាំងព្រះសង្ឃទាំងនោះដើម្បីទទួលចង្ហាន់ក្នុងគេហដ្ឋានរបស់នាងតទៅជាប់ ហើយនាងចាត់ចែងចំណាយទ្រព្យឲ្យជាងស្ថាបនាអគារស្ថានប្រមាណប្រាំរយល្វែង ព្រមទាំងតាក់តែងសម្ភារៈគ្រប់ប្រដាប់ប្រគេនព្រះសង្ឃទាំងអស់នោះ ហើយបវារណាឲ្យគង់នៅអាស្រ័យក្នុង

សេនាសនៈនោះឯង នាងបានគោរពប្រតិបត្តិបំរើព្រះសង្ឃទាំងអម្បាលនោះ ដោយបច្ច័យបួនជាប់ពុំដាច់ឡើយ ។

លំដាប់នោះ ព្រះថេរៈបានញុំាងសេដ្ឋីភរិយានោះឲ្យឋិតនៅក្នុងបញ្ចសីលដ៏ខ្ជាប់ខ្ជួនតទៅដរាប ហើយលោកគង់នៅក្នុងទីនោះសមគួរតាមកាល ។ លុះថ្ងៃជាខាងក្រោយ ព្រះថេរៈមានប្រាថ្នានឹងនិមន្តទៅក្នុងទីដទៃ លោកបាននាំភិក្ខុទាំងប្រាំរយជាបរិវារចេញទៅកាន់ជនបទគ្រាមតាមលំដាប់ និមិត្តតែបានដល់ហើយក៏គង់នៅអាស្រ័យក្នុងស្រុកនោះ ពុំទាន់បានយូរប៉ុន្មាន ក៏និមន្តឡើងកាន់សំពៅចេញអំពីជនគ្រាមនោះទៀត ព្រមទាំងភិក្ខុប្រាំរយជាបរិវារបើកឆ្លងសមុទ្រសំដៅទៅកាន់ត្រើយខាងនាយ ។ កាលព្រះថេរៈនិមន្តទៅដល់ពាក់កណ្តាលសមុទ្រ ស្រាប់តែមានឧទររោគ (រោគខ្យល់) ចាប់សឹកសៀតកើតឡើង បៀតបៀនព្រះថេរៈឲ្យបានទុក្ខវេទនាជាទម្ងន់ ។

ឯភិក្ខុទាំងឡាយ បានឃើញដូច្នោះហើយ ក៏ទូលសួរព្រះថេរៈថា: បពិត្រលោកដ៏ចំរើន កាលពីមុន ៗ បើរោគនេះកើតឡើងដល់លោកម្ចាស់ហើយតើ រម្ងាប់ទៅវិញដោយថ្នាំអ្វី ?

( នៅមានត )

# មហោសថជាតក

ព្រះសាសនមុនី កឹម-ត្រូវ ពិនិត្យ

(តមក)

---

អថេកទិវសំ ក្នុងកាលនោះ មានកាលសម័យថ្ងៃមួយក្ដី អាចារ្យកេវដ្ដព្រាហ្មណ៍ រមិលមើលមុខផ្ទះកញ្ចក់ពពិលយល់ស្រមោលស្នាមដំបៅនៅក្នុងថ្ងាសនោះហើយ គិតក្នុងចិត្តថា ស្នាមនេះ ដែលមហោសថបុត្រគហបតីកធ្វើអាត្មាហើយ អាចារ្យកេវដ្ដព្រាហ្មណ៍ខឹងមហិមាក្រៃពេក ផ្សិតខ្លួនចំឡែកខ្មាសអស់ស្ដេចមួយរយនឹងមួយ ទើបអាចារ្យកេវដ្ដ-ព្រាហ្មណ៍មកត្រិះរិះគិតតែក្នុងចិត្តឯងថា កាលណាហ្ន៎! អញនឹងបានឃើញខ្នងនៃស្ដេចនោះ? លុះគិតហើយថា បើដូច្នោះមានតែអញទៅធ្វើឧបាយកលយកកូនស្រីនៃស្ដេចយើង ឈ្មោះនាងបញ្ចាលចន្ទី នាងនោះជំទ្រទ្រង់នូវរូបដោយឧត្តមល្អដូចស្ត្រីសួគ៌ អញបង្ហាញនាងនោះឲ្យស្ដេចវិទេហរាជមើល ហើយអញនឹងប្រលោមស្ដេចវិទេហរាជ ដោយនូវកាមគុណថា យើងនឹងឲ្យនាងទៅជាភរិយាស្ដេចវិទេហរាជ ឯឧបាយកលនេះ ដូចត្រីលេបផ្លែសន្ទូចនាំមកមួយអន្លើ បើស្ដេចវិទេហរាជ នូវទៅមហោសថមកដល់កណ្ដាប់ដៃអញហើយ អញនឹងសម្លាប់អ្នកទាំងពីរផឹកស្រាជ័យហោង ឯអាចារ្យកេវដ្ដព្រាហ្មណ៍គិតនូវឧបាយកល អម្បាលនោះហើយ ឡើងទៅគាល់ព្រះបាទចុលនីព្រហ្មទត្តរាជ ដល់ហើយឡើង

លើព្រះរាជមន្ទីរ អង្គុយឋានមួយសមគួរទីឯកាគ្នា ហើយក្រាបទូលថា ទេវ បពិត្រព្រះសម្មតិទេព ក្សត្រថ្លៃប្រសើរជាអម្ចាស់ខ្ញុំអើយ! អញ្ញខ្ញុំមានគំនិត ឧបាយកលមួយ អញ្ញខ្ញុំពុំទាន់បានក្រាបទូលព្រះបាទចុលនីព្រហ្មទត្តរាជ ឡើយ ។ ស្តេចស្តាប់ពាក្យអាចារ្យកេវដ្តព្រាហ្មណ៍ទូលនូវប្រការអម្បាល នោះហើយ មានបន្ទូលថា អាចារិយ ម្នាលអាចារ្យអើយ! អញ្ញសព្វថ្ងៃ អាស្រ័យនឹងគំនិតអាចារ្យឯងហោង ថាបើដូច្នោះ តើគំនិតព្រះស្តេចនឹង គិតធ្វើដូចម្តេច? ក៏ចូរព្រះស្តេចថ្លែងប្រាប់មកឲ្យបានដឹង នូវគំនិតឧបាយ កលព្រះស្តេចយល់នោះ ឲ្យប្រាកដឥឡូវនេះហោង ។ ទើបអាចារ្យ កេវដ្តព្រាហ្មណ៍ទូលថាដូច្នេះ មហារាជ បពិត្រមហារាជអើយ! រីឧបាយ កលដទៃ សូម្បីនឹងដូចឧបាយកលនេះនោះគ្មានឡើយ ។ ស្តេចបន្ទូល ថា បើដូច្នោះ ចូរអាចារ្យស្រដីប្រាប់មកហោង ។ អាចារ្យកេវដ្ត-ព្រាហ្មណ៍ទូលថា មហារាជ បពិត្រមហារាជអើយ! គួរដើម្បីនឹងមាន តែយើងតាំងនេះឯងហោង ។ ឮដ៏កាលនោះ អាចារ្យកេវដ្តព្រាហ្មណ៍ នាំស្តេចនោះឲ្យឡើងទៅលើប្រាសាទ ហើយថាដូច្នេះ មហារាជ បពិត្រ មហារាជអើយ! យើងនឹងប្រលោមលោមស្តេចវិទេហរាជនោះ ដោយ នូវសមាគិលេស ឲ្យបានស្តេចវិទេហរាជនឹងមហោសថបុត្រគហបតី ហើយយើងនឹងឲ្យសម្លាប់ហោង ។ ស្តេចមានបន្ទូលថា ហៃអាចារ្យ អើយ! រីឧបាយកលនោះគាប់ពិតហោង ថាបើដូច្នោះ យើងនឹងប្រលោម

លោមស្តេចនោះឲ្យបាន នាំមកដោយនូវអំពើទុច្ចរិតយ៉ាងដូចម្តេច ? ។ អាចារ្យកេវដ្តព្រាហ្មណ៍ទូលថា មហារាជ បពិត្រមហារាជអើយ ! ព្រះរាជធីតានៃព្រះបាទអម្ចាស់នោះ ទ្រង់នាមឈ្មោះ ហៅនាងបញ្ចាលចណ្ឌី ជាស្រីទ្រង់នូវរូបឆោមនោះល្អឧត្តមសមនូវលក្ខណាផង យើងទាំងឡាយ ក៏ទៅរៀបនូវពាក្យសរសើរនូវលំអស្រីពិលាសដោយនូវគុណបុណ្យនៃនាងនោះ ដោយចំណង់បម្រើ យើងបានជាគាព្យដកបដោយនូវប្រាជ្ញាឈ្លាសគន្ធគន្ធើបផងទាំងឡាយ យើងនឹងឲ្យទៅច្រៀងនូវទំនុកផងឮដំមិថិលានគរ ស្រីរតនប្រសើរដ៏មានរូបសុភាពបវរលំអដូច្នេះ តើនឹងធ្វើអ្វី ក៏មិនបាននូវរាជសម្បត្តិស្តេចវិទេហរាជនោះ ? កាលនោះ បើយើងដឹងហើយនូវសុភាពជាស្តេចវិទេហរាជ ប្រតិព័ទ្ធកាត់សំឡាញ់ដោយល្បើកនៃនាងនោះមកដល់យើងហើយ អញខ្ញុំនឹងទៅឮដំហានោះ ហើយនឹងកំណត់ថ្ងៃទេ ណែឲ្យមកយកទាំងក្លនគហបតី ទុចមារបដូចត្រីលេបសន្ទូច បានមកហើយកាលបើដូច្នោះហើយ យើងនឹងសម្លាប់ហោង ។ ព្រះបាទចុលនីព្រហ្មទត្តរាជ ស្តេចស្តាប់នូវពាក្យនៃអាចារ្យកេវដ្តព្រាហ្មណ៍នោះហើយ មានព្រះទ័យត្រេកអរទទួលយក ហើយមានព្រះបន្ទូលថា នែអាចារ្យអើយ ! វិទុបាយកលនៃអ្នកនោះជាទុបាយកលល្អគាត់ អញនឹងធ្វើដូច្នោះហោង ។

កំ បន មន្តំ ចុលនីព្រហ្មទត្តស្ស សយនបាលិកា សាលិកា សកុណិកា សុត្វា បច្ចក្ខំ អកាសិ ។

វិសារិកា ដែលតែងរក្សានូវក្រឡាបន្ទំនៃព្រះបាទចុលីព្រហ្មទត្តនោះ បាញនូវគំនិតនោះ បានធ្វើឲ្យប្រាកដដូច្នោះហើយស្ងៀមនៅហោង ។

(ឯកនិបាតសំ) ចោភណា កាព្យការកេ បក្កោសា- បេត្វា ពហុជនំ ឧត្វា ឩតរំតេសំ ឧស្សេត្វា តាតា ឯតិសព្ទា រូបសម្បត្តិ ឆិសព្ទយ កាព្យំ កាភេជាតិ អាបា ។ មានកាលមួយថ្ងៃ ស្តេចមានបន្ទូលហៅនូវអ្នកតាស់បេះបង់គន្ធ៍កាព្យដកបទំនុកអំពីបុរាណមក ស្តេចឲ្យយកនូវទ្រព្យនោះច្រើន ឲ្យទៅអ្នកតាស់នោះ ហើយបង្ហាញនូវព្រះរាជធីតាកញ្ញានៃអ្នកតាស់បេះបង់គន្ធ៍ទំនុកផងដូច្នោះនោះថា ហៃក្មេង អ្នកទាំងឡាយ ចូរធ្វើទំនុកផងគន្ធ៍និយាយអភិប្រាយ ហេតុអាស្រ័យនូវលំអរូបសម្បត្តិនៃនាងបញ្ចាលចន្ទីនោះហោង ។ រីអស់អ្នកផងចងនូវចម្រៀងសរសើរដំណើរនាងមុខគួរឲ្យស្រណុកចិត្តអាណិតក្រៃពេកណាស់ ឲ្យព្រះរាជាទ្រង់ព្រះសណ្តាប់ ។ ស្តេចមានព្រះហឫទ័យត្រេកអរ ទ្រង់ព្រះរាជទានទ្រព្យដ៏ច្រើនដល់អ្នកបេះបង់គន្ធ៍កាព្យទាំងឡាយនោះ ។ រីអស់ស្រីរបាំផង រៀនកាព្យអំពីសំណាក់នៃអ្នកប្រាជ្ញទាំងឡាយ បេះបង់គន្ធ៍កាព្យនោះហើយ ក៏ច្រៀងលេងញដ៏ល្បែងមណ្ឌលមហោស្រពនោះហោង ។ រីចម្រៀងផងនោះបាញខ្ចូលាយសុះសាយទៅដល់ស្រុកក្រៅលំនៅជនបទប្រាកដស្រេច ដូច្នោះហោង គេសុ ល្បែងលេងអ្នកផងនោះ ធ្វើញដ៏ចម្រៀងខ្ចូលាយសាយ

សត្វគ្រប់ទៅពុំដល់ផ្នែកនៃមនុស្សម្នាមហាជនផងទាំងឡាយ ស្ដេចមាន ព្រះបន្ទូលឲ្យហៅនូវអ្នកច្រៀងចំរៀងផងនោះមកថា តា តា ហៃក្មេងទាំង ឡាយ តុម្ហេ រីអ្នកទាំងឡាយ ចូរចាប់យកនូវបក្សីចងនូវចង្រ្កង់ពុំដកនៃ បក្សីនោះផង ហើយលែងបក្សីផង ឲ្យហើរទៅ ចូរក្មេងចុះមកហោង ៗ អ្នកផងនោះ គេក្ដីនូវសំពួចង្រ្កង់នោះពុំដកណ្ដាលអាកាសហើយ ក៏សឹង ដំមានពាក្យមេត្រីស្រដីសរសើរដំណើរថាដូច្នេះ ការ ដោយយើងឮមក នេះ គលជាទេវតា ឬ មនុស្សឯណា ក៏មកច្រៀងសរសើរដំណើរអំពី គុណបុណ្យលំអរូបសម្បត្តិនៃនាងកូនស្រីស្ដេចឈ្មោះនាងបញ្ចាលចន្ទី រី អំពើលោកធ្វើប្រការដូច្នេះ ប្រយោជន៍ឲ្យប្រាកដ រីអ្នកផងនោះសឹងធ្វើ ដូច្នោះហោង ៗ រីស្ដេចមានបន្ទូលឲ្យហៅនូវអ្នកប្រាជ្ញមក អាចចេះចង នូវទំនុកនោះផង មកថាដូច្នេះថា តា តា ម្នាលក្មេងទាំងឡាយ រីឥឡូវនេះ ចូរអ្នកទាំងឡាយ ចងនូវចម្រៀងសរសើរដំណើរលំអរូបសម្បត្តិនៃនាង នេះហើយចងនូវកាព្យដកបទាំងពួងវិញថា រីនាងកុមារីកាបញ្ចាលចន្ទីនេះ ឯង ឃវ្ហា មានសុភាពរូបល្អដូច្នេះនេះ មិនគួរបើអញទឹងឲ្យស្ដេចដទៃ ពុំប្រលុងសកលជម្ពូទ្វីបនេះឡើយ គួរតែអញឲ្យដល់ស្ដេចវិទេហរាជ ពុំមិថិលានគរ រីឯឥស្សរិយយសនៃស្ដេចវិទេហរាជវិញ ក៏សមគួរដល់ ព្រះរាជធីតានេះពេកហោង ៗ រីអ្នកផងចេះចងនូវទំនុកកាព្យនោះ ធ្វើដូច ព្រះបន្ទូល ហើយទៅក្រាបទូលស្ដេច ៗ ព្រះរាជទ្រង់ឲ្យនូវទ្រព្យដល់

អ្នកប្រាជ្ញផងនោះ ហើយបង្គាប់ប្រើវិញទៀតថាដូច្នេះ តាតា ម្នាល ក្មេងទាំងឡាយ តុម្ហេ រីអ្នកទាំងឡាយ ចូរទៅហើយច្រៀងដោយ កលឧបាយនេះ ឮដល់មិថិលានគរនោះវិញទៀតហោង ៗ គេ តាធិ កាយន្តា អនុបុព្វេន មិថិលំ បត្តា សមជ្ឈមណ្ឌលេ គាយឹសុ ៗ រីអ្នកចម្រៀងផងនោះក៏ច្រៀងនូវចម្រៀងនោះ ដើររៀង ទៅកាន់មិថិលានគរនោះដោយនូវលំដាប់ ហើយច្រៀងឮដល់មណ្ឌលម-ហោស្រព ៗ រីមហាជនផងទាំងឡាយ ស្តាប់នូវចម្រៀងនោះ រាតព្រើក កើតមានសំរួលសំណើចជារយជាពាន់ ស្តេចកាន់ឲ្យនូវទ្រព្យនោះច្រើន ឮដល់អ្នកផងច្រៀងនោះ ៗ ឮដល់កណ្តាលរាត្រីយប់នោះហោង រីអ្នកផង នោះក៏ច្រៀងលើចុងឈើ ឮដល់កាលបែកបច្ចូសនោះហើយ ក៏ចងចង្ក្រឹន ឮដល់កនៃសត្វបក្សីផង ហើយក៏ចុះមកហោង ៗ រីមហាជនផងទាំងឡាយ ឯណា ៗ សុត្វា រាជក្ខនូវសត្វចង្ក្រឹននោះឮដល់អាកាសថាដូច្នេះ រីទេវតាវិ-សេសឯណា គាយន្តិ ក៏ច្រៀងសរសើរនូវលំអសម្បុររូបនៃកូនស្រីស្តេច ឈ្មោះនាងបញ្ចាលចន្ទីស្រីដ៏ប្រសើរហើយគួរ រីកាលាហលវល់ជាមួយ អហោសិ ស្រេចមានឮដល់ក្នុងនគរហោង ។ ម៉្លោះហើយ រីស្តេចវេទហ-រាជក្ខនូវស័ព្ទនោះហើយ អ្នកឲ្យហៅនូវអ្នកចម្រៀងផងនោះមកលេងនូវ វៀងមហាស្រពលើព្រះរាជមន្ទីរអាត្មា ហើយស្តេចក្រេកអរទើបឲ្យទ្រព្យ

ផងនោះច្រើនទៅអ្នកចម្រៀងផងនោះហើយ ដោយនូវគំនិតថាដូច្នេះ
ចុលនីកាជា រស្តេចចុលនីព្រហ្មទត្តរាជ សមគាត់ខ្លាចនឹងបង់ឲ្យនូវព្រះ
រាជបុត្រីកូនស្រីតែងប្រសើរ មានព្រះដំណើរនោះល្អ មានសុភាពដូច្នេះ
នេះ មកអញមិនទេឡើយ ។ រីអ្នកចម្រៀងផងនោះ វិលទៅទូលព្រះបាទ
ចុលនីព្រហ្មទត្តរាជហោង ។ កាលនោះ បើដូច្នោះហើយ អាចារ្យកេវដ្ត-
ព្រាហ្មណ៍ថានឹងស្តេចនោះដូច្នេះ មហារាជ បពិត្រមហារាជអើយ !
ឥឡូវនេះ អញខ្ញុំនឹងទៅប្រយោជន៍នឹងកត់ថ្ងៃ ខែ ឲ្យដឹងប្រាកដហោង ។
ស្តេចនោះថា អាចារ្យ ហៃអាចារ្យអើយ ! សាធុគាប់ហោង ថាបើ
ដូច្នោះ គួរគប្បីនឹងបានអ្វីក៏នឹងយកទៅ ? ។ អាចារ្យកេវដ្តព្រាហ្មណ៍ថា
គួរគប្បីតែមានបណ្ណាការអ្វីបន្តិចទៅផងនោះ ទើបគាប់ហោង ។ ទើប
ស្តេចប្រើឲ្យអាចារ្យកេវដ្តព្រាហ្មណ៍នោះ យកនូវគ្រឿងបណ្ណាការផងទៅ
ដល់ស្រុកវិទេហរដ្ឋមិថិលាមហានគរព្រះបាទវិទេហរាជ ដោយនូវរេហ៍
ពលសកលយោធាសេនាផងច្រើនហោង ។ រីមហាជនផងទាំងឡាយ
គេឮថាអាចារ្យកេវដ្តព្រាហ្មណ៍មកដូច្នោះហើយ អ្នកអើយ ! កើតជាកោ-
លាហលវល់ជាមួយក្នុងព្រះនគរ សឹងថាដូច្នេះ បានឮថាព្រះបាទចុលនី
ព្រហ្មទត្តរាជក្តី ព្រះបាទវិទេហរាជក្តី សឹងនឹងបង់ពន្ធជាមិត្តគិតមេត្រីផង
គ្នា មែនពិត ឬ ម្តេចអេះ ? នោះហោង មហាជនផងទាំងឡាយ សឹង
និយាយនឹងគ្នាថា ព្រះបាទចុលនីព្រហ្មទត្តរាជ គាត់គាបថានឹងបង់ឲ្យព្រះ

រាជបុត្រីនៃអាត្មា  មកជាព្រះអគ្គមហេសីនៃស្ដេចយើងមែនពិត  ឬជាមួយ
សោតលោកធ្វើឲ្យបាយកលល្បួងទេ ? តែថាបានឮមក  អាចារ្យកេវដ្ដ-
ព្រាហ្មណ៍ឯង  គាត់តែងប្រយោជន៍នឹងរកគត់ថ្ងៃឫក្សពារពេលាណាជាល្អ
ហើយនឹងនាំពត៌មានទៅថ្កានព្រះបាទចុលនីវិញហោង ។ ព្រះបាទវេទេ-
ហរាជ  ក៏ស្ដេចឮនូវពត៌មាននោះហើយ  សូម្បីព្រះមហោសថក្ដី  ក៏អ្នក
ឮនូវស័ព្ទពត៌មាននេះដែរ  ដំរិះនេះ  អ្នកគិតស្រេចមានទៅព្រះមហាសត្វ
អ្នកគិតថា  នាដំណើរអាចារ្យកេវដ្ដព្រាហ្មណ៍នោះ  នាយល់ថាមិនសុ-
ភាពគាប់ចិត្តនៃអញឡើយ  ម្យ៉ាងហើយពោធិសត្វអ្នកតែងនឹងដឹងអាចារ្យ
កេវដ្ដព្រាហ្មណ៍មកនោះជាក់ច្បាស់ហើយ ។ ពោធិសត្វអ្នកប្រើពត៌មាន
ទៅចំពោះថ្កានកាន់បុរសជាឧបនិក្ខិត្ត  ដែលទៅបំរើសំណាក់នៃព្រះបាទ
ចុលនីនោះថាដូច្នេះ  ករ្ដា  អ្នកទាំងឡាយ  ជាឆត្តា  ដឹងហើយនូវ
អាថ៌នេះឲ្យជាក់ច្បាស់  ហើយព្រះស្ដែងចូរប្រើមកកាន់ព្រមានអញវិញ
ហោង ។  ឮដំណាលនោះ  ឧបនិក្ខិត្តបុរសផងដែលទៅមុននោះមិញ
ប្រើពត៌មានមកកាន់ពោធិសត្វវិញនោះថាដូច្នេះ  យើងមិនដឹងនូវពត៌មាន
ដោយនូវច្បាស់នោះសោត  ស្ដេចឯងក្ដី  អាចារ្យកេវដ្ដព្រាហ្មណ៍ក្ដី  សឹង
អង្គុយនៅឰដ៏ល្វែងក្រឡាព្រះបន្ទំ  មកគិតមានតែសត្វសារិកា  ជាសត្វ
បក្សីតែងរក្សាក្រឡាព្រះបន្ទំនៃស្ដេចឯង  តែងនឹងគិតគំនិតនោះហោង ។
ពោធិសត្វស្ដាប់នូវពាក្យនោះហើយ  ក៏គិតថា  អកិកាសនៃសត្រូវនោះ

អង្គមានទូវប្រការម្តេចមិញ រីនគរនោះ គេធ្វើចំណែកប្រពៃ គាក់តែង លេងឲ្យសប្បាយដូច្នេះ រីអញនេះ មិនឲ្យអាចារ្យកេវដ្តព្រាហ្មណ៍ដើម្បីទឹងយល់ឡើយ រីព្រះមហាក្សត្រនោះ អ្នកឲ្យសារទូវផ្លូវនាទឹងមកនោះទូវពពារក្នុងសង់ខាងអំពីទ្វារនគរ ដរាបដល់ព្រះរាជចន្ទុំ អំពីព្រះរាជវាំង ឲ្យផិតមាគ៌ាដរាបទៅដល់ផ្ទះនៃអាត្មាហោង សូម្បីឯលើក្តី អ្នកឲ្យបាំងនូវពពារសោត អ្នកធ្វើប្រាយរាយនូវលាជក្រៀជាដើមក្នុងផ្ទៃក្រោម អ្នកឲ្យដំកល់នូវក្អមទឹកពេញ អ្នកឲ្យដាំនូវដើមចេក ឲ្យដឡើងនូវទង់ផង ។

កោវេដ្ឋ ឧតរំ បវេសិត្វា សុវីកត្តំ ឧតរំ អ-
បស្សន្តោ រញ្ញោ មេ មន្តោ អលង្ការបិតោតិ ចិន្តេត្វា
ឧតរស្ស អឧស្សឧត្តំ គតការំ ឧ ជាជាតិ ។ រីអាចារ្យកេវដ្តព្រាហ្មណ៍ចូលទៅនគរនោះ មិនយល់នូវចំណែកនគរដែលគេរណ្តាប់ប្រពៃនោះឡើយ គិតថា រីផ្លូវណោករណ្តាប់ប្រពៃដើម្បីអញ មិនដឹងនូវសុភាពគេធ្វើ ដើម្បីមិនឲ្យយល់នគរនោះឡើយ ហើយអាចារ្យកេវដ្តព្រាហ្មណ៍ទៅថ្វាយបង្គំស្តេច បង្ហើរនូវគ្រឿងបណ្ណាការទាំងពួងនោះទៅស្តេច ហើយអង្គុយក្នុងជំហានមួយ ដ៏មានសក្ការៈនោះគឺស្តេចបានធ្វើហើយ ក៏នឹងប្រាប់នូវហេតុដំណើរនៃអាត្មាមកនោះ អភាសិ ក៏ស្រដីជាបទគាថាដូច្នេះ :

រាជា សន្ថវកាមោ តេ រតនានិ បវេច្ឆតិ
អាគច្ឆន្តុ ឥតោ ទូតា មញ្ជុកា បិយភាណិនោ ។
ភាសន្តុ មុទុកា វាចា យា វាចា បដិនន្ទិតា
បញ្ចាលោ ច វិទេហោ ច ឧភោ ឯកា ភវន្តុ តេតិ ។

មហារាជ បពិត្រមហារាជអើយ ! រីស្តេចនៃយើងនេះមានបំណងជាមិត្តផិតស្នេហាជាមួយអន្ទើនឹងអម្ចាស់ច្បាស់ សមបន្ទើរឲ្យនូវព្រះរាជ-ធីតាបុត្រីស្រីរតន៍ប្រសើរ មកដល់មហារាជហោង ហើយចាប់ដើមអំពីនេះទៅគូរ រីរាជទូតនាមានសំឡេងពីរោះនោះ ស្រដីគួរស្រឡាញ់ពេញចិត្ត គឺយកនូវគ្រឿងបណ្ណាការនាំសារចូលមកអំពីស្រុកបញ្ចាលនោះ ហើយ បពិត្រមហារាជអើយ ! រីពាក្យឯណាទន់ភ្លន់ពីរោះគួរត្រេកអរ រីពាក្យនោះនឹងស្រដីនូវពាក្យនោះហោង រីព្រះបាទបញ្ចាលចន្ទក្តី ព្រះបាទវិទេហរាជក្តី កំមហាក្សត្រទាំងពីរព្រះអង្គនោះ ចូលមូលអនុកូលនូវគ្នាជាមួយហោង ។

រីអាចារ្យកេវដ្តព្រាហ្មណ៍ថាអម្បាលនោះហើយ ក៏ទូលវិញទៀតថា មហារាជ បពិត្រមហារាជអើយ ! រីស្តេចជាអម្ចាស់នៃយើងខ្ញុំឯនាយ ស្តេចមានបំណងដើម្បីនឹងចង់ប្រើអាមាត្យដទៃបក្រៃនឹងខ្ញុំនោះ ក៏ខ្លាចអាមាត្យនោះ វាមិនអាចដើម្បីនឹងទទួលប្រាប់ពតិមានធ្វើឲ្យគាប់ចិត្ត គិតដូច្នោះហើយ ទើបស្តេចមានព្រះបន្ទូលត្រាស់ប្រើអញខ្ញុំករុណាថា ហៃ

អាចារ្យអើយ ! តុម្ហេ រីអ្នកអាចារ្យ ពោះជេដ្ឋា ចូរស្រដីឲ្យដឹងនឹងស្តេចនោះឲ្យប្រពៃហើយនៃ ព្រះស្តែងប្រលោមយកនូវស្តេចនោះឲ្យបានព្រះស្តែងថាដូច្នេះ មហារាជ បពិត្រមហារាជអើយ ! តុម្ហេ រីមហា-រាជ ចូរស្តេចលីលាទៅកូវ អម្ចាស់នឹងបាននាងកុមារីស្រីរ័តន៍ប្រសើរនាងមានដំណើររូបល្អក្រៃពេកហោង រីសុភាពជាស្ពានមេត្រី មួយអន្ទើនឹងអម្ចាស់យើងខ្ញុំ នឹងបិតថេរជាកេរ្តិ៍នៅហោង ។ ព្រះបាទវិទេហរាជស្តេចស្តាប់នូវពាក្យនៃអាចារ្យកេវដ្តព្រាហ្មណ៍នោះហើយ ស្តេចមានព្រះហឫទ័យនោះត្រេកអរផ្សព្វផ្សាយពេះពយ ហាក់ទៅដិតដោយនូវពុទ្ធថាដូច្នេះ គិរ ដោយយើងពុទ្ធមកនោះ អហំ រីអញនឹងបាននាងកុមារី ដ៏ទ្រង់នូវរូបឆោមនោះល្អឧត្តមពេកណាស់ ស្តេចបន្ទូលថា អាចារ្យអើយ ! ក៏ដោយនូវពុទ្ធមក រីពាក្យអាចារ្យឯងក្តី រីពាក្យនៃបាមហោសថក្តី ទៅព្វង៏ធម្មយុទ្ធនោះហើយ អាចារ្យឯង ចូរទៅកូវ នឹងបានយល់មហោសថកូនអញ សូម្បីអ្នកទាំងពីរ សឹងជាអ្នកប្រាជ្ញអាចឲ្យអត់គ្នាទៅវិញទៅមកយកចិត្តគំនិតនឹងគ្នាហើយចូរបានមកហោង ។ អាចារ្យកេវដ្តព្រាហ្មណ៍ស្តាប់នូវពាក្យនោះហើយ ក៏ក្រាបលាចុះសំដៅទៅ ដើម្បីនឹងចង់យល់ពៅមហោសថអ្នកប្រាជ្ញនោះ ដោយនូវគិតដូច្នេះថា អំពីនេះទៅកូវ យើងនឹងបានយល់នូវពៅអ្នកប្រាជ្ញនោះ ។ នាថ្ងៃនេះឯង រីពោធិសត្វអ្នកដឹងនូវសុភាពនៃអាចារ្យកេវដ្តព្រាហ្មណ៍ នឹងមកកាន់សំណាក់នៃអាត្មាអញ ។

គិតថាដូច្នេះ រីការសំណេះសំណាលចរចាទៅវិញទៅមក យកចិត្តគំនិត គ្នាមួយអន្លើនឹងអ្នកបាបធម៌នូវអញនោះ ចូរកុំឲ្យមានឡើយ អ្នកគិតដូច្នោះ ហើយ ក៏អ្នកផឹកនូវប្រេង សូម្បីបន្តិចស្រេចអំពីព្រឹកព្រហាមហោង ។ រីពោធិសត្វអ្នកលាបស្រលាបដោយលាមកភក់ គឺអាចម៍គោអាចម៍ក្របី អាចម៍មាន់-ទា-ឆ្កែ-ឆ្មា នូវអាចម៍មនុស្សផងដោយនូវបេងបត់បែន (ពាហា លេខ ១) ដ៏ច្រើនក្រាស់ក្រៃ ហើយអ្នកឲ្យលាបនូវប្រេងឮដ៏សសរផ្ទះ ហើយអ្នកឲ្យដាក់នូវគ្រែមាសមួយនោះ ពោធិសត្វថា រីក្រិតតែងទឹងជិត ហើយសឹងអ្នកឲ្យនាំចេញទៅនូវគ្រែតាំង រីគ្រែសំណល់លែងនោះមាន ច្រើនហោង ។ រីពោធិសត្វអ្នកឲ្យកត់សំគាល់មនុស្សទាំងឡាយថាដូច្នេះ តុម្ហេ រីអ្នកទាំងឡាយ ចូរស្រដីនឹងព្រាហ្មណ៍នោះ ជាអ្នកឆ្ពោះដើម្បីនឹង ស្រដីដូច្នេះថា ម្នាលព្រាហ្មណ៍អើយ ! ព្រះស្តែងកុំស្រដី សទ្ធឹ មួយ អន្លើនឹងចៅអ្នកប្រាជ្ញនោះ ឮដ៏ថៃនោះ គឺចៅអ្នកប្រាជ្ញនោះ ផឹកនូវប្រេង សូម្បីថាបើអញធ្វើនូវស្រដីមួយអន្លើនូវព្រាហ្មណ៍នោះ តុម្ហេ រីអ្នកទាំង-ឡាយ ចូរឃាត់អញថា ទេវ បពិត្រអើយ ! រីប្រេងសូម្បី គឺអម្ចាស់ផឹក ចូរអម្ចាស់កុំស្រដីឡើយ ។ ឃរំ វិចារេត្វា មហាសត្តោ រត្តបដិ ឆិភាសេត្វា សត្តមេ ទ្វារកោដ្ឋកេ បុរិសេ ឋបេត្វា វត្តមញ្ចកេ ឆិបដ្ឋិ ។ រីព្រះបរមពោធិសត្វ អ្នកពិចារណានូវ

ប្រការអម្បាលនោះ ហើយក៏ស្លៀកនូវសំពត់ប្រាល អ្នកដេកនៅគ្រែស្លឹក ឈើញ្ញដ៏ទីបង្អស់ក្នុងក្លោងទ្វារជាគំរប់៧ជាន់នោះហោង ។ រីអាចារ្យកេវដ្ដ-ព្រាហ្មណ៍ឈរនៅញ្ញដ៏ទ្វារជាប្រថមទាំងឡាយ ក៏ដណ្ដឹងរកព្រះមហោ-សថនោះថា ហៃចៅអ្នកប្រាជ្ញអើយ ! អ្នកនៅឯណា? ។ លំដាប់នោះ រីមនុស្សម្នាមហាជនផងទាំងឡាយ សឹងប្រាយប្រាប់ព្រាហ្មណ៍នោះថា ម្នាលព្រាហ្មណ៍អើយ ! ព្រះស្ដេចឯងកុំធ្វើបទិនូវស័ព្ទខ្លាំងពេក ស្អកនឹង មិនបានចូលទៅឡើយ ម្ល៉ោះហើយសៀមកុំស្រដីមកដល់ថ្ងៃនេះ រីប្រេង សូម្បីតែចៅអ្នកប្រាជ្ញតែងផឹករីព្រះស្ដេងដើម្បីនឹងធ្វើនូវស័ព្ទនោះខ្លាំងដូច្នោះ នោះមិនបានចូលទៅឡើយ ។ រីទ្វារសំណល់លែងនោះក្ដី ក៏មហាជនផង សឹងស្រដីនឹងព្រាហ្មណ៍នោះដូច្នោះហោង ។ អាចារ្យកេវដ្ដព្រាហ្មណ៍កន្លង នូវទ្វារជាគំរប់៧ជាន់នោះ ទៅកាន់សំណាក់នៃចៅអ្នកប្រាជ្ញនោះហើយ ។ រីចៅមហោសថអ្នកប្រាជ្ញសំដែងនូវអាការជាទីងស្រដីអង្កាល ។ បើដូច្នោះ កូវអស់មនុស្សម្នាមហាជនផងទាំងឡាយ ក៏សឹងឃាត់ពោធិសត្វនោះថា ទេវ បពិត្រអម្ចាស់អើយ ! តុម្ហេ រីអម្ចាស់ មា កាជយិត្ថ កុំស្រដី ខ្លាំងពេក រីប្រេងសូម្បីអម្ចាស់ផឹក អម្ចាស់ស្រដីធ្វើអ្វី? ឥមិនា ទុដ្ឋ-ព្រាហ្មណេន សទ្ធឹ មួយអន្លើនឹងព្រាហ្មណ៍កំណាចនេះឡើយ ។ រី-អាចារ្យកេវដ្ដព្រាហ្មណ៍នោះ ទៅកាន់សំណាក់នៃចៅមហោសថអ្នកប្រាជ្ញ មិនទាន់អង្គុយឡើយ មិនបាននូវកំពលដើម្បីនឹងអាស្រ័យនូវហានឈរ

ឡើយ ហើយគេបង្ហាញនូវការជឿគេជាដើម ដែលជាន់លើសាច់គោ ទឹកនោះ ឈរនៅសង្កាល់ បើដូច្នោះក្ដី អ្នកមួយរមិលមើលនូវព្រាហ្មណ៍នោះ អ្នកមួយហែកក្អែកឲ្យ ឯកោ អ្នកមួយ កមុកាំ ឧក្ខិបិ កំញាក់មុខនូវចិញ្ចើម ឯកោ អ្នកមួយ អាកាឌ្ឍយិ កំពាញកាបង្ហ្វរំ នូវម្រាមដៃឲ្យបង្ហាញព្រាហ្មណ៍នោះហើយ រីអាចារ្យគេវដ្ដៈព្រាហ្មណ៍ យល់នូវអំពើនៃអ្នកផងគេធ្វើដូច្នោះហើយ ក៏ស្ងៀមនៅមិនស្រដីអ្វីដល់មួយម៉ាត់ឡើយ ហើយថា ហៃចៅមហោសថអ្នកប្រាជ្ញអើយ យើងនឹងលាអ្នកទៅ កាលណាបើដូច្នោះក្ដី អ្នកផងថា ម្នាលព្រាហ្មណ៍កំណាច ព្រះស្ដេចឯងកុំធ្វើនូវសំពួខាំងពេកឡើយ ស្អែកនេះហើយយើងកាច់នូវធ្មេញនៃអ្នកហោង រីអាចារ្យគេវដ្ដព្រាហ្មណ៍ ឮនូវពាក្យនៃអ្នកផងនោះហើយ សឹងភិតភ័យញ័រជើងញ័រដៃក្រពេក ប្រែបញ្ចេញមករមិលមើលទៅអស់អ្នកទាំងនោះ ៗ ឮដំណាលនោះ អស់អ្នកផងទាំងឡាយដោះឡើងទំនេ ៗ មានដៃកាន់បន្ទះឫស្សីវាយគ្រវីខ្លួន ខ្លះចាប់កបង្អោនផង ខ្លះគប់ខ្លះដាល់ ៗ អាចារ្យគេវដ្ដព្រាហ្មណ៍ភិតភ័យតក្កមា មម្នាត់ចេញទៅទបមាបីដូចម្រឹគរួចចេញពីមាត់រាជសីហ៍នោះឯង ហើយទៅកាន់ព្រះរាជដំណាក់ហោង ៗ រីឯព្រះបាទវិទេហរាជសោក ទ្រង់ព្រះចិន្តាពិចារណាថា ថ្ងៃនេះ អញនៅមានសំពួនឹងបានដឹងបានឮពត៌មានអំពីមហោសថបុត្រនៃអញហើយក្រេកអរ ទោះយោបពាក្យអ្វី ៗ គប្បីមានដំណឹងហោង

ឥឡូវនេះ អ្នកប្រាជ្ញទាំងពីរ ទំនងអត់យកចិត្តគ្នាទៅវិញទៅមកឬ ម្ដេចហ៎ ? រីអាចារ្យគោវិន្ទព្រាហ្មណ៍រត់ឡើងទៅដល់ព្រះរាជមន្ទីរស្ដេច ហើយក្រាបថ្វាយបង្គំអង្គុយឰដ៏ឋានមួយសមគួរនឹងអាត្មា ។ ស្ដេចយល់អាចារ្យគោវិន្ទ-ព្រាហ្មណ៍មកដល់ហើយ ក៏ស្ដេចដណ្ដឹងនូវអាការសន្ទនាសមគួររវាងបណ្ឌិតអ្នកប្រាជ្ញ ហើយពោលនូវគាថានេះ ដូច្នេះថា :

កចន្នុ គោវិន្ទ មហោសធេន
សមាគមោ អាសិ តទិង្ឃ ព្រូហិ
កច្ចិ តេ បដិនិជ្ឈតោ
កច្ចិ តុដ្ឋោ មហោសធោតិ ។

ហៃអាចារ្យគោវិន្ទព្រាហ្មណ៍ អ្នកបានគប់ប្រសប់សន្ទនានូវធម៌មួយអន្លើនូវអ្នកប្រាជ្ញនោះ ថាម្ដេចព្រះស្ដែន ចូរព្រះស្ដែនប្រាប់នូវហេតុនោះមក រីចៅមហោសថ នូវអាចារ្យឯង បានយកចិត្តគ្នាទៅវិញទៅមកឬទេ ?

ឰដ៏កាលនោះ រីអាចារ្យគោវិន្ទព្រាហ្មណ៍ ក្រាបថ្វាយបង្គំប្រណម្យទូលថា បពិត្រមហារាជក្សត្រថ្លៃប្រសើរអើយ អញខ្ញុំបានទៅដល់មហោ-សថហើយព្រះអង្គ រីចៅមហោសថនោះ មិនមែនជាអ្នកប្រាជ្ញឡើយ ជាអ្នកឥតធម៌សប្បុរសក្រៃពេក អាចារ្យគោវិន្ទព្រាហ្មណ៍ក្រាបទូលនូវគាថាដូច្នេះ :

អចរិយវេទោ បុរិសោ ជនិន្ទ

អសម្មោទកោ ថទ្ធោ អសព្ភិរូបោ

យថា មូគោ ច ពធិរោ ច

ន កិញ្ចិត្ថមភិភាសថាតិ ។

បពិត្រមហារាជក្សត្រប្រសើរអើយ រីមហោសថនោះ ជាពជអា· មាត្យនៃព្រះអង្គ មានសុភាពនោះអគ្គីជាអ្នកមានសប្បុរសឡើយ យល់អញខ្ញុំទៅហើយឥតត្រេកអរ ជាអ្នករបឹងរឹងរូស មានកំណើតនោះ មិនមែនជាអ្នកប្រាជ្ញឡើយ អញខ្ញុំចូលទៅកាន់ ឥតបានស្រដីសួរនូវគាថអ្វីមួយនឹងអញខ្ញុំឡើយ ធ្វើហាក់ដូចគេថ្លង់ល្ងង់គហោង ។

រីឯព្រះបាទវិទេហរាជ ស្ដេចស្ដាប់ពាក្យអាចារ្យកេវដ្ដព្រាហ្មណ៍ក្រាបទូលដូច្នោះហើយ មានព្រះកក្រ្តសួតស្ងប់សញ្ចប់នៅពុំសប្បាយហើយ មានព្រះបន្ទូលបង្គាប់ប្រើអាមាត្យ ឲ្យប្រដាប់ប្រដាគ្រឿងបណ្ណាការនូវស្បៀងនាំទៅដាក់ឲ្យអាចារ្យកេវដ្ដព្រាហ្មណ៍នៅឯដំណាក់ ហើយឲ្យដំ·ណើរអាចារ្យកេវដ្ដព្រាហ្មណ៍ទៅហោង ក្រោយពីអាចារ្យកេវដ្ដព្រាហ្មណ៍ទៅនោះ ស្ដេចទ្រង់ព្រះចិន្ដាពិចារណាថា ហេតុអ្វីមហោសថបុត្រនៃអញ មិនមកសួរទូលសំណេះសំណាល បណ្ដាលមេត្រីស្រដីមួយអន្ទើនឹងអាចារ្យកេវដ្ដព្រាហ្មណ៍នោះ តើជាហេតុម្ដេច នេះសមមហោសថយល់អាចារ្យកេវដ្ដព្រាហ្មណ៍ចូលមករិះគិតការនេះ អនាគត ភ័យសមេះដ៏មាន

ទៅឯមុខមិនទេឡើយ រីគំនិតឯណាមួយ បើមហោសថគិតៈហើយកម្រអ្នក
ឯណាមួយនឹងបានដឹងបានខយល់នោះក្រៃពេក រីសេចក្ដីលោកិយលោកា
គឺមហោសថសឹងដឹងអស់ឥតកំបាំងឡើយ ពោះយោបខ្លួនអញនឹងមាន
ភ័យញ័រវេទនាក្ដី ស្ដេចឯណាមួយក៏នៅបង់ស្រុក លុះកណ្ដាប់ដៃសត្រូវក្ដី
ក៏សឹងតែមហោសថបុត្រនៃអញដឹងហោង ។ ពោះយោបីអាចារ្យកេវដ្ដ-
ព្រាហ្មណ៍មកឥឡូវនេះក្ដី សមមហោសថដឹងនូវគំនិតព្រាហ្មណ៍នោះ ដ្បិត
មកឥឡូវនេះ មិនជាប្រយោជន៍ ជាមិត្តឡើយ សមមកប្រលោមនូវបញ្ច-
កាមគុណ នឹងនាំយកអញទៅកាន់នគរឯនាយ រីអនាគតទៅ សមភ័យ
នឹងព្រាហ្មណ៍នេះមិនទេឡើយ ស្ដេចទ្រង់ព្រះចិន្ដានូវអាថប្រស្នាប្រការ
អម្បាលនោះហើយ ស្ដេចភីតភ័យញ័រជើងញ័រដៃក្រៃពេក ស្ដេចឲ្យហៅ
អាចារ្យទាំង ៤ មកដល់ហើយ ស្ដេចដណ្ដឹងអាចារ្យសេនកថា ម្នាលអា-
ចារ្យសេនកអើយ រីយើងនឹងទៅកាន់នគរឧត្តរបញ្ចាល នឹងនាំយកព្រះ
រាជបុត្រីនៃព្រះបាទចុលនីព្រហ្មទត្តមកនោះ ព្រះស្ដេចចូលចិត្តឬទេ ? ។
អាចារ្យសេនកស្ដាប់ហើយទូលថា ម.ហារាជ បពិត្រមហារាជក្សត្រថ្លៃ
ប្រសើរអើយ មហាក្សត្រមានព្រះបន្ទូលម្ដេចដូច្នេះ រីស្រីសួស្ដីនឹងមកដល់
ព្រះអង្គហើយ មិនគួរគប្បីទៅបង្អង់ឡើយ ឧបមាបីដូចបង្អែមចូលក្នុងមាត់
ហើយ ម្ដេចឡើយនឹងខ្ជាក់ចេញវិញ ។ រីព្រះបាទចុលនីព្រហ្មទត្តរាជ
អាចមានបំណងនឹងចង់ថ្វាយព្រះរាជបុត្រី ដ៏ទ្រង់នូវរូបនោះឧត្តម ផ្សំជា

ព្រះអគ្គមហេសីនៃព្រះអង្គនោះ ដ្បិតអស់ស្ដេចទាំងសកលជម្ពូទ្វីបនេះ សឹងជាចំណុះនៃព្រះបាទចុលនី នៅខាងតែព្រះអង្គឯង សេសលល់ពុំជាចំណុះ ដ៏ជាស្ដេចឯករាជធំស្មើនឹងស្ដេចចុលនី ហេតុនោះឈេង ទើបយកព្រះរាជបុត្រី គឺនាងបញ្ចាលចន្ទីនឹងថ្វាយជាព្រះអគ្គមហេសីទេពីនៃព្រះអង្គ ដ្បិតមានតែព្រះអង្គឯង ឥតអ្នកឯណានឹងស្មើឡើយ រីឯយើងខ្ញុំសោត នឹងបាននូវគ្រឿងប្រដាប់ទំនើប គឺសំពត់នូវអាវ ដោយនូវបុណ្យសក្ការព្រះបារមីអម្ចាស់ហោង ។ ទើបព្រះបាទវិទេហរាជ មានព្រះបន្ទូលដណ្ដឹងអាចារ្យទាំង ៣ រីអាចារ្យទាំង ៣ សឹងទូលស្របដូចពាក្យអាចារ្យសេនកនោះហោង ។ ស្ដេចស្ដាប់ពាក្យអ្នកប្រាជ្ញ ៤ ទូលនូវប្រការអម្បាលនោះហើយ មានព្រះហឫទ័យត្រេកអរនឹងអាចារ្យទាំង ៤ ស្រេចហើយ ស្ដេចឲ្យយករង្វាន់ទៅជូនអាចារ្យកេវដ្ដព្រាហ្មណ៍នោះមួយសាក្រៃលែងមុននោះហោង ។ លំដាប់នោះ រីពោធិសត្វអ្នកដឹងនូវអាចារ្យវិលទៅដូច្នោះហើយ អ្នកដោះឡើងស្រង់ទឹកអប់ត្រឡប់និទៅនូវគន្ធពិដោរ គឺនាងអមរាប្រដាប់ប្រដាប្រពៃស្រេចហើយនៃ ព្រះអង្គសោយនូវភោជនាហារគ្រាកាលផ្សេង ១ ស្រេច ប្រដាប់អាត្មាលីលាឡើងទៅដល់ព្រះរាជមន្ទីរស្ដេច ក្រាបថ្វាយបង្គំអង្គុយពួងហានមួយសមគួរទំនឹងអាត្មា ។ ព្រះបាទវិទេហរាជ យល់ពោធិសត្វមកដល់ហើយ ស្ដេចទ្រង់ព្រះចិន្ដាថា រីមហោសថបុត្រនៃអញនេះ មានប្រាជ្ញានឹងគេអ្នកប្រាជ្ញឯណានឹងផ្ទឹមឥត

ស្មើឡើយ អាចិសេចក្ដី អតីត-អនាគត បច្ចុប្បន្ននេះក្ដី សឹងមហោសថ អ្នកប្រាជ្ញអាចដឹងអស់ឥតកំបាំងឡើយ រីដំណើរអញនឹងទៅគួរក្ដីពុំគួរក្ដី កំមហោសថបានគិតហើយ ។ ព្រះមហាក្សត្រ ស្ដេចទ្រង់ព្រះចិន្ដានូវប្រការអម្បាលនោះហើយ ពុំមានព្រះបន្ទូលដូចព្រះតំរិះនោះឡើយ ហេតុតែលោភនូវចំណង់តណ្ហាច្រើន ហើយកើតជាវង្វេងភ្លេចភ្លាំងស្មារតីមកបន្ទូលនឹងពោធិសត្វនូវគាថា ដូច្នេះ :

ឆន្នម្ហិ ឯកាវ មតិ សមេតិ
យេ បណ្ឌិតា ឧត្តមភូរិបញ្ញា
យានំ អយានំ អថវាបិ ឋានំ
មហោសថ ត្វំបិ មតឹ ករោហិ ៗ

ម្នាលបាមហោសថអើយ ! រីឧបាយបំណងនៃយើងទាំង ៦ នាក់នេះ សឹងចូលនូវគំនិតគ្នាស្រេចហើយ តោះយោបីអាចារ្យកេវដ្ដព្រាហ្មណ៍ក្ដី អញក្ដី អ្នកប្រាជ្ញទាំង ៤ ក្ដី ឧបមាបីដូចស្ទឹង សឹងហូរទៅកាន់យមុនានទីនាយហោង តោះយោបីមានអ្នកប្រាជ្ញឯណា ភូរិបញ្ញា មានប្រាជ្ញាឧត្ដម រីអ្នកប្រាជ្ញនោះចូលមកស្រដីនូវដំណើរគួរទៅ មិនគួរទៅក្ដី ទៅមានហេតុដូចម្ដេច ។ ក្ដី រីឧបាយនេះ មិនគួរនៅចង់ឡើយ ។

ព្រះពោធិសត្វ ស្ដាប់ព្រះបន្ទូលហើយគិតថា ស្ដេចនេះលោភឮដ៏កាមគុណពេក ហេតុតែកាន់ជឿយកពាក្យនៃអាចារ្យទាំង ៤ ជាអ្នកកំឡៅអន្ធពាលវង្វេង យកខុសជាគាប់ៗជាខុសវិញ បើដូច្នោះ អញនឹង

សំដែងទោសនៅដំណើរស្តេចទឹងទៅនោះ ទើបស្តេចក្រឡាប់វិញហោង ពោធិសត្វគិតដូច្នោះហើយ ក៏ទូលនូវគាថាបួនបទ ដូច្នេះថា:

ជាតាសិ ខោ រាជ មហានុភាវេ
មហាកុលោ ចុលនីព្រហ្មទត្ត
រាជា ច តំ ឥច្ឆតិ មារណត្ថំ
មិគំ យថា ឱកចរេន លុទ្ធោ ។
យថាបិ មច្ឆោ ពលិសំ
វង្កំ មំសេន ឆាទិតំ
អាមគិទ្ធោ ន ជានាតិ
មច្ឆោ មរណមត្តនោ ។
ឯវមេវ តុវំ រាជ
ចុលនេយ្យស្ស ធីតរំ
កាមគិទ្ធោ ន ជានាសិ
មច្ឆោ មរណមត្តនោ ។
សចេ គច្ឆសិ បញ្ចាលំ
ខិប្បមត្តំ ជហេស្សសិ
មិគំ បន្ថានុពន្ធំវ
មហន្តំ ភយមេស្សតិ ។

( នៅមានត )

ខ្មែរអក្សរសាស្ត្រ

អក្សរសាស្ត្រខ្មែរ ខ្មែរគួរថែថួន
ឲ្យបានខ្ជាប់ខ្ជួន គង់វង់គង់មត់ ។
ព្រោះអក្សរជាតិ គោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ ។
ប.ព.

## ពាក្យខ្មែរប្រែពីបរទេស

## ដោយគណៈកម្មការជាតិនៃការសិក្សា ផ្នែកអក្សរ " ក "

(តមក)

— I —

| | | | |
|---|---|---|---|
| Impuberté | (n.f.) | អវយបត្ត | (ព.ច្ប.) ។ |
| Inceste | (n.m.) | ការស្មន់ | (ព.ច្ប.) ។ |
| Incestueux | (adj.) | ដែលស្មន់ | (ព.ច្ប.) ។ |
| Incestueux | (n.m.) | អ្នកស្មន់ | (ព.ច្ប.) ។ |
| Incapacité de la femme mariée | | អសមត្ថភាពនៃស្ត្រីមានប្តី | (ព.ច្ប.) ។ |
| Inexécution des devoirs imposés par la loi | | ការល្មើសចំពោះករណីយកិច្ច ដែលច្បាប់បង្គំ | (ព.ច្ប.) ។ |
| Infidèle | (adj.) | អស្មោះភក្តិ | (ព.ច្ប.) ។ |
| Infidèlité de lafemme | | អស្មោះភក្តិនៃស្ត្រី(១) | (ព.ច្ប.) ។ |
| Interdire | | ឃាត់ (ព.ច្ប.) គឺដកហូតពីជនម្នាក់ នូវសិទ្ធិគ្រប់គ្រង និងសិទ្ធិចាត់ចែងសម្បត្តិខ្លួនដោយសេរី ។ | |

១– បើតាមយោបល់ខ្ញុំ គួរប្រែថា: អស្មោះភក្តិនៃស្ត្រីជាភរិយា ឬ នៃភរិយា ។

| | |
|---|---|
| Interdit civil | ជនត្រូវឃាត់ខាងបវេណី (ព.ច្បា.) ។ |
| Interdiction civile | គំហាត់ខាងបវេណី (ព.ច្បា.) ។ |
| Interdit pénal | ជនត្រូវឃាត់ខាងអាជ្ញា (ព.ច្បា.) ។ |
| Interdiction pénale | គំហាត់ខាងអាជ្ញា (ព.ច្បា.) ។ |
| Interdiction légale | គំហាត់ខាងនីត្យានុកូល (ព.ច្បា.) ។ |

— M —

| | |
|---|---|
| Le mariage civil est prouvé par l'acte de mariage | អាពាហ៍ពិពាហ៍បវេណី មានភស្តុតាងដោយលិខិតអាពាហ៍ពិពាហ៍ (ពច្បា) ។ |
| Mariage du 1er degré | អាពាហ៍ពិពាហ៍ថ្នាក់ទី ១ (ពច្បា) ។ |
| Membre de la Famille Royale | ព្រះរាជវង្សានុវង្ស ។ |
| Motif légitime | ហេតុសមរម្យ (ពច្បា) ។ |
| Modifier un texte | កែប្រែអត្ថបទ (ពច្បា) : កែប្រែអត្ថបទ គឺលុបអត្ថបទចាស់ ហើយយកអត្ថបទថ្មីមកជំនួសវិញ ។ |
| Modification d'un texte | ការកែប្រែអត្ថបទ (ពច្បា) ។ |
| Muet (n.m.) | មនុស្សគ ។ |
| Muet (adj.) | គ ។ |
| Mutisme (n.m.) | ភាពគ (ពច្បា) ។ |
| Mariage du 2ème degré | អាពាហ៍ពិពាហ៍ថ្នាក់ទី ២ (ពច្បា) ។ |
| Mariage dissous | អាពាហ៍ពិពាហ៍ដែលរលាយ (ពច្បា) ។ |
| Ministre de la minorité ethnique | រដ្ឋមន្ត្រីខែអប្បភាគជាតិពន្ធុ ។ |

— N —

| | |
|---|---|
| Nullités absolues des mariages civils | មោឃភាពដាច់ខាតនៃអាពាហ៍ពិពាហ៍បវេណី (ពច្បា) ។ |

| | |
|---|---|
| Nullités relatives des mariages civils | មោឃភាពមិនដាច់ខាត នៃអាពាហ៍ពិពាហ៍បវេណី ( ពប្ប ) ។ |
| Nul (adj.) | មោឃៈ ។ |

— O —

| | |
|---|---|
| Obstacles au mariage | ឧបស័គ្គចំពោះអាពាហ៍ពិពាហ៍ ។ |

— P —

| | |
|---|---|
| Paraphrase (n.f.) | បរប្របយោគ ។ ( ត្រូវអានថា : ប៉ៈ-រ៉ៈ-) |
| Paralytique (n.m.) | មនុស្សរវិន ។ |
| Paralytique (adj.) | រវិន ។ |
| Paralysie (n.f.) | ភាពរវិន ។ |
| Personnes du sang royal | ព្រះរាជវង្សានុវង្ស ។ |
| Prouve du mariage civil | ភស្តុតាងនៃអាពាហ៍ពិពាហ៍បវេណី (ពប្ប) ។ |
| Prodigue (n.m.) | មនុស្សកញ្ជះកញ្ជាយ ។ |
| Prodigue (adj.) | កញ្ជះកញ្ជាយ ។ |
| Prodigalité excessive | ភាពកញ្ជះកញ្ជាយហួសប្រមាណ ( ពប្ប ) ។ |
| Prohiber le mariage | អាយ័តមិនឲ្យរៀបអាពាហ៍ពិពាហ៍ (ពប្ប) ។ |
| Prohibition (n.f.) | ការអាយ័តមិនឲ្យរៀបអាពាហ៍ពិពាហ៍(ពប្ប)។ |
| Priorité de diriger la famille | អាទិភាពខាងដឹកនាំគ្រួសារ ( ពប្ប ) ។ |
| Prouver (v.t.) | ( ជូន ) ភស្តុតាង ( ពប្ប ) ។ |
| Puissance paternelle | អំណាចមេបា ( ពប្ប ) ។ |
| Puissance maritale | អំណាចស្វាមី ( ពប្ប ) ។ |

*(នៅមានត)*

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហា ចាំង - ទាត់ រៀបរៀង

(តមក)

---

អតិភ្ញ    គុ. ដែលប្រសើរកន្ទង ដែលខ្ពស់កន្ទង ។

អតិសំរម្ភ    ប៉ុ. ទោសៈក្រៃលែង ។

អតិសំរុទ្ធ    គុ. ដែលលិចលង់ ដែលលង់ក្រៃពេក ។

អតិសំគព្ទ    ប៉ុ សំឡេងតក្រៃលែង ។

អតិសក្ត    គុ. ដែលជាប់ក្រៃលែង ។

អតិសក្តិ    ស្ត្រី. សេចក្តីស្និទស្នំក្រៃលែង ។

អតិសក្តិមន្ត គុ. ដែលមានសេចក្តីស្និទស្នំក្រៃលែង ។

អតិសខិ    ប៉ុ. សំឡាញ់ក្រៃលែង សំឡាញ់ប្រសើរ ។

អតិសំកដ    នប៉ុ សេចក្តីអន្តរាយក្រៃលែង ។

អតិសំកល្ប    ប៉ុ. សេចក្តីតម្រិះក្រៃលែង តម្រិះយល់ត្រូវក្រៃលែង ។

អតិសំក្រុទ្ធ    គុ. ដែលក្រោធខ្លាំងក្រៃលែង ។

អតិសំចយ    ប៉ុ. កិរិយាសន្សំទុកក្រៃលែង ។

អតិសត្តុត គុ. ដែលគោះពព្រៃលែង ។

អតិត្វរមៃ ក្រិ.វិ. ដោយឆាប់រហ័ស ។

អតិសទ្រី ធាតុ. អង្គុយក្រៃពេក ស្ងាប់ ។

អតិសទយ គុ. ដែលមានសេចក្តីអាណិតកន្លង ។

អតិសទ្ទុឝ គុ. ដែលដូចគ្នាក្រៃលែង ។

អតិសំតត គុ. ដែលជាប់គ្នាក្រៃលែង ដែលជាប់គ្នារនឹក ។

អតិសំធា ធាតុ. ទ្រទ្រង់ព្រមក្រៃលែង ប្រវ័ញ្ចន៍ បញ្ឆោត បោក ។

*អតិសំធិត* គុ ដែលបោកប្រាសហើយ ។

អតិសំធាន នបុំ. ប្រវ័ញ្ចន៍ កិរិយាបញ្ឆោត ។

អតិសន្ធេយ គុ. ដែលគប្បីផ្ទាប់គ្នាក្រៃលែង ដែលគប្បីព្រមព្រៀងគ្នាក្រៃលែង ។

អតិសំនិធាន នបុំ. ទីជិតក្រៃលែង ។

អតិសមបិ គុ. ដែលអាចក្រៃលែង ។

អតិសមីបតា ស្រី. ភាពនៃទីជិតក្រៃលែង ។

អតិសមុត្រុទ្ធ គុ. ដែលខ្លាំងក្រៃលែង (សំឡេង) ។

អតិសំពាធ គុ. ដែលចង្អៀតក្រៃលែង ។

អតិសំភ្រម បុំ. កិរិយារំភើបចិត្តក្រៃពេក កិរិយាញាប់ញ័រចិត្តក្រៃពេក ។

អតិសរស គុ. ដែលប្រកបដោយរសក្រៃលែង ។

អតិសគ៌ គុ. ប្រទាន កិរិយាឲ្យ ។ *អតិសជ៌ន* នបុំ ប្រទាន កិរិយាឲ្យ ។

អតិសប៌ណា នបុំ. កិរិយាកម្រើកក្រៃលែង (ទារកនៅក្នុងគភ៌)។

អតិសរិ គុ. ដែលសព្វគ្រប់ក្រៃលែង ដែលប្រសើរ ។

អតិសរិគង្គម ក្រិ វិ. ប្រកបដោយសេចក្តីចង្អៀតក្រៃលែង ។

អតិសហសា ក្រិ. វិ ដោយរហ័សកន្ទង ។

អតិសំវត្សរ គុ. ដែលអស់ឆ្នាំក្រៃលែង ។

អតិសាធ្វស នបុំ. កិរិយាខ្លាចក្រៃលែង ។

អតិសាយម៍ ក្រិ.វិ. ល្ងាចក្រៃពេក ។

អតិសារ បុំ. រោគរាកអាចម៍ ។

អតិសាហស នបុំ. សាហ័សក្រៃលែង កិរិយាបៀតបៀនក្រៃលែង ។

*អតិសាហសិក* គុ ដែលប្រកបដោយសាហ័សក្រៃលែង ។

(នៅមានត)

# រឿងល្បើកទ្យាហ្វុងតែន (La Fontaine)

លោក ដេង-ង្វើន ប្រែរៀបរៀង

## ១– ក្អែកនិងកញ្ជ្រោង

នាយក្អែកពាំសាច់ប្រហុកមួយដុំ ទំលើមែកក្តា ។

នាយកញ្ជ្រោងធុំក្លិនប្រហុក ក៏មានវាចាទៅកាន់នាយក្អែកដូច្នេះថា៖

" ជំរាបសួរ លោកនាយក្អែក ! រូបលោកនាយស្អាតអ្វីម៉្លេះទេ បើតាមខ្ញុំបាទយល់ លោកនាយល្អហើយសមផង ខ្ញុំបាទមិនកុហកទេ ប្រសិនបើសូរសៀងលោកនាយពីរោះថែមទៀតផង នោះលោកនាយប្រាកដជាបក្សីវិសេសជាងសកុណាទាំងអស់ក្នុងព្រៃនេះ" ។

សំដីសរសើរប៉ុណ្ណេះ មិនទាន់ធ្វើឲ្យក្អែកសប្បាយអស់ពីពោះនៅឡើយ ដើម្បីបង្ហាញនូវសូរសៀងដ៏ពីរោះនោះ ក្អែកក៏ហាមាត់យ៉ាងធំទឹងស្រែក ឯប្រហុកជ្រុះធ្លាក់មកដី ។

កញ្ជ្រោងពាំផុប ហើយពោលថា: "លោកនាយ ! សូមលោកជ្រាបពីថ្ងៃនេះទៅថា: អ្នកបញ្ជោរតែងចិញ្ចឹមជីវិតដោយសារតែអ្នកស្តាប់ដំបូន្មានប៉ុណ្ណោះ សូមជូនទឹងប្រហុកមួយដុំនេះចុះ" ។

ក្អែកខ្មាសហើយ តប់ប្រមល់ពេក ទើបស្បថថា ពីថ្ងៃនេះទៅ អញឈប់ស្តាប់អាណាឲ្យសោះ ប៉ុន្តែស្បថឥតអំពើ ព្រោះហួសហើយ ។

## ២- កណ្ដុរក្រុងនិងកណ្ដុរស្រែ

ក្នុងកាលកន្លងទៅហើយ កណ្ដុរក្រុងទៅអញ្ជើញមិត្រកណ្ដុរស្រែ មកស៊ីលៀងភោជនាហារយ៉ាងឆ្ងាញ់ឯគេហដ្ឋានអាត្មា ។ ម្ហូបអាហាររៀបដាក់លើតុមានកម្រាលយ៉ាងវិចិត្រ ។ ភោជនាហារសឹងបរិបូណ៌ឥតខ្វះអ្វី ទាល់តែមានមនុស្សមកធ្វើឲ្យរំខាន ក្នុងពេលដែលមិត្រទាំងពីរកំពុងបរិភោគ ។ គេឮតែសូរមនុស្សដើរនៅក្បែរទ្វារបន្ទប់ កណ្ដុរក្រុងស្ទុះរត់ទៅលបមើល កណ្ដុរស្រែក៏ស្ទុះក្រោកតាម ។ លុះបាត់ឮសូរ មិត្រទាំងពីរត្រឡប់មកកន្លែងវិញ ហើយកណ្ដុរក្រុងមានវាចាថា: ត្រូវយើងបង្ហើយភត្តកិច្ចយើង ។

កណ្ដុរស្រែឆ្លើយដូច្នេះថា: ណ្ហើយប៉ុណ្ណឹងចុះ គួរសមហើយ ស្អែកសូមអញ្ជើញមិត្រទៅផ្ទះខ្ញុំម្ដងវិញ ចំណែកភោជនាហារមិនបានជាថ្លៃថ្នូរ ដូចរបស់មិត្រទេ តែគ្មានអ្វីមកធ្វើឲ្យខ្ញុំដាច់បាយទឹក ខ្ញុំទទួលទានតាមអំពើចិត្ត ដូច្នេះ សូមលាហើយ ការសប្បាយលាយដោយភ័យ ។

## ៣- ហ៊ឹងបង់ធំស្មើនឹងគោ

ហ៊ឹងមួយឃើញគោ មើលទៅដូចជាមានរូបកាយធំល្អ ចំណែកខ្លួនមិនធំប៉ុន្មានហួសពីស៊ុតមាន់ ក៏មានចិត្តលោភចង់ចំកោង បំប៉ោង ខំធ្វើឲ្យរីកធំ មានទំហំប៉ុនគោ ហើយនិយាយនឹងប្អូនស្រីថា: ចូរហាងឯង

មើលអញឲ្យច្បាស់ បើប៉ុនល្មមហើយ ប្រាប់អញ បើមិនទាន់ល្មម អញនឹងបំប៉ោងតទៅទៀត ។ – ប្អូនស្រីប្រាប់ថា "មិនទាន់ប៉ុនទេ" ។

– ហាងមើលអញមើល ចុះប៉ុននេះ ? ។ – ហ្នឹងក៏មិនទាន់ប៉ុនស្មើ ។
– មើលទៀតមើល ចុះប៉ុណ្ណេះ ? ។ – បងឯងគ្មានប្រហែលបន្តិចសោះ ។

សត្វគួបគម្រក់ ខំបំប៉ោងទាល់តែផ្ទុះខ្លួនផង ។

ក្នុងលោកសន្និវាសនេះ មានមនុស្សច្រើនដែលមិនមានសេចក្ដីសន្ដោស ជាតិអ្នកធ្វើការរកស៊ីធម្មតា ចង់ធ្វើឫកដូចអ្នកអង្គម្ចាស់ ជាតិស្ដេចតូចៗ ចង់មានពលខ្លួនឲ្យស្មើនគរមហាអំណាច ជាតិអ្នកអង្គម្ចាស់តូចតាច ចង់បានឲ្យមានអ្នកបំរើជាន់ខ្ពស់ដូចស្ដេចផែនដីនឹងព្រះអង្គម្ចាស់ ។

## ៤– កញ្ជ្រោងនឹងក្រសារ

ថ្ងៃមួយ កញ្ជ្រោងរៀបចំភោជនាហារ ហើយអញ្ជើញសំឡាញ់ក្រសារមកបរិភោគ ម្ហូបក៏តិចហើយមិនគ្រប់គ្រាន់ សម្លសុទ្ធតែរាវៗ ព្រោះកញ្ជ្រោងគាត់ស៊ីតិច ។ សម្លនេះសោតទៀតដាក់តែក្នុងចានទៀប ។ ក្រសារចំពុះវែងស៊ីពុំបានមួយមាត់ឬមួយដុំតូចសោះ ។ ចំណែកកញ្ជ្រោងសត្វចិល លិទ្ធតែម្នាក់ឯងអស់មួយរំពេចក្នុងពេលនោះ ។

ដើម្បីសងសឹក អំពីរឿងបញ្ឆោតនេះ មិនកន្លងទៅបានប៉ុន្មានថ្ងៃ ក្រសារក៏អញ្ជើញកញ្ជ្រោងមកស៊ីលៀងឯទីលំនៅរបស់ខ្លួនម្ដងវិញ ។

កញ្ជ្រោងមានវាចាថា " ពេញចិត្តណាស់ ព្រោះមិត្រកក្តិមានការខ្ញុំមិនតឹងតែងទេ " ។

ដល់ពេលកំណត់: កញ្ជ្រោងត្រាច់ទៅឯផ្ទះក្រសារជាសំឡាញ់ ហើយសំដែងការគួរសមកក់ពាក់យ៉ាងក្រៃលែង ចំណែកម្ហូបក៏ឆ្អិនស្រេចៈ កំពុងតែស្រួលខ្លួនស៊ីអាហារបានផង កញ្ជ្រោងរកពីណាខានមិនមក ជុំក្លិនសាច់ចំញ្ញាំយ៉ាងឈ្ងុយ គាត់រីករាយសប្បាយគិតស្មានថា ម្ហូបនេះអស់ក្រឡាហើយ ។

ដើម្បីធ្វើឲ្យកញ្ជ្រោងពិបាក ស៊ីមិនកើតវិញ ក្រសារដាក់សម្លក្នុងថូមួយកវែង ហើយតូចល្មមតែកគាត់អាចលូកចុះ អាខ្វិលកញ្ជ្រោងមាត់ធំហួស លូកស៊ីពុំកើត ក្រសារលូកចឹកស៊ីតែម្នាក់ឯងធ្វើព្រងើយ ។

កញ្ជ្រោងអត់អាហារត្រឡប់មកផ្ទះវិញ ខ្មាសក្រសារទម្លាក់កន្ទុយដាក់ស្លឹកត្រចៀកចុះ មុខស្លុត ។

អ្នកបញ្ឆោតគេទាំងឡាយ ! ចូរប្រយ័ត្នខ្លួន មានថ្ងៃណា អ្នកមុខជានឹងបានសេចក្ដីអាមាសមុខ ដូចរឿងនេះមិនខានឡើយ ។

## ៥- សត្វលាពីរ

លាទាំងពីរធ្វើដំណើរជាមួយគ្នា លាមួយ គេផ្ទុកសុទ្ធតែចម្បើង ។ លាមួយទៀត គេផ្ទុកសុទ្ធតែប្រាក់សាច់ លានេះបុកក្រអឺត ឆ្ងើកបាខនាំរបស់ប្រសើរលើខ្លួន មិនចង់ឲ្យអ្នកណាជួយសម្រាលខ្លួនសោះ ពារដើរ

លើកជើងខ្ពស់ៗ បោះជំហានវែងៗ ហើយអង្រួនប្រាក់ក្ដឹងៗ បែបសង្ហា លុះហោះមកដល់ ជង្រុកគេត្រូវការប្រាក់ គេស្ទុះទៅរកលាដឹកប្រាក់ ចាប់បង្ហៀរហើយបញ្ឈប់ ។ លានេះខំប្រឹងការពារប្រាក់ ស្រាប់តែដឹងថាខ្លួនត្រូវពីរបីព្រនង់ ហើយឈឺក្រៃល ក៏ថ្ងូរដកដង្ហើមធំ ហើយពោលថា: «កាលពេលដើម តើគេសន្យាថា ឲ្យហោរពាយអញដូច្នេះឬ? ចំណែកលាខាងណោះដែលដើរពីក្រោយ គេរួចពីគ្រោះថ្នាក់ ចុះចង្រៃអ្វីតែអញក៏ប៉ះទៅលើហោរពាយស្ទើរចង់ដាច់» ។

លាទីពីរឆ្លើយតបថា: «ម្នាលសំឡាញ់! មិនមែនស្រួលប៉ុន្មានទេដែលមានការងារខ្ពង់ខ្ពស់នោះ បើបងឯងបញ្ចុះតែម្ចាស់ដូចខ្ញុំ នោះបងឯងធ្វើម្ដេចនឹងបានឈឺខ្លួន» ។

## ៦_ មេមាន់ស៊ុតមាស

អ្នកកំណាញ់ត្រឡប់ជាខាតដើម មកពីចង់ចំណេញច្រើនពេក ។

មេមាន់មួយ ក្នុងមួយថ្ងៃពងចេញមាសមួយដុំៗ អ្នកម្ចាស់មាន់ស្មានថាក្នុងពោះមាន់មានសុទ្ធតែមាសក៏សម្លាប់មាន់ ពុះរកមើលហើយឃើញដូចជាមាន់ធម្មតា: នេះគឺបំផ្លាញតែខ្លួនឯង នាំខាតផលរបស់ដ៏ប្រសើរ ។

រឿងនេះ ជាដំបូន្មានដល់អ្នកកំណាញ់ ដែលត្រឡប់ទៅជាអ្នកកំសត់វិញ ទាល់ព្រឹក ទាល់ល្ងាច ទោះបីដល់ពេលខ្លួនជិតស្លាប់ក៏ដោយ ព្រោះតែចង់បានជ្រុលពេក ។

សុភាសិតខ្មែរ: ''លោកហួសខ្នាត នាំខាតដើម'' ។

## ៧– ចចកនឹងក្រសារ

សត្វចចកស៊ីចំណីឆាក្រក់ណាស់ ។

មានចចកមួយ រកបានរំពាមួយយ៉ាងធំ អរពេក ស៊ីឡេះឡប់ មិនប្រយ័ត្ន ស្លាក់ឆ្អឹងមួយដុំធំនៅទទឹងបំពង់ក ឈឺស្ទើរចង់ងាប់ ។ ទេសកាលអ្វី ហេតុតែបុណ្យចចក ដែលហាមាត់ស្រែកមិនរួចសោះនោះ លោតែមានក្រសារមួយដើរមកក្បែរ ចចកធ្វើសញ្ញា ក្រសាររត់មកភ្លាម ចាប់ធ្វើការមួយរំពេច មិនឲ្យយឺតយូរ ចឹកទាញឆ្អឹងមកក្រៅបាន រួចទារថ្លៃឈ្នួល ។ ចចកឆ្លើយថា: ''អ្វី? ថ្លៃឈ្នួល? យើសើចផងឆាសំឡាញ់! អ្វី! ឲ្យអាឯងដកកចេញផុតពីមាត់អញមកក្រៅប៉ុណ្ណឹង នៅមិនទាន់ល្មមចិត្តទៀតឬ? ចៀសចេញទៅ អាមិនស្គាល់គុណគេ កុំឲ្យអញខាំបំបែកក្បាលថែមទៀត ទុកជាគ្រាន់បើហើយ! ។

## ៨– សត្វលាយកស្បែកសិង្ហមកគ្របលើខ្លួន

លាមួយយកស្បែកសិង្ហមករុំជិតខ្លួន ធ្វើឲ្យគេខ្លាចក្នុងទីដំបន់នោះ ។ គួរដែរឬ សត្វពោលមៀតគ្មានអំណាចអ្វីសោះ ចេះធ្វើឲ្យគេញាប់ញ័រភិតភ័យអស់ទាំងស្រុក ។

ចៃដន្យអ្វីហេតុតែកម្ម ស្រាប់តែចុងស្លឹកត្រចៀកលេចចេញមកបន្តិច នាំឲ្យអ្នកទាំងអស់គ្នាស្គាល់បានថាជាសត្វលា   បាត់ភ្ញាក់ផ្អើលទៅវិញ ស្រាប់តែដំបងលេចឡើងព្រោងព្រាត សំពងសត្វលាទារុណយ៉ាងខ្លាំង ។ អ្នកខ្លះដែលមិនយល់ នឹកឆ្ងល់ថា ហេតុម្ដេចក៏គេហ៊ានដេញសិង្ហឲ្យរត់ជ្រកក្នុងពេងត្បាល់កិនបានដោយងាយ ។

## ៩– សិង្ហនឹងកណ្ដុរប្រែង

កណ្ដុរប្រែងមួយចេញពីរូងមក បែបល្ងីល្ងើខ្លាំង ស្រាប់តែដើរទៅនៅក្បែរជើងសត្វសិង្ហមួយ ។ ក្នុងពេលនោះ ស្ដេចសត្វចតុបាទសំដែងចិត្តមេត្តា ក៏ទុកជីវិតឲ្យដល់កណ្ដុរនោះ ។

ការល្អមិនដែលសាបសូន្យឥតផលឡើយ ។

ក្រោយមក មិនយូរប៉ុន្មាន សិង្ហដើរទៅជាប់ក្នុងសំណាញ់អន្ទាក់ព្រាន ទោះបីខំប្រឹងស្រែកគ្រាំពេញព្រៃយ៉ាងណា ក៏សិង្ហមិនអាចដោះខ្លួនឲ្យរួចពីអន្ទាក់បាន កណ្ដុរមិនភ្លេចគុណក៏រត់មកក្ខាម ហើយកកេរសំណាញ់ដាច់ខ្ទេចខ្ទីអស់ ។

ខន្តី នឹងពេលដ៏យូរ ប្រសើរជាងកម្លាំងនឹងការក្ដុងក្ដាំង ។

រឿងខាងលើនេះ បានគតិពីរយ៉ាង:

សុភាសិតខ្មែរ
- ១– អំពើល្អមិនដែលសាបសូន្យឥតផល;
- ២– ការតូងតាងមិនស្មើការអំណត់ ។

## ១០- ព្រាបនិងស្រមោច

មានព្រាបមួយចុះមកផឹកទឹកនៅមាត់ត្រពាំង ទឹកយ៉ាងថ្លា កុំពុងតែខន ផឹក ពេលក្រឡេកទៅឃើញស្រមោចមួយអណ្តែតរវើក ៗ នាកណ្តាល ត្រពាំងនោះ ហើយកំពុងតែខំប្រឹងហែលខ្វៃ ៗ ដើម្បីមករកខាង ប៉ុន្តែ ឥតអំពើ ។

ខណៈនោះ ព្រាបពេលមានចិត្តល្អ ក៏ចឹកកូនមែកឈើមួយទងបោះ ទៅ មែកឈើតូចនេះ ដូចជាកោះជួយយ៉ាងធំដល់ស្រមោច ៗ វារឡើងទំ លើមែកឈើបានរួចរស់ជីវិត ។

ក្រោយនោះបន្តិចមក មានព្រានដើងទេម្នាក់ មករកបាញ់សត្វ ស្ពាយស្នាមួយនៅស្មា ដើរលប ៗ បំរុងបាញ់ព្រាបខាងលើនេះ គេមាន ចិត្តសប្បាយទុកជាមុនថា មុខជាសើមមាត់ហើយជាន់នេះ ។

តែដល់កំពុងតែយឹតស្នាយ៉ាងតឹង ហើយដំរង់ជាស្រេច រៀបនឹងដំ- ឡោះតែ ស្រមោចខាំកែងប៉ាច់ ព្រានភ្ញាក់ជើងងាកក្បាលមើល ព្រាបឮ សូរហើរគេចទៅបាត់ សត្វដែលព្រានបានគិតទុកក៏ហើរទៅជាមួយផង អស់រលីង ។

## ១១- ឆ្នាំងដីនិងឆ្នាំងដែក

ឆ្នាំងដែកនិយាយបបួលឆ្នាំងដី ឲ្យធ្វើដំណើរទៅស្រុកឆ្ងាយលេងជា

មួយគ្នា ៗ ឆ្នាំងដីនិយាយអង្វរសូមទោសថា: ខ្ញុំនៅតែផ្ទះ ក្បែរជើងក្រានបានហើយ ព្រោះខ្ញុំគ្រាន់តែប៉ះនឹងវត្ថុបន្តិចមុខជាអន្តរាយមិនខាន ចំណែកអ្នក ស្បែករឹងជាងខ្ញុំ ៗ យល់ថា អ្នកឯងគ្មានអ្វីជាគ្រឿងឧបសគ្គឡើយ ៗ ឆ្នាំងដែកតបថា: យើងជាអ្នកការពារ អ្នកមិនត្រូវព្រួយឡើយ ប្រសិនបើ តាមផ្លូវ ណាជាមានវត្ថុអ្វីរឹង ៗ បំរុងមកទង្គិចអ្នកឯង យើងធានាស្ទុះទៅឈរកណ្តាល ហើយយើងទង្គិចតែ ១ ប៉ុង អ្នកឯងនឹងរួចខ្លួនប្រាកដ ៗ

ពាក្យប៉ុណ្ណោះនេះ ធ្វើឲ្យឆ្នាំងដីទុកចិត្តអស់ពីពោះ ហើយយល់ព្រមតាម ៗ ឆ្នាំងដែកឈរទន្ទឹមឆ្នាំងដី រួចអ្នកទាំងពីរចេញដំណើរល្គិចល្គប់ ៗ រមៀលទង្គិចគ្នាទៅវិញទៅមក គ្រាន់តែប៉ះនឹងវត្ថុមួយ ឆ្នាំងដីស្រែកថ្ងូរ មិនបានទាំង ១ រយដំហានផង ឆ្នាំងដីបែកខ្ទេច ដោយប៉ះទង្គិចតែនឹងគ្នាឯង មិនបាច់ចាំព្រួយខ្លាចក្រែងអ្នកដទៃមកទង្គិចឬធ្វើឲ្យបែកឡើយ ៗ

ត្រូវយើងកល់គ្នាដើរចូលតែនឹងមនុស្សមានភាពស្មើគ្នា បើពុំដូច្នោះទេ ខ្លាចក្រែងយើងនឹងដូចជាវាសនាឆ្នាំងដីខាងលើនេះ ៗ

## ១២– ចចកនិងកូនចៀម

កូនចៀមមួយចុះទៅផឹកទឹក នៅមាត់ស្ទឹងមួយទឹកយ៉ាងថ្លា ៗ ចចក

ដែលអត់អាហារយូរថ្ងៃហើយ ដើរស្វែងរកចំណី មកប្រទះកូនចៀមនៅទីនោះដែរ ។ ចចកក៏ញៀញកូនចៀមថា "អាណាបើកអំណាចឲ្យអាឯងមកកកូរទឹកអញល្អក់ដូច្នេះ អាឯងព្រហើនឥតពិចារណា អាត្រូវទោសឥឡូវមិនខានឡើយ" ។

កូនចៀមឆ្លើយថា: សូមទ្រង់ព្រះមេត្តាប្រោស សូមកុំមានព្រះហឫ-ទ័យខ្ញាល់អ្វីឡើយ សូមទ្រង់ពិនិត្យសំគាល់មើលសិន ដែលទូលព្រះបង្គំចូលមកផឹកនេះ គឺនៅឆ្ងាយពីទ្រង់ប្រមាណ ២០ ជំហាន ហើយក្រោមទឹកផង ហេតុដូច្នេះ ទូលព្រះបង្គំធ្វើដូចម្តេច នឹងអាចធ្វើឲ្យល្អក់ទឹកទ្រង់បាន ។

ចចកស្រែកគំហកថែមទៀតថា: អាឯងហ្នឹងធ្វើឲ្យល្អក់! ហើយម្យ៉ាងទៀត ពីឆ្នាំទៅ អាឯងនិយាយដើមអញ ។ ជឹងច្បាស់ ។

កូនចៀមឆ្លើយទៀតថា: ទូលព្រះបង្គំនិយាយដើមដូចម្តេចកើត បើទូលព្រះបង្គំមិនទាន់តាំងកើតផង សព្វថ្ងៃទូលព្រះបង្គំនៅបៅដោះម្តាយនៅឡើយ ។

– បើមិនមែនអាឯង ក៏បងអាឯងដែរ! ។

– ទូលព្រះបង្គំគ្មានបងទេ ។

– បងប្អូនសាច់ញាតិអាឯង គ្មានប្ដី អាឯងពល់គ្នានេះគ្មានបេះ សន្ដោសអញម្ដងសោះទេ អ្នកគង្វាលអាឯងក្ដី ឆ្កែអាឯងក្ដី ពេលនេះត្រូវតែអញសងសឹកវិញ ៗ

គ្រាន់តែពោលប៉ុណ្ណោះហើយ ចចកមិនបាច់ជជែកវែកតទៅទៀតឲ្យយូរការ ព្រោះឃ្លានពេក ក៏ស្ទុះខាំពាំកូនចៀមយកចូលព្រៃបរិភោគ ៗ

( នៅមានត )

គតិលោកយោគគតិធម៌ ពួកមនុស្សគ្រប់ពណ៌
ត្រូវគោរព ត្រូវរៀនឲ្យយល់ បេះឲ្យសព្វ កាយ
កប់មួយមួយ ពុំប្រសើរ ៗ ទាំងពីរនេះប្រៀបដូច
កង់បត្រ ត្រូវវិលប្រទាក់ កុំឲ្យស្មើរ កុំឲ្យមួយរត់
មួយត្រឹមដើរ ឈ្មោះថាដំណើរមិនប្រពៃ ៗ

ផេង - ថ្មីរ

# រឿងសាមកុក

## កំណាទី ៤៩

ឧកញ៉ាវិបុលរាជសេនា ញ៉ុ-គាង ប្រែរៀបរៀង

( តមក )

---

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
នឹងចេះទាយយកលចំណាន
ទាំងមានសន្តានស្នេហាជាតិ

យូរ - អ៊ុន

ចូឆូក៏ត្រឡប់ចូលបន្ទាយ ហើយនិយាយនឹងខៅឆូថា ម៉ាឈៀវនេះដឹងថាអ្នកឯងជាទាហានខ្លា បានជាខ្លាចថ្វីដៃអ្នក ខៅឆូឆ្លើយថា ព្រឹកស្អែកនេះខ្ញុំបាទនឹងសុំយកអាសាចេញទៅតយុទ្ធគ្នានឹងម៉ាឈៀវ ហើយនឹងចាប់យកខ្លួនម៉ាឈៀវឱ្យបាន ចូឆូឆ្លើយថា ឯម៉ាឈៀវនោះគេក៏ខ្លាំងពូកែណាស់ដែរ អ្នកកុំអាលមើលងាយប្រមាថឡើយ ខៅឆូថា បើខ្ញុំបាទចាប់ខ្លួនម៉ាឈៀវមិនបានទេ ស៊ូតែស្លាប់កណ្តាលរណរង្គសង្គ្រាម ហើយខៅឆូក៏ឱ្យបំរើកាន់សំបុត្រទៅដល់ម៉ាឈៀវទាំងកណ្តាលយប់នោះថា ព្រឹកនេះឱ្យម៉ាឈៀវចេញមកច្បាំងនឹងយើងកុំខាន ម៉ាឈៀវឃើញសំបុត្រខឹងខ្លាំងណាស់ និយាយថា ខៅឆូនេះបរបាព្រហើនមើលងាយយើង

ពេកណាស់ ចុះដៃកយ៉ាងណាៈទៅវេលាព្រឹកនេះ យើងនឹងលើកទាហាន ចេញទៅចាប់ខ្លួនវាឲ្យត្រាតែបាន ។

លុះដល់ពេលព្រឹក ទៅឆ្កូនឹងម៉ាឈៀវក៏លើកទាហានចេញពីបន្ទាយ រៀងខ្លួន កាលចេញទៅប្រទះមុខគ្នាហើយ ម៉ាឈៀវក៏បរសេះទៅបញ្ឈរ ពីមុខទាហានត្រើលំពែងហើយស្រែកថា នរណាជាទាហានខ្លាំងនោះ ឲ្យ ចេញខ្លួនមកល្បងចុះដៃគ្នា ចូឆូបញ្ឈរសេះនៅមុខទាហាន និយាយថា ម៉ាឈៀវនេះមានកម្លាំងច្រើនណាស់ ប្រហែលគ្នានឹងលីប៉ោ ចូឆូនិយាយ មិនទាន់ផុតមាត់ ទៅឆ្កូក៏បរសេះចូលទៅតយុទ្ធគ្នានឹងម៉ាឈៀវ ។ នឹងទៅ ឆ្កូតយុទ្ធគ្នាបាន ១០០ ក្បួន មិនបានទទួលជ័យជាំងគ្នាទាំងសងខាង តែសេះ អស់កម្លាំង នាំគ្នាថយសំរាកក្រោយទាហានហើយផ្លាស់យកសេះថ្មី នាំ គ្នាចេញតយុទ្ធម្ដងទៀតបាន ១០ ក្បួន ។

កាលទៅឆ្កូចេញទៅច្បាំងនឹងម៉ាឈៀវជាលើកទី ២ នោះ មានពោ សោបណ្ដាលឡើងពេញខ្លួន ដោះគ្រោះចេញអស់ពីខ្លួនប្រយុទ្ធគ្នា ពួក ទាហានទាំងសងខាងឃើញនាយមានកម្លាំងស្មើគ្នា មិនមានទទួលខ្សោយ ជាងគ្នាដូច្នោះ ក៏នាំគ្នាស្រែកហោកញ្ជ្រៀវអឹងកង ទាំងសងខាង ឯម៉ាឈៀវ នឹងទៅឆ្កូតស៊ូគ្នាទៀតបាន ៣០ ក្បួន ទៅឆ្កូមានកំហឹងពេញកម្លាំង លើក ដាវឡើងកាប់សំដៅខ្លួនម៉ាឈៀវ ។ គេចខុសគាស់ទាត់ដោយចុងលំពែង ហើយចាក់តម្រង់ដើមទ្រូងទៅឆ្កូ ។ ពេលដាវចេញពីដៃចាប់កន្ទ្រាក់យក

លំពែងពីម៉ាឈៀវ ។ ទីងខៅជូក៏ដណ្ដើមលំពែងគ្នា ទាល់តែបាក់ជាពីរកំ-ណាត់ ម្នាក់បាន ១ កំណាត់ ក៏វាយគ្នាជាប់ទៅវិញទៅមកលើខ្នងសេះ ចូឆូឃើញដូច្នោះខ្លាចក្រែងខៅជូខុសការ ទីងម៉ាឈៀវក៏ប្រើហែហ៊ូអៀន ហោហុង ២ នាយជិះសេះចូលទៅជួយខៅជូ ។

ប៉ាំងតេកទីងម៉ាតាយឃើញដូច្នោះ ក៏បរសេះចូលទៅជួយម៉ាឈៀវ ទាហានទាំងសងខាងនេះក៏ប្រឡូកជាប្រឡំបល់ទៅវិញទៅមក ពួកទា-ហានម៉ាឈៀវបាញ់ធ្នូត្រូវខ្នងខៅជូជាប់ព្រួញពីរផ្លែ ទាហានចូឆូឃើញដូច្នោះក៏បាក់ទ័ពត្រឡប់ចូលបន្ទាយ ម៉ាឈៀវបានការក៏បរពលចូលប្រ-កាប់ប្រហាក់ទៅដល់ក្បែរបន្ទាយ ចូឆូឲ្យបិទទ្វារបន្ទាយជិតមិនឲ្យចេញច្បាំងតាំងតែបាត់ការយាមល្បាតជាមាំមួន ម៉ាឈៀវក៏លើកទាហានចូលបន្ទាយវិញ ហើយនិយាយនឹងហ័នស៊ុយថា តាំងពីបានធ្វើការច្បាំងគ្នាមកដល់ថ្ងៃនេះ មិនដែលឃើញនរណាចូលច្បាំងចេញកម្លាំងទោះសោទ្រនឹងគង់អាចដូចជាខៅជូនេះគ្មាន កិរិយាក៏ដូចខ្លា សមដូចពាក្យដែលឮនោះមែន ។

ខណៈនោះ ចូឆូឃើញថា ម៉ាឈៀវខ្លាំងពូកែណាស់ ទើបប្រើស៊ុ-ឡុងនឹងជូឡុងឃុំទាហានលើកទៅតាំងបន្ទាយនៅក្រោយទិសខាងលិចជាទ័ពសន្ទប់ម៉ាឈៀវទុក ហើយឡើងឈរនៅលើទីដ៏ខ្ពស់ ក្រឡេកទៅឃើញម៉ាឈៀវនឹងទាហានសេះនៅមុខបន្ទាយប្រមាណ ៣០០ ទើបដោះ

ម្លួកពីក្បាលបោះចោលទៅហើយថា ម៉ាឈៀវនេះបើកមិនស្ទាប់ទឹងដៃ យើងទេ សំណើះតទៅខាងមុខគង់ធ្វើអន្តរាយដល់យើងវិញជាមិនខាន សពាយើងនេះមិនដឹងជាកំណត់ថាទឹងធ្លាក់ទៅនៅត្រង់ទីណា ហៃហ៊ូអៀន បានឮប្អូនថាដូច្នោះ ក៏ខឹងខ្វឹងណាស់ឆ្លើយថា ខ្ញុំបាទនឹងអាសាចេញកំ-ចាត់ម៉ាឈៀវចេញឲ្យបាន ប្អូនឃាត់ដូចម្ដេចក៏មិនស្ដាប់ ស្រាប់ដែលឡើងជិះសេះឃុំនាំទាហានចេញពីបន្ទាយទៅ ប្អូនឃើញហៃហ៊ូអៀនកំពុងខឹងណាស់ ក្រែងថួសការទឹងម៉ាឈៀវ ក៏លើកទាហានតាមទៅពីក្រោយ ម៉ាឈៀវឃើញហៃហ៊ូអៀនលើកទាហានចេញមកដូច្នោះ ក៏បរសេះចូលទៅនឹងតស៊ូគ្នានឹងហៃហ៊ូអៀន ទទួលក្រឡេកទៅឃើញទង់ទ័ពហ្វូងជោតមកជាសំគាល់ ក៏ដឹងថាប្អូនជាកង់ជូនលើកតាមមកទៀត ម៉ាឈៀវក៏មិនបានចូលតច្បាំងនឹងហៃហ៊ូអៀន ក៏លើកទាហានបរសេះគេចជម្រង់ទៅចំងទឹងចាប់ខ្លួនប្អូនវិញ ។

ប្អូនក្រឡេកឃើញដូច្នោះ ក៏ភ័យស្លុតស្មារតី ទាញបង្វៀរសេះរត់ត្រឡប់ទៅក្រោយ ទាហានទាំងពួងក៏បែកបាក់ព្រាត់ព្រាយគ្នា ម៉ាឈៀវឃើញបានការក៏ដេញទាហានចូលប្រកាប់ពីក្រោយ ស្រាប់តែមានទា-ហានម្នាក់មកប្រាប់ថា ឥឡូវប្អូនឲ្យទាហានលើកទៅតាំងបន្ទាយចាំខ្ទប់ពីក្រោយនៅត្រើយខាងលិច ម៉ាឈៀវឮដូច្នោះនឹងដេញឲ្យជ្រុលហួសទៅមិនបានរាំងក្រោយក៏ឲ្យទឹកក្រែងខ្លាច ទើបប្រមូលទាហានត្រឡប់

ចូលបន្ទាយវិញ ហើយប្រឹក្សានឹងហ័នស៊ុយថា ឥឡូវចូឆូឲ្យទាហានលើក ធ្ងន់ទៅក្រោយម្ខាង តាំងបន្ទាយសម្រាប់ចាំខ្ទប់ទ័ពយើង ៗ នឹងច្បាំងទាំងសងខាងក៏ឃើញថាលើសកម្លាំងណាស់នឹងច្បាំងម្តេចបាន នឹងគិតកែខប្រការម្តេចឲ្យស្រួល លីខាំទាហានហ័នស៊ុយឆ្លើយថា ដែលចូឆូធ្វើអាការគ្រានេះឃើញសម្បើមខ្លាំងណាស់ សូមឲ្យលោកគិតកេតុបាយជាមេត្រីនឹងគ្នាវិញ កុំធ្វើសង្គ្រាមតទៅឡើយ នាំគ្នាលើកទ័ពត្រឡប់ទៅសិន បើហួសទេសៈកាលៈវេលាណា សឹមគិតធ្វើការតទៅទៀត ។

ហ័នស៊ុយឮដូច្នោះ ក៏និយាយនឹងម៉ាឆៅថា ពាក្យដែលលីខាំនិយាយនេះក៏ឃើញថាជាការគួរស្តាប់ណាស់ ល្មមអ្នកនឹងអនុកូលតាមចុះ ម៉ាឆៅក៏នៅស្ងៀម អៀវឈើវហៅឈ្មួន ទាហានហ័នស៊ុយឆ្លើយថា ដែលលីខាំនិយាយនេះគួរណាស់ សូមឲ្យលោកធ្វើតាមចុះ ហ័នស៊ុយក៏តែងជាសំបុត្រហើយឲ្យអៀវឈើវកាន់ចូលទៅក្នុងបន្ទាយចូឆូ សេចក្តីថា យើងទាំងសងខាងនឹងច្បាំងគ្នាដូច្នេះមិនគួរទេ ព្រោះពេលនេះជាទេសៈកាលៈរងាណាស់ យើងទាំងសងខាងចូលជាមេត្រីនឹងគ្នា លើកទ័ពត្រឡប់ទៅវិញចុះ ។

ចូឆូឃើញសេចក្តីសំបុត្រដូច្នោះ ក៏និយាយនឹងអៀវឈើវថា អ្នកចូលត្រឡប់ទៅបន្ទាយប្រាប់នាយរបស់អ្នកចុះថា ព្រឹកស្អែកយើងនឹងតបសំបុត្រ ទៅវិញ អៀវឈើវក៏លាចូឆូទៅ ទីប្រឹក្សាទាំងពួងក៏សួរចូឆូថា ដែល

ទបពជនឹងតបសំបុត្រទៅវិញ នោះនឹងនិយាយដូចម្ដេច ចូឆូឆ្លើយថា ដែលយើងនិយាយនេះ ជាឧបាយក្នុងទទួលពាក្យតែមាត់ក្រៅទេ លុះព្រឹកឡើងទើបប្រើបំរើកាន់សំបុត្រចូលទៅក្នុងបន្ទាយហាន់ស៊ុយ សេចក្ដីថា ដែលអ្នកនឹងយើងមិនបានធ្វើសង្គ្រាមនឹងគ្នាតទៅនោះ យើងក៏ត្រូវចិត្តណាស់ វេលានេះយើងនឹងរៀបលើកទ័ពត្រឡប់ទៅវិញជាដាច់ពុំខាន ត្រូវបង្អង់បន្តិចទៅសិន រួចចូឆូក៏ប្រើមនុស្សឲ្យធ្វើស្ពានថែបដូចជានឹងនាំពលឆ្លងទៅ ប្រាថ្នានឹងឲ្យម៉ាឆៀវនឹងហាន់ស៊ុយជឿចិត្ត ។

ឯម៉ាឆៀវលុះឃើញសំបុត្រសេចក្ដីដូច្នោះ ក៏យាយនឹងហាន់ស៊ុយថា ដែលចូឆូឲ្យមានសំបុត្រទទួលពាក្យដូច្នោះក៏មែនហើយ តែថាយើងនឹងជឿទុកចិត្តជាប្រាកដមិនបានក្រែងវាបញ្ឆោតយើង សូមលោកចាត់ការឲ្យត្រៀមពលយោធាទុកសម្រាប់តទល់នឹងទ័ពមុខចូឆូ ខ្ញុំបាទនឹងចាត់ចែងទាហានទុកទទួលទ័ពបញ្ឆោតខួបពីក្រោយ ហាន់ស៊ុយយល់ឃើញត្រូវ ក៏ត្រួតត្រៀមពលទាហានទាំងពួងតាមពាក្យម៉ាឆៀវ ។

ចូឆូដឹងថា ហាន់ស៊ុយរក្សាទ័ពខាងគយមុខ ចូឆូអរណាស់និយាយថា ត្រូវនឹងឧបាយយើង ការរបស់យើងនឹងសម្រេចជាប្រាកដ លុះព្រឹកឡើងចូឆូក៏ឃុំនាំទាហានចេញទៅក្រៅបន្ទាយ ខាងទាហានហាន់ស៊ុយឃើញចូឆូលើកចេញមកក៏គិតថា ចូឆូនឹងលើកទ័ពទៅ មិនធ្លាប់ឃើញរូបចូឆូ ពួកទាហានទាំងអស់នោះក៏ប្រជ្រៀតគ្នាចេញទៅមើលក្រៅបន្ទាយ

ស្រែកប្រាប់គ្នាថា មកមើលចុះវើយគ្នាយើង ចុះបរសេះទៅមុខទាហាន ហើយស្រែកថា អញមានភ្នែកពីរ មាត់ ១ ច្រមុះ ១ ដូចខ្លួនរាល់គ្នាដូច្នោះ ដែរ មិនមែនមាត់ពីរ ភ្នែក ៤ ៦ តែជាប្លែកបន្តិចដោយមានអំណាចច្រើន គឺជាមនុស្សដែលមានប្រាជ្ញានិងសេចក្ដីគិត នរណាចង់មកមើលក៏មកចុះ ទាហានហ័នស៊ុយឮដូច្នោះក៏ភិតភ័យឈរមើលក្បួនខ្លួន ទើបចុះប្រើទា-ហានឲ្យទៅប្រាប់ហ័នស៊ុយថា មហាឧបរាជឲ្យអញ្ជើញអ្នកចេញទៅ សន្ទនាគ្នា ។

ហ័នស៊ុយឮដូច្នោះ ក៏បរសេះចេញមកក្រៅបន្ទាយ ចុះឃើញហ័ន-ស៊ុយចេញមកក៏ដោះគ្រោះចេញ ពាក់តែអាវតាមធម្មតាបរសេះចូលទៅ ទមគ្នានឹងសេះហ័នស៊ុយតែមួយទឹងមួយក៏គំនាប់គ្នាទៅវិញទៅមក ចុះ និយាយថា ខ្លួនអ្នកនឹងខ្ញុំក៏មិនមែនជាដទៃ បិតារបស់អ្នកខ្ញុំក៏បានគំនាប់រាប់ អានគ្នាថាជាមា ខ្លួនយើងទាំងពីរកាលនៅពីក្មេងក៏ជានាម៉ឺនធ្វើរាជការ នៅជាមួយគ្នា ជាមនុស្សត្រូវអធ្យាស្រ័យគ្នា ឥឡូវយើងបែកចាកគ្នាមកយូរ ហើយ ទើបនឹងមកប្រទះគ្នាគ្រានេះ អាយុអ្នកបានប៉ុន្មានហើយ ហ័ន-ស៊ុយឆ្លើយថា អាយុខ្ញុំបាន ៤០ ឆ្នាំហើយ ។

ចុះក៏ធ្វើជាយកដៃអង្អែលទ្រូងហើយថា យើងធ្វើរាជការនៅជាមួយ គ្នាកងស្រុកក្រុងក្ដាម ៗ សោះ ហោតែឃ្លាតចាកគ្នាមកដូច្នេះ ដូចជាមិន បានយូរប៉ុន្មានអាយុគន្លងទៅដល់ប៉ុណ្ណោះហើយ កាលណាស្រុកយើង

មិនកបពាបជាប្រក្រតី ដើម្បីឲ្យយើងទាំងពីរនឹងបានទៅជាសុខជាមួយគ្នាទៀត ហ៊ានស៊ុយនឹងប៊ួចនិយាយគ្នាក្នុងថ្ងៃនោះ នឹងបានប្រាប់ពីកិច្ចការសង្គ្រោមកំទេសនោះ អ្នកទាំងពីរក៏នាំគ្នាសើចពេះពោយជាមួយគ្នា លុះដល់សៀលម៉ោង៦ ហើយក៏គាំទាប់គ្នា ។ ចាហាននម្នាក់ក៏ចូលទៅប្រាប់ម៉ាឈៀវថា ឥឡូវហ៊ានស៊ុយចេញទៅនិយាយនឹងប៊ួចយូរណាស់ នឹងនិយាយពីកិច្ចការអ្វីក៏មិនយល់ច្បាស់ ។

ម៉ាឈៀវឮដូច្នោះក៏ទៅសួរហ៊ានស៊ុយថា លោកចេញទៅនិយាយអ្វីនឹងប៊ួចកណ្ដាលទីសង្គ្រោមក្នុងថ្ងៃនេះ ? ។ ហ៊ានស៊ុយឆ្លើយថា និយាយរំលឹកដល់រឿងពីដើម ដែលធ្លាប់ជួបធ្វើជាការជាមួយគ្នា ។ ម៉ាឈៀវសួរថា លោកមិនបានចរចាដោយកិច្ចការសង្គ្រោមទេឬ ? ។ ហ៊ានស៊ុយថា ប៊ួចមិនបានចរចាទេ ខ្ញុំឯងក៏មិនបាននិយាយដែរ ។ ម៉ាឈៀវមានសេចក្ដីសង្ស័យនៅតែស្ងៀម មិនបាននិយាយជាប្រការម្ដេច ក៏ត្រឡប់ទៅវិញ ។

កាលប៊ួចត្រឡប់ទៅដល់បន្ទាយ ក៏សួរកាសៀនថា ពីព្រឹកមិញយើងចេញទៅនិយាយការនឹងហ៊ានស៊ុយនោះ អ្នកដឹងយល់ឡៃបខាយរបស់យើងប្រការម្ដេចខ្លះឬទេ ? ។ កាសៀនថា ឡៃបខាយលោកដែលចេញទៅនិយាយនឹងហ៊ានស៊ុយនោះ ជាសេចក្ដីសំខាន់ល្អណាស់ តែថា

ម៉ាឈៀវនឹងហ៊ានស៊ុយនៅមិនទាន់មានសេចក្ដីសង្ស័យអ្វីនឹងគ្នាទេ ខ្ញុំបាទគិតថា បើជាធ្វើកលមួយយ៉ាងទៀត ប្រហែលជាកើតសង្ស័យនឹងគ្នាមិនខាន ។

ចុងសួរថា គំនិតរបស់អ្នកឯងនឹងគិតធ្វើប្រការម្ដេច ។ កាសៀងថា ខ្ញុំបាទគិតនឹងឲ្យយកក្រដាសទទេប្រកក្នុងស្រោម ហើយសរសេរការខ្នងជាអក្សរថែបរលុបកុំឲ្យមើលឃើញតួអក្សរច្បាស់ ឲ្យបំរើម្នាក់កាន់យកទៅឲ្យហ៊ានស៊ុយ ហើយឲ្យធ្វើជាថា នេះសំបុត្រជាការសម្ងាត់ បើម៉ាឈៀវដឹងគង់នឹងទៅមើល កាលណាហែកស្រោមយកមក ឃើញតែក្រដាសទទេក៏គង់នឹងសង្ស័យថា ហ៊ានស៊ុយលាក់សំបុត្រនោះ ហើយយកតែស្រោមនឹងក្រដាសទទេមកក្លែងឲ្យមើល មុខជាម៉ាឈៀវនឹងហ៊ានស៊ុយគង់នឹងមន្ទិលចិត្តគិតសង្ស័យនឹងគ្នាមិនខាន រួចអំពីនោះ សឹមយើងគិតប្រើមនុស្សឲ្យទៅចរចាបញ្ចុះបញ្ចូលយកខ្លួនហ៊ានស៊ុយ មកទុកជាពួកយើងវិញ មុខជានឹងកំចាត់ម៉ាឈៀវបានដោយងាយ ។

ចុងស្ដាប់យល់ត្រូវណាស់ ក៏ឲ្យយកក្រដាសមកប្រកស្រោម ហើយកាខ្នងស្រោមតាមសំដីកាសៀង ឲ្យបំរើម្នាក់កាន់យកទៅឲ្យហ៊ានស៊ុយក្នុងបន្ទាយ ។ លុះម៉ាឈៀវដឹង ទើបទៅសួរហ៊ានស៊ុយថា ចុងឲ្យសំ-បុត្រមកនិយាយការអ្វីខ្លះ ? ហ៊ានស៊ុយក៏ហុចសំបុត្រនោះទៅឲ្យម៉ាឈៀវមើល ។ ម៉ាឈៀវហែកស្រោមឃើញតែក្រដាសទទេគ្មានអក្សរ ក៏សួរ

ថា ហេតុម្តេចបានជាគ្មានអក្សរលោកយកសំបុត្រទៅលាក់ទុកឯណា ។ ហ៊ានស៊ុយឆ្លើយប្រាប់ថា សំបុត្រចូឆូឲ្យមកយ៉ាងនោះឯង យើងមិនទាន់ហែកស្រោមមើល ទទួលអ្នកមកដល់ ដែលមិនមានអក្សរយ៉ាងនេះប្រហែលចូឆូប្រទៀតលសំបុត្រនោះទុកឯណា ហើយយកក្រដាសទទេដាក់ជាជំនួសមកវិញ ។

មាំឈៀវថា លោកនិយាយយ៉ាងនោះ ខ្ញុំមិនឃើញសមសេចក្តីសោះ ព្រោះចូឆូជាមនុស្សមានតម្រិះប្រាជ្ញាមាំមួនណាស់ ដែលនឹងកេ្បចសំបុត្រនោះមិនមែនទេ ប្រហែលលោកចូលគំនិតទៅខាងចូឆូគិតនឹងប្រទូសក៏យខ្ញុំវិញទេដឹង បានជាឲ្យសំបុត្រសម្ងាត់ទៅមកកែគ្នាមិនឲ្យខ្ញុំឃើញផង ហើយក្លែងយកក្រដាសទទេមកឲ្យខ្ញុំមើល ។ ហ៊ានស៊ុយថា យើងមានសេចក្តីត្រង់សុចរិតណាស់ បើអ្នកនៅឆ្ងល់សង្ស័យនឹងយើងដូច្នេះ ពេលព្រឹកស្អែកយើងនឹងចេញទៅនិយាយនឹងចូឆូ ឲ្យអ្នកចាំមើលចុះ នឹងឃើញពិរុទ្ធយ៉ាងម្តេច ឲ្យអ្នកយកលំពែងចាក់យើងឲ្យធ្លាក់ពីលើសេះស្លាប់ចុះ ។ មាំឈៀវថា បើលោកសត្យត្រង់ធ្វើបានដូចថាមែន ខ្ញុំក៏អស់សង្ស័យ ។

លុះដល់ពេលព្រឹក ហ៊ានស៊ុយក៏នាំយៅឈួន លីខាំ លៀងហេងមាំគួន អៀវឈីវ នាយទាហាន ៥ នាក់នេះ ចេញពីបន្ទាយ ហ៊ានស៊ុយ

ប្រើទាហានចូលទៅហៅចូវផុសមុខបន្ទាយថា ហ័នស៊ិយឲ្យអញ្ជើញលោក ទៅចរចាគ្នានៅទីកណ្ដាលប្រជុំជន ។ ចូវពូវដូវបោះក៏ឲ្យចូហង់នាំទាហាន សេះ ៣០ ចេញទៅតំនាប់ហើយប្រាប់ថា មហាឧបកជឲ្យកំផាប់លោក ថា សុំបុត្រដែលឲ្យមកនោះ កុំឲ្យលោកបង្ហាញនរណាឲ្យដឹងខ្លួនខ្លាយ ទៅឡើយក្រែងខូចការដែលគិត ។ ចូហង់ប្រាប់ដូវបោះហើយ ក៏ត្រឡប់ ចូលទៅក្នុងបន្ទាយវិញ ។ ម៉ាឈៀវពូវដូវបោះក៏ប្រឡោតខឹង ទើបបរ សេះកាំលំពែងចេញទៅនឹងតក់ហ័នស៊ិយ ។ ទាហានហ័នស៊ិយជួយ ការពារបាន ហើយនាំហ័នហ៊ិយរត់ចូលបន្ទាយ ។ ហ័នស៊ិយក៏ស្រែក ឲ្យម៉ាឈៀវថា ក្មួយអើយអ្នកកុំបីធ្លស់សង្ស័យ ដែលយើងនឹងគិតប្រទូស- រ៉ាយនឹងអ្នកនោះមិនមែនទេ ។ ម៉ាឈៀវខឹងខ្លាំងណាស់មិនបានជឿសោះ ក៏បរសេះតម្រង់ចូលទៅក្នុងបន្ទាយ ។

ឯហ័នស៊ិយ ក៏ប្រឹក្សានឹងបណ្ដាពួកនាយទាហានទាំង ៤ នាក់ថា ឥឡូវនេះ ម៉ាឈៀវមានសេចក្ដីសង្ស័យសង្ស័យថា យើងត្រឡប់ទៅចូល ខាងចូវ តើយើងនឹងគិតប្រការម្ដេចទើបបានឲ្យគេអស់សង្ស័យ ។ អៀវ ឈើវឆ្លើយថា ធម្មតាជាមនុស្សមិនបានកើតខ្លាចអ្នកធំ ព្រោះហើនកាន់ខ្លួន ព្រោះមានថ្វីដៃប្រមាថមើលងាយលោកណាស់ បើនឹងធ្វើការតទៅកាល ណាឡើយនឹងឈ្នះចូវ ត្រូវការអ៊ីដែលលោកនឹងទៅចំណុះតូទក្រោង យើង នឹងត្រឡប់ចូលទៅខាងចូវវិញល្អជាង ទោះបីយ៉ាងណាក៏គង់នឹងទំនុក

បំរុងលោកឲ្យឡើងយសសក្តាបណ្ដាស័ក្តិទៅខាងមុខ ៗ ហ៊ានស៊ុយថា ខ្លួនយើងនឹងម៉ាថេងអាពុកម៉ាឈៀវជាមិត្តសំឡាញ់នឹងគ្នាមកពីដើម ដែលនឹងពោលសេចក្ដីសត្យសុចរិត ត្រឡប់ទៅចូលខាងចូចមកធ្វើប្រទូសរ៉ាយម៉ាឈៀវជាកូនរបស់មិត្រសំឡាញ់វិញនោះមិនគួរសោះ ៗ អៀវឈីវថា លោកខ្លាចក្រែងខូចសេចក្ដីសត្យដូច្នោះក៏គួរហើយ តែថាគ្រានេះមុខជានឹងកើតចលាចលដល់ខ្លួនហើយ នឹងមិនធ្វើក៏ត្រូវតែធ្វើ ៗ

ហ៊ានស៊ុយយល់ឃើញត្រូវផង ទើបនិយាយថា បើដូច្នោះនរណានឹងអាចនាំយកសេចក្ដីនេះទៅពន្យល់ឲ្យចូចដឹងបាន ៗ អៀវឈីវថា ខ្ញុំបាទនឹងសុំអាសាទៅផង ហ៊ានស៊ុយក៏តែងសំបុត្រមួយច្បាប់ថា "ខ្ញុំបាទហ៊ានស៊ុយ សុំគំនាប់មកដល់មហាឧបរាជ ព្រោះខ្ញុំបាទបានប្រមាទលើកទាហានដាក្បួនទ័ពមកតច្បាំងនឹងលោក នោះព្រោះគិតស្រាលសេចក្ដី មិនបានពិនិត្យពិចារណាឲ្យឃើញខុសត្រូវ ឥឡូវខ្ញុំបាទឃើញទោសខ្លួនហើយ ក៏លះបង់មិនគិតនឹងធ្វើសេចក្ដីប្រទូសរ៉ាយដល់លោកតទៅទៀត ទើបចូលមកសូមលន់តួទោសសូមគំនាប់លោកតាមប្រពៃណី សូមឲ្យលោកអត់ឱននូវទោសឲ្យខ្ញុំបាទចុះ" លុះតែងសំបុត្ររួចហើយ ក៏ឲ្យអៀវឈីវកាន់យកទៅជូនចូច ៗ ដឹងក្នុងសំបុត្រដូច្នោះ ក៏សោមនស្សត្រេកអរណាស់ថា ហ៊ានស៊ុយមានសេចក្ដីភក្ដីដល់យើងហើយ បើសម្រេចការហើយយើងនឹងតាំងឲ្យធ្វើជាចៅហ្វាយស្រុកសែលៀង ខ្លួនអ្នកឯងនឹងឲ្យធ្វើជាបាលរដ្ឋ

ពួកទាហានជាក់ជាប់មកយើងនឹងតាំងជប់លៀងតាមតូច-ធំ អ្នកឯងត្រូវវិលត្រឡប់ទៅប្រាប់ហ័នស៊ុយចុះថា ពេលយប់នេះ ឲ្យដុតភ្លើងឲ្យឆេះឡើងក្នុងបន្ទាយម៉ាឈៀវ យើងនឹងចូលទៅចាប់យកខ្លួនម៉ាឈៀវឲ្យបាន ។ អៀវឈីវគំនាប់ចូច្ចូហើយក៏លាថយមកវិញ ប្រាប់ពតិមាននោះឲ្យហ័នស៊ុយស្តាប់គ្រប់ប្រការ ។

ហ័នស៊ុយឮដូច្នោះ ក៏មានអំណរណាស់ ឲ្យទាហានជញ្ជូនទុសមកគរទុកក្រោយបន្ទាយជាច្រើន ហើយទើបប្រឹក្សានឹងនាយទាហានទាំង ៥ នាក់ថា ពេលយប់នេះយើងឲ្យរៀបតុលៀងអាហារ ឲ្យអញ្ជើញម៉ាឈៀវមកបរិភោគ បើបានឱកាសស្រួលហើយនឹងចាប់ខ្លួនសំឡាប់ចេញ ។ ខណៈកាលកំពុងប្រឹក្សាគ្នានោះ មានទាហានម៉ាឈៀវដឹងជំរួយថា ហ័នស៊ុយគិតនឹងប្រទូសរ៉ាយម៉ាឈៀវ ទាហាននោះក៏នាំយករឿងទៅប្រាប់ម៉ាឈៀវ ៗ ដឹងដូច្នោះ ក៏ស្រូតមកប្រញាប់ ឲ្យបាំងគេក ម៉ាតាយយុំទាហាន ៣០ នាក់ តាមការពារអន្ទពយពីក្រោយ ហើយក៏ដើរចូលទៅក្នុងបន្ទាយ ឃើញហ័នស៊ុយកំពុងនិយាយប្រឹក្សាគ្នាជាមួយនឹងនាយទាហាន ៥ នាក់ បានឮចុងសំដីថា ត្រូវប្រញាប់ធ្វើការនោះកុំបង្អង់ទុកឲ្យយូរឡើយ ម៉ាឈៀវក៏ដើរស្រូតដើងចូលទៅស្រែកដេរថា ម៉ែអាសត្រូវពាលតធ្វើអញហើយតើ ៗ នាយទាហានហ័នស៊ុយទាំង ៥ នាក់បានឮដូច្នោះ ក៏ស្ទុតស្ទាំងកាំងនឹងនៅទីនោះ ៗ ម៉ាឈៀវក៏ហូតគ្របកាប់

ហ៊ានស៊ុយ ៗ លើកជើងជើងត្រូវជើងដាច់ធ្លាក់ចុះ ។ ទាហានហ៊ានស៊ុយទាំង ៥ នាក់ក៏ហូតក្រប៊ីពល់គ្នា រត់ចូលមកតស៊ូនឹងម៉ាឈៀវ ៗ ក៏ថយចេញទៅក្រៅបន្ទាយ នាយទាហាន ៥ នាក់ក៏ដេញតាមទៅ ។ ម៉ាឈៀវទទួលតនឹងក្រប៊ី កាប់ត្រូវម៉ាអ៊ូនដួលចុះ ហើយចាក់ត្រូវលៀងហេងនឹងក្រប៊ីស្លាប់មួយរំពេច ហៅឈួន លីខាំ អៀវឈីទាំង៣នាក់ឃើញដូច្នោះនឹងតស៊ូជាមួយម៉ាឈៀវពុំបានក៏នាំគ្នារត់ ។ ម៉ាឈៀវក៏ត្រឡប់ដេញចូលទៅនឹងសម្លាប់ហ៊ានស៊ុយចេញ ទទួលពួកទាហាននាំយកខ្លួនហ៊ាន-ស៊ុយរត់រួចទៅបាន ហើយលបដុតភ្លើងឆេះឡើងខាងក្រោយបន្ទាយ ។ ទាហានម៉ាឈៀវនឹងទាហានហ៊ានស៊ុយ ក៏ចូលប្រកាប់ប្រចាក់គ្នាជាប្រួលប្របល់ ពេញទាំងបន្ទាយនឹងក្រៅបន្ទាយ ។

ប៉ាំងតេកនឹងម៉ាតាយ ក៏លើកទាហានតាមទៅទាន់ម៉ាឈៀវ ចូលជួយគ្នាតស៊ូទំលាយចេញពីក្នុងបន្ទាយមកវិញ ប្រទះនឹងពួកទាហានចូចូលើកមកពីទ្វៃថែមទៀត ក៏ចូលប្រឡូកគ្នាជា ៤ ផ្នែកសន្ធឹកសន្ធាប់ណាស់មិនបានដឹងថា ពួកឯងពួកគេ ប៉ាំងតេកនឹងម៉ាតាយក៏បែកព្រាត់គ្នាពីម៉ា-ឈៀវៗ ឃើញលើសកម្លាំងក៏ឡើងសេះនាំទាហាន ១០០ វាយទំលាយរត់ធ្លុងទៅដល់កណ្ដាលស្ពាន ទទួលក្លីស្ពានឡើងឃើញលីខាំលើកទាហានដេញតាមពីក្រោយ ម៉ាឈៀវក៏បរសេះវាមកតនឹងលីខាំ ។ ឃើញកម្លាំង

ខ្លួនទឹងតដោយម៉ាឈៀវពុំបាន កំញាក់សេះវេះរត់ថយទៅក្រោយ ម៉ា-ឈៀវក៏ដេញជិតពីក្រោយតាមទៅ ។

អ៊ីគឹមក៏លើកទាហានដេញតាមម៉ាឈៀវទៅទៀត ហើយបាញ់ទឹងធ្នូពីក្រោយ ម៉ាឈៀវឮសូរព្រួញគេពីក្រោយខ្លួនក៏ក្រាបចុះព្រួញនោះហួសទៅត្រូវលីខាំធ្លាក់ពីលើសេះស្លាប់ ម៉ាឈៀវឃើញដូច្នោះ ក៏ញាក់សេះវិលត្រឡប់ទៅតទឹងអ៊ីគឹម ។ ក៏ញាក់សេះវេះរត់ទៅ ម៉ាឈៀវលើកពលត្រឡប់ទៅឈរកណ្ដាលស្ពានវិញ ទាហានចូចូក៏លើកទៅស្កាត់ខាងដើមស្ពាន ទឹងចុងស្ពានទាំងសងខាង ចេះតែបាញ់ធ្នូចំរុះចូលទៅទាំងសងខាង ម៉ាឈៀវយកលំពែងគ្រវីទាត់ព្រួញខ្ទាតធ្លាក់ទៅក្នុងទឹកទាំងអស់គ្មានពាល់ត្រូវដល់ខ្លួនសោះ ហើយដេញទាហានឲ្យចូលប្រចាប់កងទ័ពចូចូទឹងឲ្យធ្លាយខាងដើមស្ពាន ទាហានមានតិចណាស់វាយទំ-លាយចេញមិនបាន លើសកម្លាំងក៏ត្រឡប់ថយក្រោយ ម៉ាឈៀវខឹងញ័រអស់ទាំងខ្លួនក៏ស្រែកដោយសំឡេងខ្លាំង ហើយបំផាយសេះទំលាយចេញទៅតែម្នាក់ឯង ទាហានចូចូក៏បើកផ្លូវឲ្យ ម៉ាឈៀវក៏ត្រឡប់វិលចូលទៅកណ្ដាលហ្វូងទាហាន ។ ក៏បាញ់ទឹងធ្នូត្រូវម៉ាឈៀវធ្លាក់ចុះទាហានចូចូក៏ស្ទុះស្រាវចូលទៅទឹងចាប់ខ្លួន ទទួលបាំងគេកឹងម៉ាតាយលើកពលវាយទំលាយចូលមកទាន់ ក៏ជួយគស្នើគ្នាជាចលាចល ហើយវាំងរាយកខ្លួនម៉ាឈៀវបាន ទាហានម្នាក់លោតចុះពីលើខ្នងសេះ

ឲ្យមាំឈៀវឡើងជិះលើខ្នង ហើយកាយចំណាយចេញពីកន្ទុំចំណោម
ទៅបាន ។

ឯក្ខធដីងថា មាំឈៀវរត់ទៅបានដូច្នោះ ក៏ឲ្យប្រកាសដល់ពួកទា
ហានទាំងពួងឲ្យស្រួតលើកគ្នាតាមទាំងយប់ថ្ងៃ បើនរណាយកក្បាលមាំ-
ឈៀវបានមកឲ្យយើង ។ នឹងឲ្យបំណាច់រង្វាន់មាសមួយពាន់ប្រាក់មួយ
ពាន់ បើចាប់ទាំងរស់បាននឹងតាំងឲ្យធ្វើជានាហ្មឺនធំ បណ្ដាពួកទាហាន
ដែលចង់បានគុណបំណាច់ ក៏នាំគ្នាស្រួតតាមទៅ ។ មាំឈៀវរត់ទៅ
គ្រានោះ មានពួកទាហានតិចណាស់ គឺមានតែបាំងគេក ១ មាតយ ១
នឹងកូនទាហានប្រមាណ ៣០ នាក់ នឹងរកនៅតស៊ូនឹងទ័ពច្ចធពុំបាន ក៏ចំ
តែស្រួតរត់រត់ទៅខាងទិសឯត្បូងស្រុកសែលៀង ។

ច្ចធលើកទ័ពដូនតាមទៅជាក្រោយ ដឹងថាមាំឈៀវរត់ហួសរួចទៅ
តាមមិនទាន់ហើយ ក៏លើកទ័ពវិលមកស្រុកទៀងអ៊ានវិញ ឈប់សម្រាក
ទាហាននៅរក្សាបួសដើងហ៊ានស៊ុយឲ្យជា ហើយច្ចធឃើញថាជាមនុស្ស
ពិការនឹងធ្វើសង្គ្រាមតទៅទៀតពុំបាន ក៏តាំងឲ្យធ្វើជាចៅហ្វាយស្រុកសែ
លៀង ឲ្យហៅឈ្មួន នឹងអៀវឈីវជាបាឡាត់សំរបយ៉ុំនាំទាហានទៅ
ល្បាតតាមមាត់ស្ទឹងអ៊ុយហោ ដើម្បីការពារគន់ទ័ពមាំឈីវ ឯបណ្ដាទា-
ហានក្រៅពីនោះ ក៏តាំងជានាហ្មឺនធំ-តូច តាមគុណបំណាច់តិចច្រើន ។

ខណៈនោះ អៀវហ៊ូជាទាហានរង់អៀវឈើវក៏និយាយថា មហាឧបរាជនឹងលើកទ័ពទៅផ្លូវនេះ ក្នុងស្រុកខៀងអ៊ននោះនឹងរកនរណាជាធំនឹងរក្សាត្រួតត្រាគ្មាន ខ្ញុំបាទឃើញថា ម៉ាឈៀវថៃកទ័ពទៅគ្រានេះ គង់នឹងមានសេចក្ដីព្យាបាទជាប់ក្នុងចិត្ត មុខជានឹងគិតសងសឹកវិញ ហើយក្រែងម៉ាឈៀវនឹងបញ្ចុះបញ្ចូលពលទាហានបានច្រើន នឹងលើកមកធ្វើអន្តរាយជាក្រោយក៏នឹងថ្វស់ការ សូមឲ្យលោកចាត់ការរើសមនុស្សឲ្យទៀវឡាតមានគំនិតមារយាទ ឲ្យល្មមទុកចិត្តបាននៅរក្សាស្រុកខៀងអ៊ន ដើម្បីការពារតនឹងម៉ាឈៀវ បើម៉ាឈៀវលើកទ័ពមក នឹងបានជួយគ្នាតយុទ្ធឲ្យបាន ៗ ចូចូឆ្លើយថា ការនេះកុំបអ្នកព្រួយបារម្ភ យើងបានគិតបំរុងទុកជាស្រេចហើយ អៀវហ៊ូឮដូច្នោះ ក៏គំនាប់លាចូចូទៅស្រុកសៃលៀងជាមួយនឹងហ៊ានស៊ុយ ៗ

កាលហ៊ានស៊ុយលើកទ័ពទៅហើយ ទាហានទាំងពួងក៏និយាយនឹងចូចូថា យើងខ្ញុំមានសេចក្ដីសង្ស័យណាស់ ព្រោះកាលដើមម៉ាឈៀវលើកទ័ពមកវាយបន្ទាយតុងគួននោះ ហេតុម្ដេចមហាឧបរាជមិនឲ្យលើកទ័ពទៅតាំងតទ័ពពីក្រោយហ៊ានស៊ុយទុក បើលោកលើកទៅតទ័ពពីក្រោយមិនមានជ័យជំនះធាប់ឬ ? មហាឧបរាជមកតាំងទទួលម៉ាឈៀវនៅបន្ទាយតុងគួននេះ ទាល់តែជាប់ដៃគ្នាជាយូរណាស់ ហើយទើបឲ្យលើកទៅចាំតទ័ពខួប់ខាងត្រើយទិសឯកើតជាក្រោយវិញ តើដោយហេតុប្រការអ្វី ?

ចូច្ចថា កាលនេះឈ្មោះនន្ទះបុាញ់ មិនទាន់យកដៃបិទត្រចៀក អ្នកកល់គ្នាមិនទាន់យល់ទេ ខណៈកាលមាំឈៀវលើកទ័ពមកនោះ យើងមិនបានឲ្យលើកទៅព័ទ្ធពីក្រោយទុក ព្រោះយើងឃើញទាហានមាំឈៀវលើកមកមិនទាន់អស់លើង លុះនឹងបន្ទំឲ្យស្រួតរូតទៅព័ទ្ធពីក្រោយភ្លាម ។ បើទាហានមាំឈៀវលើកមកជាក្រោយ ក៏នឹងសល់នៅនឹងត្រូវតតាំងច្បាំងគ្នាជាពីរផ្នែក ឃើញនឹងកមុខពក្រោយយកជ័យជំនះមិនបាន ហេតុនេះបានយើងក្លែងនៅទទួលតគ្នាឲ្យយូរ ប្រាថ្នានឹងឲ្យទាហានមាំឈៀវលើកមកឲ្យអស់ លុះក្រោយសឹមយើងឲ្យស៊ុំឡូងនឹងជូឡេង នាំទាហានលើកធ្វង់ទៅក្រោយខ្មាំង តាំងព័ទ្ធខ្ទប់ទុកឲ្យត្រូវតាមកលឧបាយ ត្រូវធ្វើការសង្គ្រាមតែមុខមួយមិនព្រួយធុរៈរវល់រាំងទៅទ័ពឯណាដទៃ ក៏បានជ័យជំនះដោយកម្លាំងនឹងថ្វីដៃទាហានទាំងពួងយ៉ាងស្រួល ។

បណ្ដាសេនាទាហានទាំងអស់ បានស្ដាប់ដូច្នោះក៏យល់ឃើញផង ទើបសួរថា កាលលោកតាំងនៅទីនោះ មានមនុស្សយកសេចក្ដីមកប្រាប់ថា ទាហានមាំឈៀវលើកមកទៀត ២ ពាន់ ៣ ពាន់ មហាឧប-ពជមានសេចក្ដីត្រេកអរត្រឡប់ជាអស់សំណើចនោះ ដោយឃើញហេតុយ៉ាងម្ដេច ? ។ ចូច្ចប្រាប់ថា ស្រុកសៃលៀងនោះមានខែត្រកយជាច្រើន កាលទាហានលើកដើរមក យើងក៏ដឹងថា កងទ័ពបណ្ដាខែត្រទាំងនោះលើកមកអស់លើងហើយទើបមានចិត្តត្រេកអរ ព្រោះឃើញថា

ទាហានទាំងពួងនោះ សុទ្ធតែនៅស្រុកចំរៃពីគ្នា មិនរៀបរយគ្នានឹងធ្វើការជាចិត្តមួយ ទោះនឹងមកច្រើនយ៉ាងណាក៏ដូចជាតិច ឃើញថាគង់នឹងចាញ់ថ្វៃដៃទាហានយើងជាប្រាកដ បានជាយើងសើច បើអ្នកមានសតិបញ្ញាតិច នឹងធ្វើសង្គ្រាមតនឹងម៉ាឈៀវត្រឹមខួបឆ្នាំមួយយ៉ាងរហ័ស ដែលនឹងឲ្យបានជ័យជំនះ ដល់បណ្ដាទាហានគ្រប់ខែត្រដូចយ៉ាងធ្វើនេះ កម្រក្រៃក្រណាស់ ។

បណ្ដាសេនាទាហានបានស្ដាប់ហើយ ក៏នាំគ្នាទទួលគំនាប់ហើយសរសើរថា មហាឧបរាជនេះពេញជាមានគម្រិះប្រាជ្ញដ៏សុខុម ប្រកបដោយអានុភាពបដូចទេព ។ ចួចឆ្លើយឡើងថា យើងមានជ័យជំនះគ្រានេះ ក៏អាស្រ័យដោយកម្លាំងនឹងថ្វៃដៃអ្នកកលគ្នា ហើយក៏ឲ្យបំណាច់រង្វាន់ទាហានធំ-តូចតាមសមគួរ ហើយប្រគល់ទាហានរបស់ម៉ាឈៀវដែលចាប់បានមកជាឈ្លើយនោះ ឲ្យហៃហ៊ូគៀនឃុំយកទុករក្សាស្រុកទៀងអ៊ន ឲ្យទៀវគីចៅហ្វាយស្រុកកេងទៀវនៅជួយរាជការផង ចួចចាត់ចែងទាហាននឹងរៀបស្រុកភូមិស្រេចហើយ ក៏ឲ្យលើកកងទ័ពត្រឡប់ចូលទៅស្រុកក្រុង ។

# សាមកុកខ្សែ ៥០

តាំងពីចូឆូឈ្នះទ័ពម៉ាឈៀវ រត់រួចទៅ ចូឆូលើកទ័ពចូលទៅក្រុងវិញ ព្រះចៅហៀនតេ យាងចេញទៅទទួលដល់ក្រៅក្រុង រហូតដល់ឡៅពីលើកទ័ពទៅច្បាំងនឹងឡៀវជៀងចៅហ្វាយស្រុកសែឈួន ។

---

ឯព្រះចៅហៀនតេត្រាស់ថា ចូឆូមានជ័យជំនះសង្គ្រាមម៉ាឈៀវ ហើយលើកទ័ពត្រឡប់មកវិញ ក៏ទ្រង់មានព្រះរាជហឫទ័យសោមនស្ស ស្ដេចទ្រង់គង់រាជរថចេញទៅទទួលទ័ពចូឆូដល់ក្រៅទីក្រុង ហើយមានត្រាស់នឹងចូឆូថា អំណើះពីនេះទៅ បើមិនមានត្រាស់ឲ្យហៅ ក៏កុំឲ្យចូលគាល់ដូចជានាហ្មឺនធម្មតានោះឡើយ បើយើងមានការឲ្យហៅចូលគាល់ ក៏ត្រូវឲ្យសៀតក្រប៊ីចូលគាល់ជាដរាប ហើយកុំបាច់ឲ្យក្រាបថ្វាយបង្គំជាដាច់ខាត ។

ចូឆូបានឮព្រះត្រាស់ផ្ដាល់ដូច្នោះ ក៏មានចិត្តកំរើបជាទំហំក្រៃលែងលើសពីដើម កិត្តិសព្ទក៏ឮខ្ទរខ្ទាយទៅដល់ទៀវឡូ ចៅហ្វាយស្រុកហ័នតុង ។ ឯទៀវឡូនោះ ជាក្មួយទៀវឡេង ៗ នោះពីដើមជាពួកស្រុកសែឈួន ទៅស្វែងរៀនវិជ្ជានេះតំបន់ភ្នំបេងស័ន លុះរៀនវិជ្ជាការបានចំណានហើយ ក៏មកនៅក្នុងស្រុកហ័នតុង អាណាប្រជានុរាស្ត្រចំណុះស្រុកនោះ បើនរណាឈឺថ្កាត់ដោយជម្ងឺអ្វី ៗ ក៏យកជាធុរៈជួយទំនុកបំរុងឲ្យសម្រេចសេចក្ដីប្រាថ្នាគ្រប់ប្រការ អាណាប្រជានុរាស្ត្រទាំងពួងក៏

រាប់អានស្រឡាញ់ទៅមកជាទីគារវៈ បើនឹងរក្សាកេអ្នកឯណាជា ក៏មិនបានយកវត្ថុ ឲ្យយកតែស្រូវ ៤ ថាំងទៅគំនាប់បូជាគ្រូ លុះទៀវឡេងស្លាប់ ទៀវឡូជាក្មួយក៏បានវិជ្ជាការនោះធ្វើតាមប្រពៃណីតមក អាណាប្រជានុរាស្ត្រទាំងពួងក៏រាប់អានស្រឡាញ់ តាំងនៅក្នុងឱវាទបង្គាប់បញ្ជាគ្រប់ប្រការ សន្មតិឲ្យជាអ្នកធំ ទៀវឡូក៏ប្រដៅមនុស្សទាំងពួងឲ្យធ្វើតាមឱវាទ តាំងនៅដោយប្រក្រតីមិនបានបៀតបៀនគ្នា បើអ្នកឯណាធ្វើខុសដល់ ៣ ដងក៏មិនបានយកទោសអាណាប្រជានុរាស្ត្រទាំងពួងក៏នៅជាសុខក្សេមក្សាន្តគ្រប់ភូមិលំនៅ បណ្ដាស្រុកគ្រាមនិគមដែលត្រូវឡើងស្រុកហ័នតុង នោះក៏កោតខ្លាចអំណាចទៀវឡូទាំងអស់ ឯចៅហ្វាយស្រុកហ័នតុងនោះសោត ក៏កោតខ្លាចគំនាប់គោរពទៀវឡូ ។

ខណៈនោះទៀវឡូដឹងដំណឹងថា ចូឆូមានជ័យជំនះម៉ាឈៀវ ហើយមានចិត្តកំរើបធំលើសឡើង ក៏នឹកបារម្ភខ្លាចក្រែងចូឆូនឹងលើកទ័ពមកធ្វើអន្តរាយដល់ស្រុកហ័នតុង ទើបទៀវឡូឲ្យប្រមូលមនុស្សចាស់ទុំមកប្រឹក្សាថា ឥឡូវនេះចូឆូ ដើរប្រាប់ប្រាមគ្រប់អាណាខេត្តទាំងពួង ក៏ចុះចូលជាច្រើនណាស់ហើយ ដូចម៉ាថេងចៅហ្វាយស្រុក-សែលៀងនោះសោត ចូឆូក៏សម្លាប់ចេញបាន ម៉ាឈៀវជាកូនទៀតក៏បែកចាញ់ទ័ពចូឆូ គិតការជាធំទូលាយលើសអំពីដើម បើនឹងលើកទាហានមកវាយស្រុកហ័នតុង ការណាមុខជាអាណាប្រជានុ-

រាស្ត្រទាំងពួងនឹងបានសេចក្ដីក្ដៅក្រហាយជាខ្លាំង គួរតែយើងនឹងតាំងខ្លួនឡើងជាម្ចាស់ ឈ្មោះព្រះចៅហ៊ានឡើងផង នឹងបញ្ចុះបញ្ចូលទាហានឲ្យបានច្រើន ហើយនឹងធ្វើការតនឹងចិន ការពារស្រុកទុកមិនឲ្យជាអន្តរាយ រក្សាណាប្រជានុរាស្ត្រឲ្យនៅជាសុខតទៅ អ្នកទាំងពួងពល់គ្នានឹងយល់ឃើញប្រការម្ដេច ។

យៀមផៅឆ្លើយថា លោកគិតនេះគួរណាស់ ព្រោះស្រុកហ៊ានតុងមានមនុស្សច្រើននៅក្នុងឡកខលោកក្នុងចំនួន ១០ ម៉ឺន ចំណីអាហារក៏បរិបូណ៌ទាំងអស់ តែថានៅមិនទាន់ស្មើនឹងចិនទៅឡើយ ឯម៉ាឈៀវដែលបែកទ័ពពីចិនមកឥឡូវនេះ ក៏គង់នឹងមកប្រាស្រ័យនៅនឹងយើង ទោះយ៉ាងណាក៏គង់តែចិននោះ នឹងលើកទ័ពតាមមកដល់ស្រុកយើងជាប្រាកដ ដែលយើងនឹងគិតធ្វើការតយុទ្ធនឹងចិននោះ គួរតែនឹងទៅវាយយកស្រុកសៃឈួនទាំងសែសិបខែត្រឲ្យបានសិន ទើបកម្លាំងយើងនឹងបានច្រើន ព្រោះឡៅជៀងចៅហ្វាយស្រុកអេកជីវ ដែលជាធំក្នុងស្រុកសៃឈួននោះក៏ជាមនុស្សលោភណាស់ មុខជានឹងវាយបានដោយងាយ បើបានសម្រេចហើយ លោកនឹងតាំងខ្លួនជាអម្ចាស់ទើបស្រួល ទៀវឡ្យបានស្ដាប់ដូច្នោះក៏យល់ត្រូវផង ទើបឲ្យកេខ្លួនទៀវអ៊ុយមកប្រឹក្សា ដើម្បីនឹងលើកទ័ពទៅវាយស្រុកសៃឈួន ។

ឡៅជៀវចៅហ្វាយស្រុកអេកដីវនឹងទៀវឡុនោះ ជាមនុស្សហារិ គ្នាមកពីដើម ព្រោះឡៅអៀវជាឪពុកឡៅជៀងអនិច្ចកម្មទៅ ឡៅជៀង ក៏បានឡើងជាចៅហ្វាយស្រុកជំនួសឪពុក ចាប់យកម្តាយទៀវឡុទៅ សម្លាប់ ខ្លាចទៀវឡុនឹងលើកទ័ពមកធ្វើអន្តរាយ ទើបតាំងឲ្យប៉ាំងយីជា ចៅហ្វាយស្រុកប៉ាសេ ប្រាថ្នានឹងឲ្យចាំការពារទ័ពទៀវឡុ លុះប៉ាំងយីដឹង ដំណឹងថាទៀវឡុ រិះគិតប្រមូលជាកងទ័ពនឹងលើកមកវាយយកសែឈួន ដូច្នោះ ក៏ឲ្យបំរើសេះស្រួតនាំដំណឹងនោះទៅប្រាប់ឡៅជៀង ៗ ដឹងរឿង ដូច្នោះក៏ភ័យណាស់ ទើបឲ្យហៅបណ្តានាម៉ឺនធំ តូចទាំងពួងមកប្រឹក្សា ៖

ទៀវសុងទីប្រឹក្សាឆ្លើយថា ដែលទៀវឡុនឹងលើកទ័ពមកធ្វើអន្តរាយ ដល់ស្រុកសែឈួននោះលោកកុំព្រួយឡើយ ខ្ញុំបាទសុំយកតែអណ្តាត ៣ ឆ្នាប់នេះអាសាទៅតនឹងទៀវឡុ មិនឲ្យលើកមកធ្វើអន្តរាយបាន ឡៅ-ជៀងបានស្តាប់ក៏ក្រឡេកមើលទៀវសុងឃើញរូបរាងតាបគន្ធិល ក្បាល ត្រមោងដូចផ្លែត្នោត ច្រមុះក្រពិត រូបមិនសមជាអ្នកចេះនិយាយ ក៏មិន បានទឹងជឿ ទើបសួរថាអ្នកនឹងគិតទៅនិយាយយ៉ាងម្តេច ចូរថាឲ្យយើង ស្តាប់សិន ។

ទៀវសុងឆ្លើយថា ខ្ញុំបាទដឹងថាប៉ូឆូនេះជាអ្នកមានអំណាចដើរប្រាប់ ប្រាមចំណោះសមាឡៃនៅក្នុងអំណាចខ្លួនទាំងអស់ សូមឡីអ្នួនសៀវ អ្នួន ស៊ុតសោត ក៏ចូឆូកំចាត់ចេញអស់ហើយ តង្វូរម៉ាឈៀវជាកូនមាទេង

សោតក៏ចាញ់ប្រៀបចូឆូបែកទ័ពរត់មកទៀត ចូឆូមានទាហានច្រើនណាស់ សុំឲ្យគាត់តែងគ្រឿងបណ្ណាការទៅសុំចុះចូលគំនាប់ចូឆូ ខ្ញុំបាទនឹងសុំយកភាសាកាន់សំបុត្រទៅនិយាយឲ្យចូឆូលើកទ័ពមកវាយស្រុកហ័នតុង បើស្រុកហ័នតុងកើតសឹកជាប់ដៃគ្នាហើយ ក៏មុខជាមិនលើកទ័ពមកធ្វើអន្ត-រាយស្រុកយើងទេ ឡៅជៀងស្តាប់ឃើញត្រូវក៏មានសេចក្តីត្រេកអរ ទើបចាត់ចែងតែងគ្រឿងបណ្ណាការនឹងសំបុត្រមួយច្បាប់ឲ្យទៀវសុង ៗ ក៏លបគូរផែនទីស្រុកសែឈួនគ្រប់រយៈទាំងអស់ហើយ ក៏នាំចូលទៅក្រុងហ៊ូតោឆ្លងកាត់ស្រុកកេងជីវទៅ ៗ

ខណៈនោះ ខុងបេងដឹងថា ឡៅជៀងប្រើឲ្យទៀវសុងនាំគ្រឿងបណ្ណាការចូលទៅគំនាប់ចូឆូ ក៏ចាត់ប្រើមនុស្សឲ្យតាមស៊ើបស្តាប់ការរាជ-ការមើលក្នុងស្រុកហ៊ូតោ លុះទៀវសុងទៅដល់ស្រុកហ៊ូតោហើយ នឹងចូលទៅគំនាប់ចូឆូមិនបាន ព្រោះចូឆូមិនបានចេញនិយាយការរាជការនៅរង់ចាំដល់ ៣ ថ្ងៃ ទើបឲ្យមនុស្សបំរើចូលទៅតាមដំណើរសេចក្តីដល់ចូឆូ ៗ ក៏ឲ្យហៅខ្មុនទៀវសុងចូលទៅខាងក្នុង ទៀវសុងគំនាប់ហើយក៏ជូនសំបុត្រនឹងគ្រឿងបណ្ណាការឲ្យចូឆូ ៗ

( នៅមានត )

រឿងព្រេងចិន

លោក ប៉ាយ-ប៊ុក ប្រែរៀបរៀង

(តមក)

## ៣– រឿងជក់ទិព្វ

មានកាលមួយថ្ងៃ ម៉ាលៀងបានគូរសត្វក្រៀលមួយសម្បុរសសុទ្ធ គ្មានភ្នែក ។ តែដោយការធ្វេសប្រហែស ម៉ាលៀងក៏ធ្វើឲ្យទឹកខ្មៅមួយដំណក់ធ្លាក់ចំភ្នែកក្រៀលនោះ ។ ក្រៀលក៏បើកភ្នែកធំ ត្រដាងស្លាបហើរទៅលើនភាល័យ ។ ព្រឹត្តិការណ៍ប្លែកនេះ ធ្វើឲ្យប្រជាពលរដ្ឋដែលស្ថិតនៅទីនោះផ្អើលឆោឡោគ្រឹកគគ្រេងពាសពេញទីនោះ ។ មានជនពួកខ្លះធ្វើបុតហ្មាយថ្វាយដល់ព្រះមហាក្សត្រ ។ ព្រះមហាក្សត្រទ្រង់ត្រាស់បង្គាប់ឲ្យរដ្ឋមន្ត្រីមកអញ្ជើញម៉ាលៀងទៅកាន់រាជធានី ។ ម៉ាលៀងមិនចង់ទៅសោះឡើយ តែរដ្ឋមន្ត្រីបង្ខំម៉ាលៀងដោយអូសទាញទាល់តែដល់ព្រះបរមរាជវាំង ។

ម៉ាលៀងមានចិត្តស្អប់ព្រះមហាក្សត្រ ដោយបានឮដំណឹងថាព្រះមហាក្សត្រធ្វើទុក្ខបុកម្នេញបណ្ដារាស្ត្រតូចតាច ។ ដោយហេតុនេះហើយបានជាម៉ាលៀងគិតក្នុងចិត្តថា ខ្ញុំមិនគួរគូរទៅតាមព្រះរាជបញ្ជាព្រះមហាក្សត្រទេ ។ ព្រះមហាក្សត្រ ទ្រង់ត្រាស់បង្គាប់ឲ្យម៉ាលៀងគូរនាគ

ម៉ាលៀនគូរគឺងគក់គគ្រាត ។ បើព្រះមហាក្សត្រទ្រង់គ្រាស់បង្គាប់ឲ្យ
ម៉ាលៀនគូរសត្វពជហង្ស? ( blénix ) ម៉ាលៀនគូរមាន់ញីគ្មានស្លាប ។
សត្វទាំងពីរមានសភាពគួរឲ្យខ្ចើមឆ្មើមពន់ពេក ។ សត្វនេះលោតចុះឡើង
ជុំវិញព្រះមហាក្សត្រ បន្ទោបង់នូវលាមកស្អុយពេញពាស មានក្លិន
អសោចចាល់តែព្រះមហាក្សត្រទ្រង់ព្រះក្រោធខ្លាំង ។ ទ្រង់មានព្រះរាជ
ទង្គារឲ្យពាហានចាប់ម៉ាលៀនតទ្រាក់យកដក់ទ្រុង ហើយយកម៉ាលៀន
ទៅឃុំខាំងនៅក្នុងសើនមួយ ។

ព្រះមហាក្សត្រទ្រង់យកដក់ទ្រុងនោះ មកគូរពាសជាគំនូរមាសមួយ ។
តែមាសមួយគំនូរនេះ ទ្រង់យល់ថាតិចពេកមិនអាចបំពេញនូវសេចក្ដី
លោភរបស់ព្រះអង្គបាន ទ្រង់ក៏គូរមួយគំនូរទៀត រួចគំនូរទី ៣ ទី ៤...
រហូតដល់គំនូរជាអនេកប្បការ ។ ដល់គូររួចហើយ ទ្រង់ទតទៅយល់
មិនមែនឃើញជាគំនូរមាស ទៅជាគំនូរជុំថ្មទៅវិញ ។ ដោយថ្មខាង
លើធ្ងន់ពេកគំនូរថ្មនោះក៏រលំធ្លាក់មកក្រោមអស់ ។

សេចក្ដីលោភ នៃព្រះមហាក្សត្រមិនទាន់ផុតរលត់ត្រឹមនេះទេ ។
ដោយទ្រង់មិនសព្វព្រះហឫទ័យនឹងគំនូរមាស ទ្រង់ក៏គូរអិដ្ឋមាសថែម
ទៀត ។ ទ្រង់គូរមួយ ពីរ បី . . . តែអិដ្ឋមាសនោះតូចពេក . . . ទ្រង់
ក៏គូរអិដ្ឋមាសមួយធំ វែងជាច្រើនម៉ែត្រ ។ ដល់ទ្រង់គូររួចហើយ ទ្រង់
ក៏ទតទៅឃើញមិនមែនជាអិដ្ឋមាស ត្រឡប់ទៅជាពស់វែកមួយវែងស្អុះ

មកចឹកព្រះអគ្គិ ។ ប៉ុន្តែពួករាជមន្ត្រីព្រះអគ្គិរត់ទៅជួយ កុំអីពស់នោះវាលេបមហាក្សត្រទាំងរស់ទៅហើយ ។

មហាក្សត្រទ្រង់យល់ជាក់ច្បាស់ថា ទ្រង់មិនអាចប្រព្រឹត្តសកម្មភាពអ្វីបានក្រៅពីម៉ាលៀងសោះឡើយ ។ ទ្រង់ក៏ត្រាស់បង្គាប់ឲ្យយកម៉ាលៀងចេញពីគុកហើយ ទ្រង់បានព្រះរាជទាននូវមាសប្រាក់ជាច្រើនព្រមទាំងទ្រង់មានព្រះឱស្ឋវាចាផ្អែមល្ហែម បង្ខំឲ្យម៉ាលៀងធ្វើសមរសេទនឹងព្រះអគ្គិម្ចាស់ក្សត្រី ។

ម៉ាលៀងមានផែនការរបស់ខ្លួន បានប្រកាសចំពោះព្រះភក្ត្រព្រះអគ្គិថា លោកយល់ព្រមធ្វើព្រះសមរសេទនឹងព្រះអគ្គិម្ចាស់ក្សត្រី ។ ព្រះមហាក្សត្រ ដោយទ្រង់ចតទៅឃើញម៉ាលៀងស្លូតព្រមធ្វើតាមព្រះរាជបញ្ជាគ្រប់យ៉ាង ទ្រង់ក៏ព្រះរាជទាននូវជក់ទិព្វដល់ម៉ាលៀងវិញ ។

ព្រះមហាក្សត្រទ្រង់ព្រះតម្រិះក្នុងព្រះអង្គឯងថា: “ប្រសិនបើជាអញប្រាប់ម៉ាលៀងឲ្យវាគូរភ្នំ ប្រហែលជាមានសត្វសាហាវ ។ បើដូច្នេះត្រូវឲ្យវាគូរសមុទ្រវិញប្រសើរជាង” ។ ទ្រង់ក៏ត្រាស់បង្គាប់ឲ្យម៉ាលៀងគូរសមុទ្រ ។

ម៉ាលៀងគ្រាន់តែយកជក់ទិព្វ គ្រវាសពីរដង ស្រាប់តែលេចសមុទ្រទឹកល្ហាច ។ នៅចំព្រះភក្ត្រព្រះអគ្គិមានទឹកសមុទ្រត្រជាក់ថ្លាល្ហល្ហើ មានពណ៌ខៀវថ្លៃមេឃ ភ្លឺចាំងដូចជាក្នុងកញ្ចក់ ។

ព្រះមហាក្សត្រទ្រង់ទតអោយលស់សមុទ្រហើយ ទ្រង់ត្រាស់បង្គាប់ឲ្យម៉ាលៀងគូរត្រីទៀត ។ ម៉ាលៀងក៏គូរត្រីតាមព្រះរាជបញ្ជា ។ សមុទ្រក៏មានត្រីពាសពេញគ្រប់ពណ៌ហិចហែលបក់កន្ទុយរវិច ។ ត្រីនោះក៏ហែលឆ្ងាយពីច្រាំងរហូតទៅដល់កណ្តាលសមុទ្រ ។ ព្រះមហាក្សត្រទ្រង់ក្រសាលសប្បាយ នឹងត្រីនោះពន់ពេក ទ្រង់ក៏មានព្រះរាជឱង្ការថា: "ត្រូវឯងគូរនាវាមួយ ! អញចង់ទៅមើលត្រីកណ្តាលសមុទ្រ" ។

ម៉ាលៀងក៏គូរនាវាធំមានក្តោងមួយ ។ ព្រះមហាក្សត្រ ព្រះមហារាជិនី ព្រះអង្គម្ចាស់ក្សត្រី ក្សត្រា ស្តេចឡើងគង់លើនាវាក្តោងនោះជាមួយនឹងពពួកមន្ត្រីជាព្រះរាជបរិវារ ។

ម៉ាលៀងយកជក់ទំពួមកគូរវាសទៅ ស្រាប់តែព្រះពាយបក់មក នាវានោះក៏ធ្វើដំណើរទៅកាន់កណ្តាលសមុទ្រ ។ ម៉ាលៀងគូរវាសម្តងទៀត ស្រាប់តែសមុទ្រមានរលកធំៗ បក់បោកមកកាន់នាវាធ្វើឲ្យព្រះអង្គទទឹកអស់ ។

ព្រះមហាក្សត្រទ្រង់មានព្រះរាជបន្ទូលសូរសីហនាទថា: "ម៉ាលៀងឈប់ កុំគូរទៀត" ។ តែម៉ាលៀងពុំព្រមតាមព្រះរាជបញ្ជាធ្វើដូចជាមនុស្សថ្លង់ ក៏ចេះតែគូរវាសតទៅទៀត ទាល់តែព្យុះសង្ឃរាធំបក់មកប៉ះនាវានោះលិចលង់ក្នុងជលសា បណ្តាលឲ្យព្រះមហាក្សត្រ ព្រះមហារាជិនី

ព្រះរាជវង្សានុវង្សលិចលង់អស់ព្រះជន្មាយុ ។ ឯពពួករដ្ឋមន្ត្រីក៏ទទួលមរណភាពកន្លងមហាសាគរនោះដែរ ។

ក្រោយដែលព្រះមហាក្សត្រទទួលទិវង្គតទៅ កិច្ចការនៃម៉ាលៀងក៏ពុះសព្ទសូររន្ទឺទៅគ្រប់ប្រទេស ។ តែម៉ាលៀង គ្មានអ្នកណាបានដឹងថាគាត់ទៅឯណាឡើយ ។ មានខ្លះពោលថាគាត់បានត្រឡប់ទៅកាន់ភូមិគាត់វិញ មានខ្លះថាគាត់ ដើរពីភូមិមួយទៅភូមិមួយ ត្រូវបសព្វយ៉ាងដើម្បីជាបេរចិញ្ចឹមជីវិតទៅតាមយថាកម្មរបស់ខ្លួន ។

## បប់រឿងជក់ទិព្វ

នៅមានរឿង វិរបុរសសីគាល់តទៅទៀត ជារឿងព្រេងពីសន្តតិវង្សយើ ល្អគាន់ណាស់ ។

## ៤- រឿងវិរបុរស « សីគាល់ »

4— L'histoire du héros Chegal
( Conte de la Nationalité )

តាំងពីបុរាណកាលមក ផែនដីយើងសព្វថ្ងៃគឺដោយព្រះអាទិត្យ ៧ ព្រះចន្ទ ៦ ។ អាកាសក្ដៅស្អាន្នរ៉ង់រឿង បរិយាកាសក៏ក្ដៅ សត្វតិរច្ឆានក៏មានច្រើនលើសលុប ។ ក្នុងសម័យនោះ លោកវិរបុរស សីគាល់ បានចុះតិមកក្នុងលោក ចម្រើនវ័យវៃឆ្លាតមាការធំឡើង ហើយមានភរិយាពីរៗ នៅសរទោផ្លូវ លោកបានលាភរិយាតាំងពីរបស់លោក ដែលស្ថិតនៅ

ក្នុងកោះនៃសមុទ្រខាងកើត យកព្រះច័ន្ទសៀតបង្កើះ រួចជិះសេះមួយ ហោះធ្វើដំណើរជុំវិញពិភពលោក ។ ដំណើរលោកសីគាល់នោះមានវត្តបំណង គឺលោកចង់ពិនិត្យមើលមនុស្សជាតិ និងសត្វតិរច្ឆានទាំងអស់រស់នៅទៅតាមព្រះពរបំណងនៃអាទិទេព គឺរស់នៅដោយសមភាពនិងសន្តិភាពឬ? ។

លោកបានធ្វើដំណើរនេះយ៉ាងវែង ។ មានមួយថ្ងៃ លោកបានអញ្ជើញទៅដល់កលមួយស្ថិតនៅជិតភ្នំលៀងបន្ទូ ។ លោកបានក្រឡេកទៅឃើញមានបក្សាបក្សីជាច្រើនណែនណាន់តាន់តាប់ ជជែកគ្នាទៅវិញទៅមកដោយសេចក្តីព្រួយបារម្ភយ៉ាងខ្លាំង ។ លោកសីគាល់ក៏នឹកក្នុងចិត្តថា: អញបានទស្សនាជាងពាក់កណ្តាលពិភពលោកហើយ អញបានឃើញជាក់ច្បាស់នឹងមិនសង្ស័យថាមនុស្សជាតិនិងតិរច្ឆានជាតិបានទទួលសមភាពនិងសន្តិភាពគ្រប់ ៗ គ្នា ។ តើឥឡូវនេះ ម្តេចក៏បក្សាបក្សីនេះឈរជិតគ្នាទុកមុខព្រួយបារម្ភដូច្នេះ? ។

លោក សីគាល់ ក៏ពោលទៅកាន់បក្សាបក្សីទាំងនោះថា: «មនុស្សជាតិ តិរច្ឆានជាតិនៃពិភពលោក គេរស់នៅសុខសប្បាយគ្រប់គ្នា ។ ម្តេចក៏អ្នកឯងរាល់គ្នាមានទឹកមុខព្រួយម្ល៉េះ» ។

ក្នុងពេលនោះ មានអាអួតមួយជាអ្នកមានវោហាគ្រាន់បើ បានចូលមកជិតលោកសីគាល់ហើយបានពោលថា:

(នៅមានត)

# ទំនៀមកុលសម្ពន្ធ

## ខ្មែរលើ

ពាក្យថា "កុលសម្ពន្ធ" ដូចជាមានន័យកំបាំងបន្តិច តែខ្ញុំយកឈ្មោះនេះមកនិយាយ ព្រោះសព្វថ្ងៃក្រុមនេះ នៅមានស្ទើរគ្រប់ប្រទេសក្នុងអាស៊ីទ្វីប ។ នៅប្រទេសខ្មែរ ក្រុមនេះហៅថា "ខ្មែរលើ" ។ ខ្មែរលើគឺជាជនមួយពួកដែលមានឈាមជ័រជាខ្មែរដែរ តែពួកយើងជាខ្មែរធម្មតាភាគច្រើន មិនសូវជាយល់ ឬដឹងនូវទំនៀមនៃជននេះសោះ ។ ឥឡូវរាជរដ្ឋាភិបាលសង្គមរាស្ត្រនិយម កំពុងអប់រំពួកខ្មែរលើឲ្យមានជីវភាពខ្ពង់ខ្ពស់ឈមមុខទៅរកអារ្យធម៌ ។ ដូច្នេះ ពួកខ្មែរលើមុខតែអាចបំភ្លេចនូវទំនៀមខ្លះចោលបាន ។ ខ្ញុំសូមឆ្លៀតឱកាសនេះ និទានទំនៀមទម្លាប់ខ្មែរលើខ្លះជូនលោកអ្នកជ្រាប តាមឯកសាររបស់លោក ចូ ធន សាស្ត្រាចារ្យនៅអនុវិទ្យាល័យព្រះមហាក្សត្រិយានី កុសុមៈ (ក្រចេះ) ដែលកត់ទុកនៅក្នុងក្រុមជំនុំទំនៀមទម្លាប់ ដូចតទៅ ៖

## យញ្ញពិធីរបស់ខ្មែរលើ

ខែត្រក្រចេះ ដែលបែងចែកទៅជារតនគីរីខ្លះ ទៅជាមណ្ឌលគីរីខ្លះ ជាកន្លែងដែលបរិបូណ៌ទៅដោយពួកកុលសម្ពន្ធ ដែលយើងស្គាល់ឈ្មោះពិតថា "ខ្មែរលើ" ។

ខ្មែរលើមានវប្បធម៌ ឬទំនៀមទម្លាប់សឹងតែប្លែកពីខ្មែរយើងធម្មតា ។ ទំនៀមដែលប្លែកពីខ្មែរធម្មតាខ្លះ មិនសូវជាធ្វើឲ្យយើងព្រឺព្រួចស្ញើបទេ តែចំពោះពិធីមួយ ដែលយើងធ្លាប់តែឮនៅក្នុងគម្ពីរខ្លះនោះ ឥឡូវពួកខ្មែរលើនៅប្រព្រឹត្តសព្វថ្ងៃ គឺ "ពិធីបូជាយញ្ញ" ឬ "យញ្ញពិធី" ។ ពិធីបូជាយញ្ញ ដែលគួរឲ្យស្ញើបព្រឺព្រួច គឺការសែនព្រេនដើម្បីគោរពនូវព្រលឹងស្រូវ ដែលយើងហៅថា ព្រះពៃស្រពណ៍ ។

រដូវប្រូតប្រឡះយកគ្រាប់ស្រូវចេញពីគួររួចហើយកាលណា ពួកខ្មែរលើយកជារស្រូវទៅគរ ឬទុកក្នុងជាកតែមួង ។ អ្នកមានមុខមាត់ដែលគេស៊ីធូរបានស្រូវច្រើននៅក្នុងភូមិ គេសន្មតថា ជាអ្នកមាននៅក្នុងភូមិ ហើយអ្នកនេះត្រូវរៀបចំពិធីសែនព្រេនព្រលឹងស្រូវ មិនដែលខានទេ ។

ពេលពិធីសែនព្រលឹងស្រូវមកដល់តាមបុក្សពារហើយ ។ ភ្ញៀវដែលគេបានអញ្ជើញនោះ ក៏មកអង្គុយដក់ក្នុងតែនភ្លូនតាមលំដាប់ឋានៈនៅជុំវិញពិនូងស្រា ឬក៏នៅហែតាមលំដាប់ពិនូងស្រា ប្រសិនបើជាមានថុទិនស្រាច្រើន ។ ពិនូងស្រា គេរៀបដាក់ជាគំនរពីធំទៅតូចឡើងទៅ មានកំពស់ប្រហែលជា ១ ម៉ែត្រកន្លះ ។ ភ្ញៀវអង្គុយបំរុងបឺតស្រាតាមបំពង់ក្នុងថុទិន ភ្លេងក្រឡាប់តាក់សំឡឹងដោតទៅក្រុមជន្រមួយវង់ ។ ពួកអ្នកភ្លេងជួតក្បាលសំពត់ជាតិ ឈរកាន់គងនៅគ្រប់ដៃ នៅក្បែរកន្ទង

ដែលគេសំពប់បូជាយញ្ញ ។ នៅពិឃាតដ្ឋាន មានក្របីយ៉ាងធាត់មួយ ឬក៏មួយទឹមត្រូវគេចងក្រៀកនៅទីនោះស្រេច ។ សត្វអភ័ព្វឈរសម្រក់ទឹកភ្នែកតក់ៗ បំរុងលាខ្លួនចាកមនុស្សលោកទៅតាមមច្ចុរាជ ។ គេចងអម្បោះពីស្នែងក្របីដែលត្រូវសម្លាប់ បន្តទៅដល់គំនរស្រូវដើម្បីឲ្យព្រលឹងស្រូវទៅទទួលសេពសោយឈាមក្របីស្រស់ ។

ពេលហោមពិធីមកដល់តាមកំណត់ទុកហើយ ខ្មែរលើម្នាក់ពងធាត់ក្រអាញដើរអើអាក កាន់ក្រីសមុខសស្លាបជម្រង់ទៅសត្វអភ័ព្វ ។ ខណៈនោះ ភ្លេងក៏ប្រគំ "បទអំប្រើ(១)" ឡើង ។ ខ្មែរលើកាន់ក្រីសស្ទុះចូលទៅចាក់ខ្នះធ្លើះសរសៃកនៃក្របីផ្តាច់ឲ្យហូរឈាម ។ អ្នកចាស់ទុំមានមុខមាត់និយាយសំបូងសំរួង អញ្ជើញខ្មោចព្រាយអារក្សអ្នកតាបង់បត់គ្រប់ទិសទស ពិសេសគឺគេស្ងូត្រអញ្ជើញព្រលឹងស្រូវឲ្យចូលមកសេពសោយឈាមក្របី ។

លុះនិយាយបួងសួងចប់ហើយ ភ្លេងប្រគំរហូតដល់តំរប់ ៣ ជង ។ ឯអ្នកអារកាត់សរសៃជើងក្របី បេះតែកាត់ចាល់តែក្របីស្រែកទន់ខ្លួនដួលត្រប់ទៅលើព្រះធរណី ។ ក្នុងពេលដែលក្របីដួលមិនទាន់ស្លាប់ គៀរក៏ស្រែកហោក្រេវ ៗ ឡើងគ្រវីព្រឹក្បាល ហើយស្ទុះចូលទៅចាប់អារសាច់ក្របីទាំងរស់ រួចបោះទៅក្នុងឆើកភ្លើងឆេះឆគុលនៅក្បែរនោះស្រាប់

---

១- បទភ្លេងនឹងចម្រៀងមួយបែបរបស់ខ្មែរលើ ។

រួចនាំគ្នាស៊ីផឹក បឺតស្រាដកបដល់អស់ពីក្នុងពាងទាំងផ្លូវនោះ ទើបនាំគ្នាថយចេញទៅកន្លែងរៀងៗខ្លួន ។

---

## ពួកស្អូច

សម្លៀកបំពាក់: ស្អូចប្រុសៗច្រើនស្លៀកសំពត់វែងដូចខ្មែរលើដែរ តែលែងដងខ្លួនទទេ ។ ចំណែកស្រីៗវិញ ស្លៀកសំពត់ពណ៌ខ្មៅៗ សំពត់ស្លៀក គេកាត់តែប៉ុនទទឹងធ្មេញឈើ យកមករុំព័ទ្ធតែមួយជុំបង្កេះ សំយ៉ុងទៅក្រោមហៀរកែងៗ ដងខ្លួនគេយកសំពត់មួយទៀតមកបោមពុងៗ សម័យឥឡូវ ពួកស្អូចបានឈមមុខមករកការប្រធម៌ខាងសំលៀកបំពាក់កាន់តែដូចខ្មែរធម្មតាហើយ ។

គេហដ្ឋាន: ទីលំនៅរបស់ស្អូចមិនបានជាមាំទាំទេ ។ គេសង់ជាខ្ទមតូចៗ ដូចជាជម្រកបណ្ដោះអាសន្ន ។ របៀបសង់ផ្ទះ គេមានទំនៀមខាងសង់ផ្ទះទទឹងថ្ងៃ ។

របរកស៊ី: អាជីវកម្មរបស់ពួកស្អូច មិនបានជាសព្វគ្រប់ទេ គេធ្វើឲ្យតែគ្រប់គ្រាន់ប៉ុណ្ណោះ ។ គេច្រើនតែដាំស្រូវ ពោត ត្រាវ ដំឡូង ដែលជាការចាំបាច់ក្នុងការចិញ្ចឹមជីវិត ។

ភាសា: រឿងភាសានេះ ពួកកុលសម្ពន្ធនិយាយមិនដូចគ្នាទេ ។ បើតាមខ្ញុំសង្កេតទៅដូចជាត្រូវតាមមតិលោក ជន. ប. ការុល (Jonh B. Carroll)

ដែលនិយាយថា "ភាសារបស់សង្គមនីមួយៗ មិនអាចឲ្យមានឯកភាពត្រឹមត្រូវបានទេ ប្រសិនជាសង្គមមនុស្សកើតធំឡើង ភាសាកាន់តែរេទៅរកសេចក្ដីឃ្លៀងឃ្លាតបន្តិចដែរ ។ ដូច្នេះ សង្គមនីមួយៗ រមែងមានលំនាំសំដីផ្សេងៗពីគ្នា" ។ ភាសារបស់កុលសម្ព័ន្ធនៅស្រុកខ្មែរ មានពួកគួយ ជង ស្អូច ជាដើម មានភាសាដូច្នេះខ្លះ ខ្ញុំសូមលើកយកពាក្យខាងក្រោមនេះជាឧទាហរណ៍:

| | | |
|---|---|---|
| ខ្មែរធម្មតា | ស្អូច | ពង |
| ទៅណា | ចេវូទី | អាក្រក់ម៉ៃ |

ឧទាហរណ៍ខាងនេះ អាចបញ្ជាក់ថា សង្គមមនុស្សប្លែកគ្នាអាចឲ្យប្រើភាសាប្លែកគ្នាបន្តិចទៅដែរ ។ ដូចយ៉ាងជនស្បែកក្រហមនៅសហរដ្ឋអាមេរិក ពួកណាវ៉ាហូ « Navajo » ពួកផឹប្លូ « Pueblo » ពួកអាប៉ាឆេ « Apache » និងពួកឯទៀតៗ និយាយមិនត្រូវគ្នាទេ ។

សាសនា: ពួកស្អូចមិនមែនប្លែកពីខ្មែរយើងសម័យដើមប៉ុន្មានទេ ។ ការកាន់សាសនាវិញនោះ គឺគេគោរពប្រតិបត្តិទំនឹងមាំតែលើខ្មោចអារក្សអ្នកតា ដូចតែខ្មែរយើងពីដើមដែរ ។ ពួកស្អូចតែងលៃថ្ងៃខែ តែងនាំគ្នាធ្វើបុណ្យបូជាអារក្សអ្នកតា ដើម្បីឲ្យបានអាយុវែង ។ ពិធីបុណ្យនេះ គេយកម្ហូបចំណីទៅរៀបសែនព្រេនទៅទីកន្លែងណាដែលមានអារក្សអ្នកតាឬកន្លែងណាដែលមានដើមឈើធំៗ គួរជាទីស្ងប់ស្ងែង ។

ពិធីអាពាហ៍ពិពាហ៍ៈ ទំនៀមស្តីដណ្តឹងកូនក្រមុំគេ មុនរៀបការ ពួកស្អូចនៅមានប្រព្រឹត្តដូចខ្មែរយើងធម្មតា ។ មុនដំបូង គេរកអ្នកផ្សំទៅ មហាទៅស្តីដណ្តឹងកូនគេដល់ឪពុកម្តាយខាងស្រី ។ អ្នកផ្សំទៅមហាថៃ ចូរគ្នាស្រុះស្រួលថាព្រមឲ្យកូនហើយ គេទើបតាត់រៀបការកូនប្រុសស្រី ។ ពេលថ្ងៃរៀបមង្គលការ ឪពុកម្តាយខាងកូនប្រុស ត្រូវរៀបរណ្តាប់បណ្ណា-ការ (ដែលយើងនិយមថាលើកជំនូន) លើកយកទៅជូនដល់ម៉ែឪខាងស្រី ។ រណ្តាប់លើកជំនូនមាន ស្រាអេក ១ ក្អម[1] ចន្ទុះ ១ ដើម មាន់ ១ និងនំខ្នោច[2]ដើម្បីទុកចែកជូនដល់ភ្ញៀវខាងស្រី ។

មេបាខាងស្រីទទួលយករណ្តាប់បណ្ណាការនេះហើយ ទើបសម្លាប់មាន់បោចពេមឲ្យស្អាត ហើយកាត់ជើងទាំងពីរ យកពោះវៀនព្រមទាំងគោះ ថ្លើមប្រមាត់បេះដូងទុក ឯសាច់តួមាន់ គេយកទៅស្ងោរសំរេចទុក រៀបចាយស្លកយកទៅសែនខ្មោច ។ លុះចំអិនរួចស្រេច មេបាហៅកូនប្រុសកូនស្រីមកអង្គុយផ្ទឹមគ្នា ដោយមិនបាច់តាំងតែងខ្លួនប្រណាទេ ទើបគេយកស្លកម្ហូបមាន់ស្ងោរមកដាក់ខាងមុខគូស្វាមីភរិយា ។ មេបាខាងប្រុសស្រីព្រមខាងញាតិជិតឆ្ងាយមកអង្គុយព័ទ្ធជុំវិញ ហើយទើបមេបាបង្គាប់ឲ្យកូនប្រុសយកដៃឧបពាក់កកូនស្រី ឯកូនស្រីវិញ ក៏យកដៃទៅ

---

១- ស្រាអេក ស្រាពួងមួយបែបដែលគេត្រាំដោយគ្រឿងផ្សំក្នុងកេង ។

២- របៀបធ្វើនំខ្នោច គេបេកអង្ករទាំបុកធ្វើជាម្សៅពូតជុំតូច ១ រួចខ្ចប់នឹងស្លឹករុំរួច ស្ងោរឲ្យឆ្អិន ។

តាក់តកូនប្រុសដែរ ។ នៅទីនេះ គេឃើញមានស្រីឆ្មបម្នាក់ ដៃម្ខាងកាន់ពោះវៀនមាន់ ដៃម្ខាងកាន់ជើងមាន់ អង្គុយខាងក្រោយកូនប្រុសកូនស្រី និយាយសែនព្រេនប្រាប់ខ្មោចថា ឥឡូវបានរៀបការកូនប្រុសកូនស្រីទាំងពីរនាក់នេះឲ្យធ្វើជាប្តីប្រពន្ធ សូមកុំឲ្យខ្មោចជីដូនជីតាធ្វើធ្លល់អ្វី មេឆ្មបនិយាយរួចកិច្ចបណ្ដើរ ដៃកាន់ជើងមាន់គោកកាយខ្នងកូនប្រុសស្រីបណ្ដើរអស់វារៈ ៣ ដង ទើបគេគ្រក់សបញ្ចូរបោលទៅក្រៅទៅ ។ ពិធីរៀបមង្គលការទុកជាហើយស្រេច មិនបាច់កាត់ចំណងដៃផ្សំដំណេកអ្វីទេ ។

ពេលឆ្លងទន្លេ : នៅពេលឆ្លងទន្លេ គេរកឆ្មបដែរ ។ ឆ្មបនៅរក្សាកូនចំនួន ៣ ថ្ងៃ ទើបទុកឲ្យស្រីសម្រាលកូននៅតែឯង ។ គេមិនឃើញមានពិធីបង្កក់ឆ្មបទេ ។ ពេលសំរាលកូនមកមានដុតភ្លើងជើងក្រាននៅចុងជើង គេអាំងភ្លើងដូចយើងអាំងមិនឲ្យរងា គេដេកអាំងភ្លើងដូចខ្មែរធម្មតាមិនបានទេ ព្រោះភ្លើងនៅតែក្នុងជើងក្រាន បើដេកអាំង មុខត្រូវក្ដៅតែបាតជើង ។

ពិធីឈាបនកិច្ច: មតកបុគ្គលទោះប្រុសក្ដីស្រីក្ដី តែដល់ស្លាប់ គេយកឈើពីរធ្វើជាមេសណ្ដូក ចងរែងជារនាប ហើយលើកសពដាក់ពីលើ រួចមនុស្សពីរនាក់សែងមុខក្រោយយកទៅកប់ ។ ក្រៅពីនេះមិនមានពិធីអ្វីប្លែកទេ ។

---

## ផ្នែកកំណត់ដឹងប្រវត្តិការណ៍

# ពិធីប្រគេនសញ្ញាបត្រ
# បំពោះព្រះតេជព្រះគុណ រាជ-កឹង វត្តសារាវ័ន
# ជាមេគណក្រុងភ្នំពេញ

---

កាលពីថ្ងៃសុក្រទី ៣១ សីហា ១៩៦៦ វេលារសៀល នៅក្នុងឧបដ្ឋានសាលាវត្តសារាវ័នតេជោ ក្រុងភ្នំពេញ មានធ្វើពិធីប្រគេនសញ្ញាបត្រចំពោះព្រះសិរីសម្មតិវង្ស រាជ-កឹង ជាមេគណ ក្រុងភ្នំពេញ ក្រោមអធិបតីភាព នៃសម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត (ជោតញ្ញាណោ) សង្ឃនាយកគណៈមហានិកាយ ។

នៅមុនពេលប្រារព្ធពិធីនេះ មានព្រះសង្ឃ គ្រហស្ថ ឧបាសក ឧបាសិកាជាច្រើន បាននិមន្ត-អញ្ជើញទៅរួបរួមក្នុងពិធីនេះ ដែលយើងសង្កេតឃើញជាអាទិ៍ ផ្នែកព្រះសង្ឃមានព្រះពោធិវង្ស ហួត-តាត អគ្គាធិការនៃពុទ្ធិកសិក្សា ព្រះធម្មលិខិត ម៉ឹង សែស ចៅអធិការវត្តមហាមន្ត្រី ព្រះមហាថេរទាំងឡាយជាចៅអធិការគ្រប់វត្តក្នុងក្រុង ព្រមទាំងព្រះសង្ឃជាច្រើនរូបទៀត ។ ផ្នែកគ្រហស្ថ មាន ឯ.ឧ.

ខេត.ជន ព្រះរាជប្រតិភូប្រចាំ ក្រុងភ្នំពេញ បុគ្គលិកសាលាក្រុង ចៅសង្កាត់នានាក្នុងក្រុង លោកនាយស្នងការប៉ូលិសក្រុង ព្រមទាំងឧបាសក ឧបាសិកាជាច្រើន ។

នៅវេលាម៉ោង ៤ និង ៤៥ នាទី សម្តេចព្រះសង្ឃនាយកនិមន្តដល់ ដោយមានព្រះថេរានុត្ថេរ ថ្វាយបង្គំទទួលសម្តេចសង្ឃតាមទំនៀម ។ លុះភ្ញៀវទាំងបព្វជិតទាំងគ្រហស្ថនិមន្តនិងមកជួបជុំហើយ ឯ.ឧ. ខេត-ជន បានថ្លែងអំណរដ៏ស្មោះស្ម័គ្រ ព្រមទាំងថ្លែងនូវសេចក្តីសង្ឃឹមថា ដោយមានការរៀបចំឲ្យមានមេគណប្រចាំក្រុងភ្នំពេញនេះ ជាការប្រសើរណាស់ ជាហេតុនាំឲ្យព្រះរាជធានីយើងមានរបៀបរៀបរយទីងស្អាតល្អគ្រប់បែបយ៉ាងតទៅ ។

បន្ទាប់មក សម្តេចព្រះសង្ឃនាយកបានថ្លែងអំពីដំណើរដែលនាំឲ្យកើតមានមេគណក្រុងភ្នំពេញ ។ សម្តេចព្រះសង្ឃនាយកបានបញ្ជាក់ថា មានព្រះរាជក្រមមួយលេខ ១២ ចុះខែកុម្ភៈ ១៩៤៣ ត្រង់ប្រការ ១៣ មានចែងថា "ត្រូវមានមេគណសម្រាប់ក្រុងភ្នំពេញ" តែតាំងពីពេលនោះមក ពុំទាន់បានរៀបចំនៅឡើយ ហើយចំនួនវត្តនៅក្នុងក្រុងខាងផ្នែកមហានិកាយមានតែ ១៧ វត្ត ឥឡូវដោយត្រូវពង្រីកទីក្រុង ត្រូវមានវត្ត ៤ ទៀត បានចូលមកក្នុងព្រះរាជធានី គឺចំនួនវត្តក្នុងក្រុងក៏កើនឡើងពី ១៧ ទៅ ២១ វត្ត ហើយកាលៈទេសៈក៏បានតម្រូវផង ទើប

សម្រេចរៀបចំឲ្យមានមេគណគ្រួនឡើង ដោយក្រសួងធម្មការ សាលាគ្រួនក្តុំពេញបានយល់ស្រប ហើយសម្តេចព្រះប្រមុខរដ្ឋ ព្រះអង្គក៏ទ្រង់សព្វព្រះរាជហឫទ័យ ឲ្យមានមេគណគ្រួនេះដែរ ហើយបានតម្រូវឲ្យព្រះសិរីសម្មតិវង្ស រាជ.គាំង ទទួលនាទីនេះ ។

លុះថ្ងៃចប់ហើយ សម្តេចព្រះសង្ឃនាយក បានប្រគល់ត្រាជាសញ្ញាតែងតាំងចំពោះព្រះសិរីសម្មតិវង្ស រាជ.គាំង ជាមេគណគ្រួនក្តុំពេញ ពេញសមត្ថភាពតាំងពីពេលនេះតទៅ ។

យើងសូមដកស្រង់នូវជីវប្រវត្តិ នៃព្រះសិរីសម្មតិវង្ស រាជ.គាំង មេគណគ្រួនក្តុំពេញ ដោយសង្ខេបដូចតទៅនេះ៖

"ព្រះសិរីសម្មតិវង្ស រាជ.គាំង មានព្រះជន្មាយុ ៥២ ឆ្នាំ ញោមប្រុសនាម អ៊ួង រាជ ញោមស្រីនាម ក្រែស-ឈុំកា ។ លោកកើតពីថ្ងៃទី ២៣ វិច្ឆិកា ១៩១០ នៅឃុំត្រាកោង ស្រុកកំពង់ស្ពាន ខែត្រព្រែកឫស្សី (កម្ពុជាក្រោម) ។ កាលនៅពីកុមារ បានទៅសិក្សាអក្សរសាស្ត្រនៅវត្តតេនបទុម ។ អាយុ ១១ ឆ្នាំ បានបួសជាសាមណេរ លុះដល់គ្រប់អាយុក៏បានបំពេញឧបសម្បទាជាភិក្ខុ បាននាមឆាយាជា សុវណ្ណកេសរ លោកបានសិក្សារៀនសូត្រគន្ថធុរៈ និង វិបស្សនាធុរៈ បានទទួលជាឋានានុក្រម បានទទួលជាពជាគណៈទី ៤ ជាពជាគណៈទី ៣ បានធ្វើជាសាស្ត្រាចារ្យ កាន់ការជាអគ្គាធិការរងនៃពុទ្ធិកសិក្សា ជាទីប្រឹក្សានៃ

ពុទ្ធិកសមាគមកម្ពុជរដ្ឋ សមាគមមិត្តពុទ្ធិកវិទ្យាល័យ សមាគមមិត្រខ្មែរកម្ពុជាក្រោម ជាជនកសមាជិក ជាឧបការីសមាជិក ទីងជាលេខាធិការនៃសមាគមគិលានុបដ្ឋានព្រះមហាក្សត្រិយានី ។ ល ។

លោកបានទទួលមេដៃយ៍អស្សរិទ្ធមុនីសារករណ៍ពីឆ្នាំ ១៩៥៣ ហើយនៅឆ្នាំ ១៩៦២ នេះ លោកបានទទួលនាទីជាមេគណក្រុងភ្នំពេញ ។

យើងសូមបញ្ជាក់ថា ក្នុងឱកាសពិធីនេះ ថៅកែភេសជ្ជៈសេរីនអាប់មានសេចក្តីជ្រះថ្លា បានប្រគេននូវភេសជ្ជៈសេរីនអាប់ចំនួន ២០០ ដប សម្រាប់ចាត់ចែងក្នុងពិធីនេះផង ។ ពិធីនេះបានចប់សព្វគ្រប់នៅវេលាម៉ោង ៦ គត់ ។

---